# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៦



វត្តនិគ្រោធវ័ "គល់ទទឹង"

# អភិធម្មត្ថសង្គហៈ

# បរិច្ឆេទទី ៦

*វត្តនិគ្រោធវ័ន "គល់ទទឹង"*

*រៀបរៀងដោយ* **ភិក្ខុ អគ្គធីរោ គង់ សុមិត្ត**

*ព.ស. ២៥៥៥*

# សម្តែងព្រះអភិធម្ម នៅឋានតាវត្តិង្ស

កាលព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ចាំព្រះវស្សាទី៧ នៅឋានតាវត្តិង្សទេវលោក ក្នុងគ្រាដែលបានសំដែងយមកបាដិហារ្យផ្ចាញ់ពួកតិរ្ថិយរួចហើយ បានគង់លើសិលាសនៈ ឈ្មោះបណ្ឌុកម្ពល ក្រោមដើមបារិឆត្ត ទ្រង់ព្រះសិរីសោភា ដូចព្រះអាទិត្យឧទ័យឡើងលើភ្នំយុគន្ធរ ដែលពួកនៃទេវតាទាំងឡាយក្នុងម៉ឺនចក្រវាឡបានមកប្រជុំគ្នា ហែហមសម្តេចព្រះបរមសាស្តាចារ្យ ទ្រង់ធ្វើសន្តុសិតទេវបុត្រដែលធ្លាប់ជាពុទ្ធមាតា ឱ្យជាប្រធាននៃពួកទេវតាទាំងឡាយ ហើយត្រាស់កថាមគ្គព្រះអភិធម្មថា "**កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា**"ជាដើម ទ្រង់សម្តែងដោយន័យនេះ ជាប់តរហូតអស់មួយព្រះវស្សា ដោយតេជៈនៃព្រះសព្វញ្ញុតញ្ញាណនោះ ។ ក៏កាលដែលទ្រង់សម្តែងធម៌នោះ ក្នុងវេលាភិក្ខាចារទ្រង់និម្មិតព្រះពុទ្ធនិមិត្តដោយទ្រង់អធិដ្ឋានថា "ព្រះពុទ្ធនិមិត្ត

នេះ ចូរសម្តែងធម៌ ឈ្មោះប៉ុណ្ណោះ ដរាបដល់តថាគតមក" ហើយក៏ស្តេចយាងទៅព្រៃហេមពាន្ត ទ្រង់ទំពាឈើស្ទន់ឈ្មោះនាគលតា ខ្ពុរព្រះឱស្ឋក្នុងស្រះអនោតត្ត នាំបិណ្ឌបាតអំពីឧត្តរកុរុទ្វីប បានធ្វើភត្តកិច្ចក្នុងរោងធំទូលាយហើយ ។ ព្រះសារីបុត្រទៅធ្វើវត្តចំពោះព្រះសាស្តាក្នុងទីនោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ជាទេវតារបស់ទេវតា ជាអ្នកនាំវិសេសអង្គនោះ កាលទ្រង់សំដែងអភិធម្មណា ដល់ទេវតាទាំងឡាយហើយ ក៏បានត្រាស់ប្រាប់ដល់ព្រះសារីបុត្តត្ថេរ អ្នកឧបដ្ឋាកព្រះមហេសីជាម្ចាស់ ក្នុងអនោតត្តស្រះ ដោយន័យ (សង្ខេប)ទៀតថា "ម្នាលសារីបុត្រ ថ្ងៃនេះតថាគតបានសម្តែងធម៌ឈ្មោះប៉ុណ្ណោះ អ្នកចូរប្រាប់ដល់(ភិក្ខុ ៥០០) ជាកូនសិស្សរបស់អ្នក" ព្រះថេរៈបានស្តាប់ហើយ ក៏បាននិមន្តមកកាន់លំនៅឋាន ហើយប្រាប់ដល់ភិក្ខុទាំងឡាយ, ព្រះអភិធម្មនោះ ដែលភិក្ខុទាំងឡាយបានទ្រទ្រង់ចាំទុកហើយ ដោយប្រការយ៉ាងនេះ ។

# ជីវប្រវត្តិសង្ខេប

ភិក្ខុ **គង់-សុមិត្ត** គង់នៅពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន វត្តនិគ្រោធវ័ន គល់ទទឹង

ញោមប្រុស ឈ្មោះ គង់-តិក (ស្លាប់) ញោមស្រី ឈ្មោះ ហុក-តាង រស់នៅក្នុងភូមិវិទ្ធិត ឃុំព្រែកខ្ពប ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

កើតនៅថ្ងៃព្រហស្បតិ៍ ៩ កើត ខែមិគសិរ ឆ្នាំ ថោះ ព.ស. ២៥១៩ - គ.ស. ១៩៧៦ ។ មានបងប្អូន ៧ នាក់ គឺ ប្រុស ៥ នាក់ ស្រី ២ នាក់. ជាកូនពៅ

ក្នុងកុមារ បានចូលរៀនសាលារដ្ឋ (ក្តាំងផា និង ព្រែកហ្លួង)ដល់ថ្នាក់ទី ៨ ។

ក្នុងព.ស.២៥៣៧ មានអាយុ១៩ឆ្នាំ បួសជាសាមណេរ ក្នុងសំណាក់ឧបជ្ឈាយ៍ ព្រះនាម ឡូយ-លឿង វត្តស្លាកែត មកគង់នៅវត្តក្តាំងផា ខេត្តបាត់ដំបង ។

ព.ស. ២៥៣៨ មានអាយុគ្រប់ ២០ បានឧបសម្បទាជាភិក្ខុភាវៈ ។ ព.ស. ២៥៣៩ មកគង់នៅវត្តសមសាន្ត (ខេត្តបាត់ដំបង) រៀនវិន័យ-អភិធម្ម ។ ព.ស. ២៥៤០ មកនៅវត្តនិគ្រោធវ័ន ខេត្តកណ្ដាល រៀនធម៌វិន័យបន្ត ។ ព.ស. ២៥៤១ បេញទៅគង់នៅវត្តខេមវ័ន (ខេត្តកំបាម) បង្រៀនធម៌វិន័យ ។ ព.ស. ២៥៤៥ បានត្រឡប់មកវត្តនិគ្រោធវ័នវិញហើយលាសិក្ខា បានខិតខំ រៀបចំ និងជួយសរសេរសៀវភៅធម៌-វិន័យ ។ ព.ស. ២៥៤៦ បានបួសជាសាមណេរវិញទៀត ក្នុងសំណាក់ព្រះឧបជ្ឈាយ៍ ព្រះនាម ឃី-ទិត វត្តកោះក្របី ឃុំព្រែកថ្មី ស្រុកគៀនស្វាយ ខេត្តកណ្ដាល បានជួយបង្រៀនព្រះវិន័យដល់ព្រះសង្ឃ ក្នុងវត្តនិគ្រោធវ័ន ។ ព.ស. ២៥៤៧ បានឧបសម្បទាជាភិក្ខុ បានបង្រៀនព្រះវិន័យដល់ព្រះសង្ឃ បង្រៀនអភិធម្មដល់ដូនជី ក្នុងវត្តនិគ្រោធវ័ន និងខិតខំរៀបចំសៀវភៅធម៌-វិន័យរហូតមក ។

# អភិធម្មត្ថសង្គហកថា

គម្ពីរអភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ព្រះអនុរុទ្ធាចារ្យ បានចងក្រងឡើង ។

អភិធម្មត្ថសង្គហៈ មាន ៩ បរិច្ឆេទ គឺ

បរិច្ឆេទទី១ ចិត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកចិត្ត ៨៩ ឬ១២១

បរិច្ឆេទទី២ ចេតសិកសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកចេតសិក ៥២

បរិច្ឆេទទី៣ បកិណ្ណកសង្គហៈ ការសម្តែងសង្គ្រោះនិងចែកបកិណ្ណក ៦ ពួក

បរិច្ឆេទទី៤ វិថីសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកវិថីចិត្ត

បរិច្ឆេទទី៥ វិថីវិមុត្តសង្គហវិភាគ ការសម្តែងសង្គ្រោះនិងចែកវិថីវិមុត្ត

បរិច្ឆេទទី៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ការសម្ដែងសង្គ្រោះ
និងចែករូបនិងនិព្វាន

បរិច្ឆេទទី៧ សមុច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិង
ចែកពួកធម៌ជាក្រុម ៗ

បរិច្ឆេទទី៨ បច្ចយសង្គហវិភាគ ការសម្ដែងសង្គ្រោះនិង
ចែកបច្ច័យ១២ និង២៤

បរិច្ឆេទទី៩ កម្មដ្ឋានវិភាគ ការសម្ដែងចែកកម្មដ្ឋាន
៤០ និងវិបស្សនា ។

សៀវភៅអភិធម្មនេះ ព្រះអនុរុទ្ធាចារ្យបានប្រមូលចង ក្រងអំពីបិដក និងអដ្ឋកថា ហើយបានចែកជាបរិច្ឆេទតាម ប្រភេទនៃបរមត្ថធម៌ ដើម្បីងាយស្រួលក្នុងការសិក្សា គឺ បរិច្ឆេទទី១ សម្ដែងចិត្តបរមត្ថ, បរិច្ឆេទទី២ សម្ដែងចេតសិក បរមត្ថ, បរិច្ឆេទទី៣, ៤, ៥ សម្ដែងចិត្តបរមត្ថ និងចេតសិក បរមត្ថរួមគ្នា, បរិច្ឆេទទី ៦ សម្ដែងរូបបរមត្ថ, និងនិព្វាន បរមត្ថ, បរិច្ឆេទទី៧, ៨, ៩ សម្ដែងបរមត្ថទាំង ៤ រួមគ្នា ។

# បុព្វកថា

សៀវភៅអភិធម្មនេះ ខ្ញុំបានសរសេរក្នុងព.ស. ២៥៤៥ ចប់នៅក្នុងព.ស. ២៥៤៧ ។ ព.ស. ២៥៥២ បានរៀបចំជាសៀវភៅធំ ឈ្មោះថា អភិធម្មត្ថសង្គហៈ ៩ បរិច្ឆេទ ។ ព.ស. ២៥៥៥ ដោយសេចក្ដីត្រូវរបស់អ្នកសិក្សាក៏បានចែកតាមបរិច្ឆេទនីមួយ ៗវិញ ដើម្បីងាយកាន់សិក្សា ។

ការរៀបចំសៀវភៅអភិធម្មត្ថសង្គហៈនេះ បានចប់សព្វគ្រប់ ហើយ បើមានពាក្យឬសេចក្ដីណានៅខុស ក៏សូមអភ័យទោស និងសូមមេត្តាកែ សម្រួលផងចុះ ។

គម្ពីរព្រះអភិធម្ម ជាគម្ពីរដែលសម្ដែងឡើងនូវធម៌ពិត គឺ សច្ចធម៌ បរមត្ថធម៌ និងបង្ហាញនូវផ្លូវបដិបត្តិឆ្ពោះទៅរកទីរំលត់ទុក្ខ គឺ ព្រះនិព្វាន ។ សត្វលោកដែលកើតមកសុទ្ធតែមានអវិជ្ជា និងតណ្ហាគ្រប់គ្នា មានតែព្រះពុទ្ធនិងព្រះបច្ចេកពុទ្ធទេ ដែលអាចត្រាស់ដឹងនូវធម៌ពិត កម្ចាត់អវិជ្ជាបានដោយខ្លួនព្រះអង្គឯង ក្រៅពីនោះ ត្រូវតែអាស្រ័យ

ព្រះពុទ្ធ ដែលទ្រង់មានព្រះទ័យមហាករុណាសម្ដែងប្រាប់ ទើបអាចយល់ដឹងស្គាល់ធម៌ពិត និងបានឃើញផ្លូវបដិបត្តិដល់ព្រះនិព្វានជាទីរំលត់ទុក្ខបាន ។

កាលបើពុទ្ធបរិស័ទទាំងអស់ សិក្សានូវព្រះអភិធម្មបានយល់ដឹងហើយ បញ្ញាក៏កើតឡើង បានឃើញនូវសភាវធម៌ពិតទាំងដែលយើងសព្វថ្ងៃបានជួប បានទាន់ព្រះធម៌កំពុងឋិតនៅសម្រាប់ក្រេបជញ្ជក់ធម្មរស ហើយធ្វើឱ្យយើងមានសម្រស់ក្នុងជីវិត មិនឋិតនៅក្នុងភាពស្ងិតស្រពោន និងសម្រេចមគ្គផលតាមឧបនិស្ស័យដែលយើងបានសន្សំមក, ព្រោះហេតុដូច្នេះទើបខ្ញុំព្យាយាមរៀបចំសៀវភៅនេះឡើង ។ ម្យ៉ាងទៀត សៀវភៅនេះ ក៏ដូចជាសាវកមួយអង្គដែលឈ្លាសវៃនាំយកព្រះពុទ្ធដីកាមកប្រាប់ ហើយពន្យល់សេចក្ដីនោះ ឱ្យយើងបានយល់ដឹងឬចាត់ថា ជាគ្រូក៏បាន ។

ការរៀបចំសៀវភៅធម៌នេះ ជាបុណ្យកុសលមួយ

យ៉ាងល្អប្រសើរ ដែលខ្ញុំព្រះករុណា អាត្មាភាព និងពុទ្ធបរិស័ទទាំងឡាយ បានរួបរួមសាមគ្គីជួយឧបត្ថម្ភ ដោយកម្លាំងកាយចិត្ត និងថវិកា ជាចេតនាមហាកុសលថ្នាក់ធម្មទាន និងធម្មបូជា យ៉ាងពេញចិត្តគ្រប់ ៗគ្នា ។ ដោយអំណាចនៃបុណ្យនេះ នឹងនាំឱ្យបានទទួលនូវសេចក្ដីសុខ ជាពិសេស គឺបាននូវបញ្ញាដែលជាពន្លឺញ៉ាំងជីវិតឱ្យរុងរឿងគ្រប់ ៗ ជាតិ រហូតដល់បានលះបង់នូវមន្ទិលគឺ កិលេស ដែលយើងគ្រប់ ៗ គ្នាចង់បាននូវ ការត្រាស់ដឹងនូវសច្ចធម៌ ឃើញច្បាស់នូវព្រះនិព្វាន ដែលជាទីបំផុតទុក្ខ ។ ម្យ៉ាងទៀត បញ្ញានេះឯង អាចឱ្យសម្រេចតាមសេចក្ដីប្រាថ្នានោះបាន ។

ខ្ញុំព្រះករុណាអាត្មាភាព សូមអនុមោទនានូវបុណ្យកុសលរបស់ពុទ្ធបរិស័ទ ទាំងអស់ ដែលបានឧបត្ថម្ភថវិកាជាធម្មទាន និងការខិតខំសិក្សានេះ ។ ម្យ៉ាងទៀត សូមពុទ្ធ

បរិស័ទទាំងអស់ អនុមោទនាយកនូវបុណ្យដែលខ្ញុំព្រះករុណាអាត្មាភាព បានរៀបចំបោះពុម្ពព្រះអភិធម្មនេះផងចុះ ។ សូមឱ្យពុទ្ធបរិស័ទទាំងអស់ មានបញ្ញា ភ្លឺថ្លាមោះមុត ជាគ្រឿងត្រាស់ដឹងនូវសច្ចធម៌ សូមបានសម្រេចនូវសម្បត្តិលោកិយៈ និងលោកុត្តរៈ មានចិត្តល្អបរិសុទ្ធរួចផុតចាកទុក្ខដល់ព្រះនិព្វានគ្រប់ ៗ គ្នា កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអនុមោទនា !!!

ថ្ងៃ១៥កើត ខែស្រាព ឆ្នាំថោះ ត្រីស័ក ព.ស.២៥៥៥

# ឯកសារវិគ្រោះ

| អក្សរកាត់ | អក្សរពេញ | ភាគគម្ពីរ |
| --- | --- | --- |
| វិន. បារា. | វិន័យ បារាជិក | បិដកភាគ ១ |
| វិន. បាចិ. | វិន័យ បាចិត្តិយ | បិដកភាគ ៣ |
| ទីឃ. មហា. | ទីឃនិកាយ មហាវគ្គ | បិដកភាគ ១៦. ១៧. |
| ទីឃ. បាដិ. | ទីឃនិកាយ បាដិកវគ្គ | បិដកភាគ ១៨. ១៩ |
| មជ្ឈិ. មូល. | មជ្ឈិមនិកាយ មូលបណ្ណាសក | បិដកភាគ ២០. ២១. |
| មជ្ឈិ. មជ្ឈិ. | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក | បិដកភាគ ២៣. |
| មជ្ឈិ. ឧប. | មជ្ឈិមនិកាយ ឧបរិបណ្ណាសក | បិដកភាគ ២៦. ២៨. |
| សំយុ. សគា. | សំយុត្តនិកាយ សគាថវគ្គ | បិដកភាគ ៣០ |
| សំយុ. សឡា. | សំយុត្តនិកាយ សឡាយតនវគ្គ | បិដកភាគ ៣៥ |
| អង្គុ. ឯក. | អង្គុត្តរនិកាយ ឯកនិបាត | បិដកភាគ ៤០ |
| អង្គុ. តិក. | អង្គុត្តរនិកាយ តិកនិបាត | បិដកភាគ ៤១ |
| អង្គុ. ចក្កុ. | អង្គុត្តរនិកាយ ចតុក្កនិបាត | បិដកភាគ ៤២ |
| អង្គុ. អដ្ឋ. | អង្គុត្តរនិកាយ អដ្ឋកនិបាត | បិដកភាគ ៤៨ |
| ខុទ្ទ. ធម្ម. | ខុទ្ទកនិកាយ ធម្មបទ | បិដកភាគ ៥២ |
| ខុទ្ទ. ឥតិ. | ខុទ្ទកនិកាយ ឥតិវុត្តក. | បិដកភាគ ៥៣ |

| អក្សរកាត់ | អក្សរពេញ | ភាគគម្ពីរ |
|---|---|---|
| ខុទ្ទ. សុត្ត. | ខុទ្ទកនិកាយ សុត្តនិបាត | បិដកភាគ ៥៤ |
| ខុទ្ទ. ជាត. | ខុទ្ទកនិកាយ ជាតក | បិដកភាគ ៥៨ |
| ខុទ្ទ. មហា. | ខុទ្ទកនិកាយ មហានិទ្ទេស | បិដកភាគ ៦៤. ៦៦. |
| ខុទ្ទ. ចូឡ. | ខុទ្ទកនិកាយ ចូឡនិទ្ទេស | បិដកភាគ ៦៧. |
| អភិ. សង្គ. | អភិធម្ម ធម្មសង្គណី | បិដកភាគ ៧៨. ៧៩. |
| អភិ. វិភ. | អភិធម្ម វិភង្គ | បិដកភាគ ៨០. ៨១. ៨២. |

សទ្ធម្មប្បកាសិនី អដ្ឋកថានៃខុទ្ទកនិកាយ បដិសម្ភិទាមគ្គ

អត្ថយោជនា, វិភាវិនីដីកា,

លេខដែលនៅបន្ទាប់គឺ ខាងដើមជាភាគគម្ពីរ កណ្តាលជាលេខឃ្នាប ខាងចុងជាលេខទំព័រ ឧទាហរណ៍ : ៨០. ២/១ គឺ បិដកភាគ ៨០ លេខឃ្នាប ២ ទំព័រ ១ ។

# បញ្ជីមាតិកា អភិធម្មត្ថសង្គហៈ

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


*សម្តេចព្រះអភិធម្ម នៅឋានតាវត្តិង្ស ... ... ... ... ក*

*ជីវប្រវត្តិសង្ខេប ... ... ... ... ... ... ... ... ... ... ... ... គ*

*អភិធម្មត្ថសង្គហកថា ... ... ... ... ... ... ... ... ... ... ង*

*បុព្វកថា ... ... ... ... ... ... ... ... ... ... ... ... ... ... ... ឆ*

*ឯកសារវិគ្រោះ ... ... ... ... ... ... ... ... ... ... ... ... ជ*

*បញ្ជីមាតិកា ... ... ... ... ... ... ... ... ... ... ... ... ... ឌ*


**អភិធម្មត្ថសង្គហៈបរិច្ឆេទទី ៦ រូបសង្គហវិភាគ**


*សង្គហគាថាទី១-២ រូបសង្គហៈ ៥ន័យ ... ... ... ... ១*

*រូបមាន ៧ ន័យ ... ... ... ... ... ... ... ... ... ... ... ... ... ... ៣*

*លក្ខណាទិចតុក្កៈរបស់រូប ... ... ... ... ... ... ... ... ១១*

*រូបន័យទី ១ រូបសមុទ្ទេស ... ... ... ... ... ... ... ... ... ... ១២*

*សង្គហគាថាទី៣-៤ ... ... ... ... ... ... ... ... ... ... ... ... ១២*

*រូប ១១ ពួក ... ... ... ... ... ... ... ... ... ... ... ... ... ... ១៦*

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

ពួកទី ១ : មហាភូតរូប ៤ ... ... ... ... ... ... ... ១៦
ភូតៈមាន ៧ ន័យ ... ... ... ... ... ... ... ... ១៧
១-បឋវីធាតុ ... ... ... ... ... ... ... ... ... ... ... ... ១៩
២-អាបោធាតុ ... ... ... ... ... ... ... ... ... ... ... ២៣
៣-តេជោធាតុ ... ... ... ... ... ... ... ... ... ... ... ២៨
៤-វាយោធាតុ ... ... ... ... ... ... ... ... ... ... ... ៣០
ពួកទី ២ : បសាទរូប ៥ ... ... ... ... ... ... ... ... ៣៩
១-ចក្ខុបសាទរូប ... ... ... ... ... ... ... ... ... ... ៤០
២-សោតបសាទរូប ... ... ... ... ... ... ... ... ... ៤៨
៣-ឃានបសាទរូប ... ... ... ... ... ... ... ... ... ... ៥២
៤-ជិវ្ហាបសាទរូប ... ... ... ... ... ... ... ... ... ... ៥៤
៥-កាយបសាទរូប ... ... ... ... ... ... ... ... ... ... ៥៦
ពួកទី៣ : វិសយរូប ៧ ... ... ... ... ... ... ... ... ... ៦១
១-រូបារម្មណ៍ "វណ្ណ" ... ... ... ... ... ... ... ... ៦២

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

២-សទ្ទារម្មណ៍ "សំឡេង" ... ... ... ... ... ... ... ៦៣
៣-គន្ធារម្មណ៍ "ក្លិន" ... ... ... ... ... ... ... ... ... ៦៥
៤-រសារម្មណ៍ "រស" ... ... ... ... ... ... ... ... ៦៦
៥-ផោដ្ឋព្វារម្មណ៍ "សម្ផស្ស" ... ... ... ... ... ... ៦៩
ពួកទី៤ : ភាវរូប ២ ... ... ... ... ... ... ... ... ... ៧០
១-ឥត្ថីភាវរូប ... ... ... ... ... ... ... ... ... ... ... ៧០
២-បុរិសភាវៈ ... ... ... ... ... ... ... ... ... ... ... ៧២
ពួកទី ៥ ហទយរូប ... ... ... ... ... ... ... ... ... ៧៥
ពួកទី ៦ : ជីវិតរូប ... ... ... ... ... ... ... ... ... ៨០
ពួកទី៧ : អាហាររូប ... ... ... ... ... ... ... ... ... ៨២
ពួកទី៨ : បរិច្ឆេទរូប ... ... ... ... ... ... ... ... ... ៨៦
ពួកទី ៩ : វិញ្ញត្តិរូប ២ ... ... ... ... ... ... ... ... ៩០
១-កាយវិញ្ញត្តិ ... ... ... ... ... ... ... ... ... ... ... ៩០
២-វចីវិញ្ញត្តិរូប ... ... ... ... ... ... ... ... ... ... ... ៩៣

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

ពួកទី១០ : វិការរូប ៣ ... ... ... ... ... ... ... ... ... ៩៦
ពួកទី ១១ : លក្ខណរូប ៤ ... ... ... ... ... ... ... ៩៩
១-ឧបចយរូប ... ... ... ... ... ... ... ... ... ... ... ១០១
២- សន្តតិរូប ... ... ... ... ... ... ... ... ... ... ... ១០៣
៣-ជរតារូប ... ... ... ... ... ... ... ... ... ... ... ... ១០៥
៤-អនិច្ចតារូប ... ... ... ... ... ... ... ... ... ... ... ១០៨
រូបន័យទី ២ រូបវិភាគ ... ... ... ... ... ... ... ... ... ... ... ... ១១០
ឯកវិធន័យ ... ... ... ... ... ... ... ... ... ... ... ... ... ១១០
ទុកន័យ ... ... ... ... ... ... ... ... ... ... ... ... ... ... ១១៤
សង្គហគាថាទី៥ ... ... ... ... ... ... ... ... ... ... ... ... ១១៤
ដោយចែករូប ២៨ ជា ១១ គូ ... ... ... ... ... ... ... ១១៤
គូទី១. អជ្ឈត្តិករូប និងពាហិររូប ... ... ... ... ... ... ១១៤
គូទី២. វត្ថុរូប និងអវត្ថុរូប ... ... ... ... ... ... ... ... ១១៥
គូទី៣. ទ្វាររូប និងអទ្វាររូប ... ... ... ... ... ... ... ... ១១៦

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ

គូទី៤. ឥន្ទ្រិយរូប និងអនិន្ទ្រិយរូប ... ... ... ... ... ១១៧
គូទី៥. ឱឡារិករូប និងសុខុមរូប ... ... ... ... ... ... ១១៨
គូទី៦. សន្តិកេរូប និងទូរេរូប ... ... ... ... ... ... ... ១១៩
គូទី៧. សប្បដិឃរូប និងអប្បដិឃរូប ... ... ... ... ១១៩
គូទី៨. ឧបាទិន្នរូប និងអនុបាទិន្នរូប ... ... ... ... ... ១២០
គូទី៩. សនិទស្សនរូប និងអនិទស្សនរូប ... ... ... ១២១
គូទី១០. គោចរគាហិករូប និងអគោចរគាហិករូប ... ១២១
គូទី១១. អវិនិព្ភោគរូប និង វិនិព្ភោគរូប ... ... ... ១២៣
រូបន័យទី ៣ រូបសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ១២៤
សមុដ្ឋាននៃរូបមាន ៤ ... ... ... ... ... ... ... ... ... ... ... ១២៥
១-កម្មសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ... ១២៥
២-ចិត្តសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ... ១២៧
៣-ឧតុសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ... ១៣៣
៤-អាហារសមុដ្ឋាន ... ... ... ... ... ... ... ... ... ... ... ១៣៥

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**


អាហារជរូបមាន ១២ ... ... ... ... ... ... ... ... ... ១៣៨

សរុបរូបដែលកើតអំពីសមុដ្ឋាន ៤ ... ... ... ... ... ១៣៨

សម្ដែងរូបសមុដ្ឋាន ៤ ... ... ... ... ... ... ... ... ... ... ១៣៩

១-កម្មជរូប ១៨ ... ... ... ... ... ... ... ... ... ... ... ១៣៩

២-ចិត្តជរូប ១៥ ... ... ... ... ... ... ... ... ... ... ... ១៣៩

៣-ឧតុជរូប ១៣ ... ... ... ... ... ... ... ... ... ... ... ១៤០

៤-អាហារជរូប ១២ ... ... ... ... ... ... ... ... ... ... ១៤០

ចំនួនរូប ដោយសមុដ្ឋាន ៥ ន័យ ... ... ... ... ... ១៤០

សរុបរូបដែលជាសមុដ្ឋាន ដោយអភិធម្មន័យ ... ១៤២

បែកសមុដ្ឋានិករូប ដោយសុត្តន្តន័យ ... ... ... ... ១៤៣

១- សសម្ភារបថវី ២០ ... ... ... ... ... ... ... ១៤៣

២- សសម្ភារអាបោ ១២ កោដ្ឋាស ... ... ... ១៤៤

៣- សសម្ភារតេជោ ៤ កោដ្ឋាស ... ... ... ... ១៤៥

៤- សសម្ភារវាយោ ៦ កោដ្ឋាស ... ... ... ... ១៤៥

**មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ**

ចែកសមុដ្ឋាន ៤ ក្នុងកោដ្ឋាស ៤២ ... ... ... ... ... ១៤៦
រូបន័យទី ៤ រូបកលាប ... ... ... ... ... ... ... ... ... ... ... ១៤៧
សង្គហគាថាទី៨-៩ ... ... ... ... ... ... ... ... ... ... ... ១៤៨
១-កម្មជកលាប ៩ ... ... ... ... ... ... ... ... ... ... ... ... ១៤៩
ចែកកម្មជកលាប ៩ ដោយកាយ ៣ ចំណែក ១៥២
ឋានរបស់កលាប ក្នុងកាយ ៣ ចំណែក ... ... ... ១៥៣
២-ចិត្តជកលាប ៦ ... ... ... ... ... ... ... ... ... ... ... ១៥៤
ចិត្តជរូប - ចិត្តជកលាប ... ... ... ... ... ... ... ... ... ១៥៦
ឋានរបស់ចិត្តជកលាប ៦ ក្នុងកាយ ៣ ចំណែក ១៥៨
៣-ឧតុជកលាប ... ... ... ... ... ... ... ... ... ... ... ... ... ១៥៩
ឧតុជកលាប ៤ ដែលកើតខាងក្នុងកាយសត្វ ... ... ១៦០
ឧតុជកលាប ២ កើតខាងក្រៅ ... ... ... ... ... ... ... ១៦២
ឋានរបស់ឧតុជកលាបក្នុងកាយ ៣ ចំណែក ... ... ១៦២
ឧតុជកលាប ៤ យ៉ាងទៀត ... ... ... ... ... ... ... ... ១៦៣

**មាតិកា អភិធម្មត្ថសង្គហៈ** **ទំព័រ**

៤-អាហារជកលាប ២ ... ... ... ... ... ... ... ... ... ... ... ១៦៤
អាហារជរូប-អាហារជកលាប ... ... ... ... ... ... ... ១៦៥
ឋាននៃអាហារ ២ ក្នុងកាយ ៣ ចំណែក ... ... ... ១៦៦
កលាប ២១ ក្នុងអាការ ៤២ ... ... ... ... ... ... ១៦៦
១. សសម្ភារបឋវី ២០ មាន ២ ន័យ ... ... ១៦៦
២. សសម្ភារអាបោ ១២ មាន ៣ ន័យ ... ១៦៧
៣. សសម្ភារតេជោ ៤ មាន ២ ន័យ ... ... ១៦៨
៤. សសម្ភារវាយោ ៦ មាន ២ ន័យ ... ... ១៦៩
រូបកលាប ២១ ក្នុងសសម្ភាររូប ៥ ... ... ... ... ... ១៦៩
ការបរិភោគអាហារ ... ... ... ... ... ... ... ... ... ... ... ១៧១
រូបន័យទី ៥ រូបបវត្តិក្កម ... ... ... ... ... ... ... ... ... ... ... ១៧២
សង្គហគាថាទី១០ ... ... ... ... ... ... ... ... ... ... ... ១៧៥
១-សម្តែងរូបដោយភូមិ ២៧ ... ... ... ... ... ... ... ១៧៦
សង្គហគាថាទី១១ ... ... ... ... ... ... ... ... ... ... ... ១៧៦

**មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ**

ចែករូប២៨ ក្នុងកាមភូមិ១១ ដោយសមុដ្ឋាន៤ ... ១៧៩
ន័យមួយទៀត រាប់សមុដ្ឋានិករូបដោយពិស្តារ ... ១៨០
ចែករូប២៣ ក្នុងរូបភូមិ១៥ ដោយសមុដ្ឋាន៣ ... ១៨១
ចែករូប ១៧ ដែលកើតក្នុងអសញ្ញសត្តភូមិ
ដោយសមុដ្ឋាន ២ ... ... ... ... ... ... ... ... ... ១៨២
២-សម្តែងរូបដោយកាល ៣ ... ... ... ... ... ... ... ១៨៣
សង្គហគាថាទី១២ ... ... ... ... ... ... ... ... ... ... ... ១៨៣
៣-សម្តែងរូប ២៨ ដោយកំណើត ៤ ... ... ... ... ... ១៨៧
ចែកកំណើត ៤ ដោយកម្មជកលាប ៩ ... ... ... ១៩២
ឱមកន័យ ក្នុងបដិសន្ធិកាល គឺ ... ... ... ... ... ... ១៩២
សម្តែងកម្មជកលាប ដែលកើតក្នុងបវត្តិកាល ... ... ១៩៥
ឱបបត្តិកន័យ ... ... ... ... ... ... ... ... ... ... ... ... ១៩៦
សម្តែងការកើតឡើងនៃតិជរូប ... ... ... ... ... ... ... ១៩៨

## មាតិកា អភិធម្មត្ថសង្គហៈ ទំព័រ


និព្វានបរមត្ថ ... ... ... ... ... ... ... ... ... ... ... ... ... ... ... ... ២០២

វចនត្ថៈរបស់និព្វាន ... ... ... ... ... ... ... ... ... ... ... ... ២០២

សង្គហគាថាទី១៣ ... ... ... ... ... ... ... ... ... ... ... ... ២០៤

អធិប្បាយ គុណរបស់ព្រះនិព្វាន ... ... ... ... ... ... ២០៥

ព្រះនិព្វានមាន ១ ... ... ... ... ... ... ... ... ... ... ... ... ... ២០៧

លក្ខណាទិតិកៈរបស់ព្រះនិព្វាន ... ... ... ... ... ... ... ២០៧

ព្រះនិព្វានមាន ២ ... ... ... ... ... ... ... ... ... ... ... ... ... ២០៩

អធិប្បាយ និព្វានធាតុ ២ ... ... ... ... ... ... ... ... ២០៩

ព្រះនិព្វានមាន ៣ ... ... ... ... ... ... ... ... ... ... ... ... ... ២១១

សង្គហគាថាទី១៤ ... ... ... ... ... ... ... ... ... ... ... ... ២១៤

អវសានគាថា ... ... ... ... ... ... ... ... ... ... ... ... ... ២១៤

# អភិធម្មត្ថសង្គហៈ

## បរិច្ឆេទទី ៦ រូបសង្គហវិភាគ

*នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។*

### សង្គហគាថា

១. ឯត្តាវតា វិភត្តា ហិ     សប្បភេទប្បវត្តិកា
ចិត្តចេតសិកា ធម្មា     រូបន្ទានិ បវុច្ចតិ ។

២. សមុទ្ទេសា វិភាគា ច     សមុដ្ឋានា កលាបតោ
បវត្តិក្កមតោ ចេតិ បញ្ចធា តត្ថ សង្គហោ ។

*ធម៌ទាំងឡាយ គឺ ចិត្តនិងចេតសិក ព្រមទាំងប្រភេទនិងបវត្តិ ខ្ញុំបានចែកហើយដោយលំដាប់នៃពាក្យ មានប្រមាណប៉ុណ្ណោះ ឥឡូវនេះ ខ្ញុំនឹងពោលរូបបរមត្ថតទៅ ។ ក្នុងរូបនោះ មានសង្គហៈ (ការរួបរួម) ដោយអាការ*

**៥ ន័យ គឺ ដោយសមុទ្ទេស ដោយវិភាគ ដោយសមុដ្ឋាន ដោយកលាប និងដោយបវត្តិក្កម ។**

## អធិប្បាយ សង្គហគាថា

បរិច្ឆេទទី ៦ នេះ ព្រះអនុរុទ្ធាចារ្យសម្តែងរូបបរមត្ថទុក ១៤ គាថា ក្នុងគាថាដំបូង ជាពាក្យអនុសន្ធិ ក៏ព្រោះធម៌ គឺ ចិត្ត និងចេតសិក លោកបានពោលទុកដោយពិស្តារហើយ ។ ឥឡូវនេះកាលនឹងសម្តែងរូប និងនិព្វាន ក្នុងលំដាប់នៃរូបនោះ ទើបពោលគាថាទី ២ សម្តែងរូបសង្គហៈ ដោយន័យទាំង ៥ នេះ គឺ ៖

**១- រូបសមុទ្ទេស** សំម្តែងរូបសង្ខេបដើម្បីឱ្យជ្រាបលក្ខណៈ

**២- រូបវិភាគ** សម្តែងរូបពិស្តារ ដោយចែកជាគូ ៗ

**៣- រូបសមុដ្ឋាន** សម្តែងហេតុកើតរូប ដោយសមុដ្ឋាន ៤

**៤- រូបកលាប** សម្តែងរូបជាកលាប មានចក្ខុកលាបជាដើម

**៥- រូបបវត្តិក្កម** សម្តែងលំដាប់ការប្រព្រឹត្តិទៅរបស់រូបដោយការផ្សេងគ្នានៃភព កាល និងសត្វ ដែល

កើតក្នុងភូមិផ្សេង ៗ ។

ម្យ៉ាងទៀត ក្នុងគាថាដំបូង ពាក្យថា **រូបទ្ទានិ** បែកបទចេញជា **រូប + ឥទានិ, រូប** ប្រែថា រូប ក៏**រូប**ស័ព្ទនេះ ដោយទូទៅមានន័យច្រើន ដើម្បីនឹងឱ្យអត្ថនៃរូបនេះជាក់ច្បាស់ ទើបពោលដល់រូប ៧ ន័យ តាមធាតុប្បទីបិកាពោលទុកថា ៖

## រូបមាន ៧ ន័យ

១- រូប សំដៅដល់ **រូបក្ខន្ធ** ដូចបាលីថា **យំ កិញ្ចិ រូបំ អតីតានាគតបច្ចុប្បន្នំ ។បេ។ អយំ វុច្ចតិ រូបក្ខន្ធោ** : រូបណាមួយ ជាអតីត អនាគត បច្ចុប្បន្ន ។ល។ នេះហៅថា រូបក្ខន្ធ ។[១]

២- រូប សំដៅដល់ **រូបភព** ដូចបាលីថា **រូបូបបត្តិយា មគ្គំ ភាវេតិ** : បុគ្គលចម្រើននូវមគ្គដើម្បីទៅកើតក្នុងរូបភព ។[២]

---

១. អភិ. វិភ. ខន្ធវិភង្គ. ៨០. ២/១ ។

២. អភិ. សង្គ. រូបាវចរកុសល. ៧៨. ១៩១/១៤០ ។

៣- រូប សំដៅដល់ **និមិត្តក្នុងកសិណ** ដូចបាលីថា ***អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ*** : មិនសំគាល់នូវរូបខាងក្នុង ឃើញនូវពួករូបខាងក្រៅ ។[១]

៤- រូប សំដៅដល់ **បច្ច័យ ឬ ហេតុ** ដូចបាលីថា ***សរូបា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា*** : ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមក រមែងកើតឡើង ព្រោះបច្ច័យរបស់ខ្លួន ។[២]

៥- រូប សំដៅដល់ **សរីរៈ** (រាងកាយ) ដូចបាលីថា ***អដ្ឋិញ្ច បដិច្ច ន្ហារុញ្ច បដិច្ច មំសញ្ច បដិច្ច ចម្មញ្ច បដិច្ច អាកាសោ បរិវារិតោ រូបន្ត្វេវ សំខ្យំ គច្ឆតិ*** : អាកាសដែលអាស្រ័យឆ្អឹងខ្លះ អាស្រ័យសរសៃខ្លះ អាស្រ័យសាច់ខ្លះ អាស្រ័យស្បែកខ្លះ រួបរួមជាមួយគ្នាហើយ ទើបហៅថា រូបកាយបាន

---

១. អភិ. សង្គ. រូបាវចរកុសល. ៧៨. ១៧៨/១០៩ ។

២ . អង្គុ. ឯក. រូបាទិអដ្ឋកថា ។

ដូច្នេះឯង ។[១]

៦- រូប សំដៅដល់ **វណ្ណៈ** (ពណ៌) ដូចបាលីថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ** ប្រែថា ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យចក្ខុប្រសាទ និងរូបារម្មណ៍ ។[២]

៧- រូប សំដៅដល់ **សណ្ឋាន** "ទ្រង់ទ្រាយ" ដូចបាលីថា **រូបប្បមាណោ រូបប្បសន្នោ** : បុគ្គលជ្រះថ្លាក្នុងរូប ឈ្មោះថា រូបប្បមាណ ។[៣]

ក្នុងគាថានេះ សំដៅយករូបន័យទី ១ ។

**រូប** មានវចនត្ថៈថា **រុប្បតីតិ = រូបំ** : ឈ្មោះថា រូប ព្រោះអត្ថថា បែកធ្លាយ គឺ រមែងបែកធ្លាយ ដោយបច្ច័យដែលជាសត្រូវមានត្រជាក់ និងក្តៅជាដើម ។

---

១ . មជ្ឈិ. មូល. មហាហត្ថិបទោបមសូត្រ. ២១. ៨៤/២១១ ។

២. មជ្ឈិ. មូល. មធុបិណ្ឌិកសូត្រ. ២០. ២៤៨/៤១៧ ។

៣. អង្គុ. ចតុ. បត្តកម្មវគ្គ. ៤២. ៦៦/១៧៥ ។

ក្នុងវិភាវិនីដីកា លោកបានអធិប្បាយទុកថា ៖

**សីតុណ្ហាទិវិរោធិប្បច្ចយេហិ រុប្បតីតិ = រូបំ** : ធម្មជាតណា រមែងបែកធ្លាយ (វិនាសទៅ)ដោយបច្ច័យដែលជាសត្រូវ មានត្រជាក់ជាដើម ព្រោះដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា រូប ។

ព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយរបស់ណាវិនាស របស់នោះហៅថា រូប ។ ចុះវិនាសដោយអ្វី ។ វិនាសដោយត្រជាក់ក៏មាន វិនាសដោយក្តៅក៏មាន វិនាសដោយគំលានក៏មាន វិនាសដោយសម្រេកក៏មាន វិនាសដោយសម្ផ័ស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូចពស់ធំក៏មាន"[១] ។

សួរថា បើដូច្នោះ សូម្បីអរូបធម៌ គឺ ធម៌ដែលជានាម ក៏ហៅថា រូបបានឬ ?

ឆ្លើយថា មិនបានទេ ព្រោះលោកសំដៅយកការប្រែប្រួល

---

១. សំយុ. ខន្ធ. ខជ្ជនីយវគ្គ. ៣៣. ១៥៩/២០២ ។

ដែលប្រាកដច្បាស់ ដោយបច្ច័យដែលជាសត្រូវ មានត្រជាក់ជាដើម ។

តើប្រាកដច្បាស់ដូចម្ដេច ?

<u>ក្នុងសម្មោហវិនោទនី អដ្ឋកថាវិភង្គ</u> ពោលទុកថា ៖

រូបរមែងបែកធ្លាយ គឺ រមែងសាបសូន្យទៅ ព្រោះត្រជាក់នោះ ដូចក្នុងលោកន្តរនរក, នរកមួយរណ្ដៅ ៗ ប្រមាណ ៨.០០០ យោជន៍ ក្នុងចន្លោះចក្រវាឡទាំង ៣ ខាងក្រោមមិនមានផែនដី ខាងលើមិនមានព្រះចន្ទ ព្រះអាទិត្យ មិនមានពន្លឺអ្វីបន្តិចបន្តួចឡើយ ងងឹតជានិច្ច ឈ្មោះថា លោកន្តរនរក, អត្តភាពរបស់សត្វដែលកើតក្នុងទីនោះ មានប្រមាណ ៣ គាវុត សត្វទាំងនោះ មានក្រចក-វែងក្រាស់ ៗ តោងប្ដក់ជើងភ្នំចក្រវាឡខាងក្រោម សំយុងក្បាលចុះ ដូចសត្វជ្រើង ឬប្រចៀវ កាលណា វារំកិលទៅប៉ះគ្នា ពួកវាក៏សំគាល់ថា បានអាហារហើយ ក៏វល់វាយក្នុងអាហារនោះ ដេញតាមគ្នាទៅប្រកិត ៗ

ហើយក៏ធ្លាក់ចុះទៅក្នុងទឹកទ្រផែនដីទៅ កាលខ្លះត្រូវខ្យល់ត្រជាក់បក់មក ពួកវាភ័យខ្លាច ក៏របូតដាច់ធ្លាក់ចុះក្នុងទឹកទៅ ពេលធ្លាក់ទៅដល់ទឹកនោះ ពួកវាត្រូវទឹកដ៏ត្រជាក់ កាត់ទម្លាយជាដុំ ៗ ដូចដុំម្សៅដែលគេដាក់ក្នុងខ្លាញ់ក្ដៅ, ការវិនាសទៅនៃរូបក្នុងលោកន្តរនរកដោយត្រជាក់យ៉ាងនេះ សូម្បីក្នុងប្រទេសដែលត្រជាក់ខ្លាំងព្រោះទឹកកក និងព្រិលធ្លាក់ មានដែនឈ្មោះមហិសកៈជាដើម ក៏ដូចគ្នា ព្រោះសត្វទាំងឡាយ ក្នុងប្រទេសនោះ មានរាងកាយត្រូវត្រជាក់ធ្វើឱ្យវិនាស ដរាបដល់អស់ជីវិត ក៏មាន ។

រូបដែលវិនាសទៅ ព្រោះក្ដៅ ដូចសត្វកើតក្នុងអវិចីមហានរក ។

រូបដែលវិនាសទៅ ព្រោះស្រេកទឹក ដូចប្រេត ឈ្មោះកាលកញ្ជិកាសូរ មិនអាចបានតំណក់ទឹក ត្រឹមតែញ៉ាំងបំពង់កឱ្យសើម អស់រយៈកាល ២-៣ ពុទ្ធន្តរ សូម្បីពួកខ្លះទៅដល់ទន្លេដោយគិតថា នឹងផឹកទឹក ទឹកនោះក៏ស្ងួតហួតហែង នៅសល់សុទ្ធ

តែខ្សាច់ ។

រូបដែលវិនាសទៅ ព្រោះឃ្លាន ដូចពួកប្រេតដែលត្រូវសេចក្តីឃ្លានគ្របសង្កត់ មិនបានអាហារអ្វីបរិភោគឡើយ រហូតអស់រយៈកាល ២-៣ ពុទ្ធន្តរ ខាងក្នុងផ្ទៃពោះ ដូចដើមឈើមានប្រហោងខាងក្នុងត្រូវភ្លើងឆេះ, ឬក្នុងពេលកើតទុព្ភិក្ខភ័យ សត្វទាំងឡាយក៏ដល់នូវសេចក្តីស្លាប់យ៉ាងច្រើន ព្រោះឃ្លាន ។

រូបដែលវិនាសទៅ ព្រោះសម្លស្សរបោមមូស រមែងប្រាកដក្នុងទីដែលមានសម្លស្សរបោមមូសនោះច្រើន ។

រូបដែលវិនាសទៅ ព្រោះខ្យល់ ដូចខ្យល់ដែលទម្លាយដៃជើង ខ្នងជាដើម ធ្វើឱ្យជាមនុស្សខ្វិន ខ្វាក់ភ្នែក ពិការអវយវៈនិងគមជាដើម ។

រូបដែលវិនាសទៅ ព្រោះកំដៅនោះ រមែងប្រាកដក្នុងផ្លូវកន្តារ មានវាលខ្សាច់ជាដើម មានរឿងពោលទុកថា មានស្ត្រីម្នាក់ បានបែកគ្នាអំពីពួកឈ្នួញរទេះទៅក្នុងវេលារាត្រី ព្រោះតែខ្លួនយឺតយូរពេក នាកណ្តាលវាលខ្សាច់ធំល្វឹងល្វើយ កាលព្រះ

អាទិត្យគោចរទៅដល់ថ្ងៃត្រង់ ក៏មិនអាចដាក់ជើងលើខ្សាច់ដ៏ក្តៅបាន ទើបដាក់កញ្ជើចុះពីក្បាលមកជាន់, កាលមិនអាចជាន់លើកញ្ជើបាន ព្រោះក្តៅខ្លាំង ក៏ដាក់សាដកពីលើហើយជាន់ទៀត សូម្បីសាដកក៏នៅតែក្តៅ ទើបចាប់កូនដែលពរមកជាមួយឱ្យដេកផ្កាប់ហើយជាន់ មិនយូរប៉ុន្មាន ម្តាយនិងកូនក៏ស្លាប់ទាំងពីរនាក់ក្នុងទីនោះឯង ។

រូបដែលវិនាសទៅ ព្រោះត្រូវសត្វលូននិងសត្វវារតូច-ធំចិកឬខាំ រូបនោះ ក៏វិនាសទៅ ព្រោះអាសិរពិសផ្សេង ៗ ចិកឬខាំនុ៎ះឯង ។

សួរថា បើរូបវិនាសទៅ ដោយបច្ច័យខាងលើនេះមែន ចុះក្នុងព្រហ្មលោក ដែលមិនមានទូវបច្ច័យទាំងនេះបៀតបៀនសោះ តើហេតុដូចម្តេច បានជាភូមិនោះ ហៅថា រូបព្រហ្ម "ព្រហ្មមានរូប"បាន ?

ឆ្លើយថា សូម្បីបច្ច័យដែលជាសត្រូវមិនប្រាកដ ព្រោះមានតែបច្ច័យដែលជួយឧបត្ថម្ភ, ក៏ការប្រែប្រួលវិនាសនៃរូបក្នុង

ព្រហ្មលោកនោះ នៅតែមានដដែល គឺ ព្រោះបច្ច័យដែលជួយឧបត្ថម្ភនោះឯងអស់ ដូច្នោះ ការបញ្ញត្តិថា រូបក្នុងព្រហ្មលោកនោះ ក៏មិនកន្លងនូវការប្រែប្រួល វិនាសទៅឡើយ ។

## លក្ខណាទិចតុក្កៈរបស់រូប

**១-រុប្បនលក្ខណំ** រូបមានការបែកធ្លាយ ជាលក្ខណៈ

**២-វិកិរណរសំ** មានការខ្ចាត់ខ្ចាយ ជាកិច្ច

**៣-អព្យាកតបច្ចុប្បដ្ឋានំ** មានភាពជាអព្យាកត ជាផល

**៤-វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណ ជាបទដ្ឋាន

<u>ក្នុងបរមត្ថទីបនី</u> ពោលថា ៖

១-រូបមានការបែកធ្លាយ ជាលក្ខណៈ

២-មានការមិនដឹងអារម្មណ៍ ជាកិច្ច

៣-មានការៈជាសម្បយោគ ជាផល

៤-មានវិញ្ញាណ ជាបទដ្ឋាន ។

# រូបន័យទី ១ រូបសមុទ្ទេស

## សង្គហគាថា

៣. ភូតប្បសាទវិសយា ភាវោ ហទយមិច្ចបិ
ជីវិតាហាររូបេហិ អដ្ឋារសវិធំ តថា ។

៤. បរិច្ឆេទោ ច វិញ្ញត្តិ វិការោ លក្ខណន្តិ ច
អនិប្ផន្នា ទស ចេតិ អដ្ឋវីសវិធំ ភវេ ។

*រូប ២៨ គឺ មហាភូតរូប៤ ប្រសាទរូប៥ វិសយរូប៤ ភាវរូប២ ហទយរូប១ ជីវិតរូប១ អាហាររូប១ រួមជានិប្ផន្នរូប១៨ ។ អនិប្ផន្នរូប១០ គឺ បរិច្ឆេទរូប១ វិញ្ញត្តិរូប២ វិការរូប៣ និងលក្ខណរូប៤ ។*

រូបទាំងអស់ ២៨ កាលចែកដោយប្រភេទធំបាន ២ គឺ មហាភូតរូប ៤ និងឧបាទាយរូប ២៤ តែកាលចែកដោយប្រភេទតូច ៗហើយ បានរូប ១១ ពួក ដូចតទៅនេះ គឺ ៖

១-មហាភូតរូប ៤ បានដល់ បឋវី អាបោ តេជោ វាយោ

២-ប្រសាទរូប ៥ បានដល់ ចក្ខុ-សោត-ឃាន-ជិវ្ហា-កាយប្រសាទ

៣-វិសយរូប ៤ បានដល់ វណ្ណៈ សទ្ទៈ គន្ធៈ រសៈ

៤-ភាវរូប ២ បានដល់ ឥត្ថីភាវៈ បុរិសភាវៈ

៥-ហទយរូប ១ បានដល់ ហទយវត្ថុ

៦-ជីវិតរូប ១ បានដល់ ជីវិតិន្ទ្រិយ

៧-អាហាររូប ១ បានដល់ កពឡិង្ការាហារ

៨-បរិច្ឆេទរូប ១ បានដល់ អាកាសធាតុ

៩-វិញ្ញត្តិរូប ២ បានដល់ កាយវិញ្ញត្តិ វចីវិញ្ញត្តិ

១០-វិការរូប ៣ បានដល់ លហុតា មុទុតា កម្មញ្ញតា

១១-លក្ខណរូប ៤ បានដល់ ឧបចយៈ សន្តតិ ជរតា អនិច្ចតា ។

បណ្ដារូប ២៨ នេះ ក្នុងបាលីចែកទុកជា ២ ពួក គឺ សភាវរូប ១ និង អសភាវរូប ១ ។

**សភាវរូប** បានដល់ មហាភូតរូប៤ ប្រសាទរូប៥ វិសយរូប៤ ភាវរូប២ ហទយរូប១ ជីវិតរូប១ អាហាររូប១ ។

រូប ១៨ នេះ មានឈ្មោះហៅបាន ៥ យ៉ាង គឺ ៖

**១- សភាវរូប** រូបដែលមានភាវៈរបស់ខ្លួន

**២- សលក្ខណរូប** រូបដែលមានលក្ខណៈ

**៣- និប្ផន្នរូប** រូបដែលកើតអំពីសមុដ្ឋាន ៤

**៤- រូបរូប** រូបដែលបែកធ្លាយ

**៥- សម្មសនរូប** រូបដែលគួរពិចារណា

រូប ដែលឈ្មោះថា **សភាវៈ** ព្រោះមានភាវៈរបស់ខ្លួន ដោយចំពោះមិនលាយគ្នា មានភាពរឹងជាដើម ។

ដែលឈ្មោះថា **សលក្ខណៈ** ព្រោះប្រកបដោយលក្ខណៈ មានការកើតជាដើម ឬមានការមិនទៀងជាដើម ។

ដែលឈ្មោះថា **និប្ផន្ន** ព្រោះសម្រេចហើយ ដោយសមុដ្ឋាន ៤ មានកម្មជាដើម ។

សភាវៈដែលប្រែប្រួល ឬបែកធ្លាយ ព្រោះបច្ច័យ ឈ្មោះថា **រូប.** និងរូបនេះឯង មានការប្រែប្រួល បែកធ្លាយទៅ ជា

ធម្មតា ដូច្នេះ ទើបលោកថែមពាក្យថា **រូប** មកមួយស័ព្ទទៀត គឺ **រូបរូប** ប្រែថា រូបដែលបែកធ្លាយ ដោយការសំដៅដែលយើងធ្លាប់ហៅមក ដូចពាក្យថា ទុក្ខទុក្ខ ។

ដែលឈ្មោះថា **សម្មសន** ព្រោះជារូបដែលគួរដល់ការពិចារណា ដោយអនិច្ចលក្ខណៈជាដើម ។

ចំណែករូប ១០ ទៀតដែលនៅសល់ គឺ

បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ និងលក្ខណរូប ៤ ទាំងនេះ ក៏មានឈ្មោះហៅបាន ៥ យ៉ាង ដូចគ្នា គឺ អសភាវរូប ១ អសលក្ខណរូប ១ អនិប្ផន្នរូប ១ អរូបរូប ១ និងអសម្មសនរូប ១ ។

## រូប ១១ ពួក

### ពួកទី ១ : មហាភូតរូប ៤

មហាភូតរូប សំដៅដល់ រូបដែលជាធំ បានដល់ បឋវី អាបោ តេជោ វាយោ ។ មហាភូតរូបនេះ មាន ៤ ប៉ុណ្ណោះ ទើបលោកហៅថា **មហាភូតរូប ៤** ។

**ក្នុងវិភាវិនីដីកា** ពោលថា ធម៌ទាំងឡាយ មានបឋវីជាដើម ឈ្មោះថា **មហាភូត** ព្រោះអត្ថថា កើត គឺ ប្រាកដជាសភាពធំ ក្នុងសន្តានដែលមានចិត្តគ្រប់គ្រង និងមិនមានចិត្តគ្រប់គ្រង ដោយអំណាចនៃធាតុ ព្រមទាំងសម្ភារៈ ។

**ក្នុងអដ្ឋកថា ធម្មសង្គណី** ពោលថា ៖

ដែលឈ្មោះថា មហាភូត ព្រោះហេតុ ៥ គឺ

១-ព្រោះប្រាកដជារបស់ធំ ២-ព្រោះដូចជាអ្នកលេងកលល្បិច

៣-ព្រោះត្រូវបរិហារ ( រក្សា ) ច្រើន ៤-ព្រោះវិការៈធំ

៥-ព្រោះជារបស់ធំដែលមានពិត

## ភូតៈមាន ៧ ន័យ

**១-ភូត** សំដៅដល់ **ភាវៈដែលមាននៅពិត** ដូចបាលីថា :

**យោ បន ភិក្ខុ ។បេ។ ភូតស្មឹ បាចិត្តិយំ :** ភិក្ខុណាមួយប្រាប់ឧត្តរិមនុស្សធម៌ដល់អនុបសម្បន្ន ត្រូវអាបត្តិបាចិត្តិយ ព្រោះភិក្ខុនោះ បានពិតមែន ។[១]

**២-ភូត** សំដៅដល់ **ខន្ធ ៥** ដូចបាលីថា : **ភូតមិទំ ភិក្ខវេ បស្សថ :** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញនូវខន្ធបញ្ចកៈនេះដែលកើតឡើងហើយឬទេ ។[២]

**៣-ភូត** សំដៅដល់ **រូប** ដូចបាលីថា : **ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ :** ម្នាលភិក្ខុមហាភូតរូបទាំង ៤ ជាហេតុ មហាភូតរូបទាំង ៤ ជាបច្ច័យដែលនាំឱ្យបញ្ញត្តនូវរូបក្ខន្ធ ។[៣]

---

១ . វិន. បាចិ. មុសាវាទវគ្គ. ៣. ៣០៥/៣១៧ ។

២. មជ្ឈិ. មូល. មហាតណ្ហាសង្ខយសូត្រ. ២២. ៨៥/១៦០ ។

៣. មជ្ឈិ. ឧប. មហាបុណ្ណមសូត្រ. ២៦. ១២៤/១៩៣ ។

៤-ភូត សំដៅដល់ **ព្រះខីណាស្រព** ដូចបាលីថា : **យោ ច កាលឃសោ ភូតោ ស ភូតបចនឹ បចិ** : ចំណែកសត្វណាជាអ្នកស៊ីនូវកាល សត្វនោះ ឈ្មោះថា ដុតនូវតណ្ហាដែលជាធម្មជាតិដុតសត្វ ។[១]

៥-ភូត សំដៅដល់ **សព្វសត្វ** ដូចបាលីថា : **សព្វេវ និក្ខិបិស្សន្តិ ភូតា លោកេ សមុស្សយំ** : ពួកសត្វទាំងអស់ មុខជានឹងដាក់ចុះនូវរាងកាយ ក្នុងលោក ។[២]

៦-ភូត សំដៅដល់ **ដើមឈើ** ដូចបាលីថា : **ភូតគាមបាតព្យតាយ បាចិត្តិយំ** : ភិក្ខុធ្វើភូតគាម មានឈើនិងស្មៅជាដើមឱ្យវិនាស ត្រូវអាបត្តិបាចិត្តិយ ។[៣]

---

១. ខុទ្ទ. ជាត. សិគាលវគ្គ. ៥៨. ៣៤០/១៣៣ ។

២. ទីឃ. មហា. ១៦. ១៤៦/៣២៦ ; សំយុ. សគា. បរិនិព្វានសូត្រ. ៣០. ១០១/៨០ ។

៣. វិន. បាចិ. ភូតគាមវគ្គ. ៣. ៣៥៤/៣៤៩ ។

*៧-**ភូត** សំដៅដល់ **អមនុស្ស** ដូចបាលីថា : **ភូតេ ភូតតោ សញ្ញានាតិ** : សំគាល់នូវពួកសត្វថា ជាសត្វពិត ។*[១]

## ១- បឋវីធាតុ

***បឋវីធាតុ** មាន ២ លក្ខណៈ គឺ ៖*

*១-**កក្ខឡ បឋវី** បឋវីដែលមានភាពរឹង ជាលក្ខណៈ*

*២-**អថទ្ធ បឋវី** បឋវីដែលមានភាពមិនរឹង ជាលក្ខណៈ*

***បឋវី** មានវចនត្ថៈថា **បត្ថីនត្ថេន = បឋវី** ឈ្មោះថា **បឋវី** ព្រោះអត្ថថា រឹង ។*

*ន័យមួយទៀត **សហជាតរូបានិ បឋន្តិ បតិដ្ឋហន្តិ ឯត្ថាតិ = បឋវី** ប្រែថា សហជាតរូបទាំងឡាយ រមែងអាស្រ័យ តាំងនៅក្នុងធាតុនេះ ព្រោះហេតុនោះ ធាតុនេះ ទើបឈ្មោះថា **បឋវី** ។*

---

១. មជ្ឈិ. មូល. មូលបរិយាយសូត្រ. ២០. ២/៤ ។

ពិតមែន បឋវីរមែងប្រាកដ ដោយភាពជាទីអាស្រ័យរបស់រូបដែលកើតរួមគ្នា ដូចដីប្រក្រតី ជាទីអាស្រ័យរបស់ដើមឈើជាដើម ។ ធាតុគឺ បឋវី ឈ្មោះថា បឋវីធាតុ ។ ដែលឈ្មោះថាធាតុ ព្រោះអត្ថថា ទ្រទ្រង់នូវលក្ខណៈ របស់ខ្លួនជាដើម ព្រោះអត្ថថា មិនមែនសត្វ មិនមែនជីវៈ និងដែលដូចគ្នា ដោយ ធាតុដែលជាចំណែកប្រកបនៃសរីរៈ និង ភ្នំ ។ កាលប្រៀបធៀបជាមួយធាតុដទៃ ៗ បឋវីធាតុនេះ មានលក្ខណៈរឹងជាង គឺ ក្នុងវត្ថុណា បើមានបឋវីច្រើន វត្ថុនោះ ក៏រឹងច្រើន ដូចក្នុងស្លឹកឈើ ឥដ្ឋ ថ្ម ដី ក្រួសជាដើម តែបើវត្ថុណា មានបឋវីតិច វត្ថុនោះក៏មានភាពរឹងតិច ដូចក្នុងសំឡី ជ័រ និងពពុះទឹកជាដើម ។

## លក្ខណាទិចតុក្កៈរបស់បឋវី

**១- កក្ខឡត្តលក្ខណា** មានភាពរឹង ជាលក្ខណៈ

**២- បតិដ្ឋានរសា** មានការតាំងនៅមាំ ជាកិច្ច

**៣- សម្បដិច្ឆន្នបច្ចុប្បដ្ឋានា** មានភាពជាទីទទួលរង ជាផល

៤- **អវិសេសធាតុត្ថយបទដ្ឋានា** មានធាតុ ៣ ដែលនៅសល់ជាហេតុជិត ។

## បឋវីធាតុមាន ៤ យ៉ាង

**១-បរមត្ថបឋវី** ឬ **លក្ខណបឋវី** បានដល់ ធាតុដីដែលមានភាពរឹង ឬទន់ជាសភាវៈ

**២-សសម្ភារបឋវី** ឬ**សុត្តន្តបឋវី** បានដល់ ធាតុដីដែលមានចំណែកប្រកប មានទាំងខាងក្នុងកាយ និងខាងក្រៅកាយ ។

ដែលមានខាងក្នុងកាយរបស់សត្វ ជាឧបាទិន្នរូប ហៅថា **អជ្ឈត្តិកបឋវី** ។

ដែលមានខាងក្រៅកាយរបស់សត្វ ជាអនុបាទិន្នរូប ហៅថា **ពាហិរបឋវី** ។

ក្នុងធាតុវិភង្គ ចែក **អជ្ឈត្តិកបឋវី** នេះទុក ១៩ យ៉ាង តែក្នុងអដ្ឋកថាបន្ថែម **មត្ថលុង្គំ** ចូលផង ទើបរួមជាធាតុដីខាងក្នុង

២០ ដោយចាត់ជា ៤ ពួក គឺ

| ពួកតចបញ្ចកៈ | ពួកវក្កបញ្ចកៈ |
| --- | --- |
| ១- កេសា សក់ | ៦- មំសំ សាច់ |
| ២- លោមា រោម | ៧-នហារូ សរសៃ |
| ៣- នខា ក្រចក | ៨- អដ្ឋិ ឆ្អឹង |
| ៤- ទន្តា ធ្មេញ | ៩- អដ្ឋិមិញ្ជំ ខួរក្នុងឆ្អឹង |
| ៥- តចោ ស្បែក | ១០- វក្កំ តម្រងបស្សាវៈ |

| ពួកបប្ផាសបញ្ចកៈ | ពួកមត្ថលុង្គបញ្ចកៈ |
| --- | --- |
| ១១- ហទយំ បេះដូង | ១៦-អន្តំ ពោះវៀនធំ |
| ១២- យកនំ ថ្លើម | ១៧-អន្តគុណំ ពោះវៀនតូច |
| ១៣- កិលោមកំ វាវ | ១៨-ឧទរិយំ អាហារថ្មី |
| ១៤- បិហកំ ក្រពះ | ១៩-ករីសំ អាហារចាស់ |
| ១៥- បប្ផាសំ សួត | ២០-មត្ថលុង្គំ ខួរក្នុងក្បាល |

ពាហិរបឋវី គឺ ធាតុដីខាងក្រៅ បានដល់ ធម្មជាតិដែលរឹង

ជាអនុបាទិន្នរូប ក្នុងធាតុវិភង្គមានពាក្យថា "**អយោ** ដែក, **លោហំ** លោហៈ, **តិបុ** សំណប៉ាហាំង, **សីសំ** សំណភក់, **សជ្ឈុ** ប្រាក់, **មុត្តា** កែវមុក្តា, **មណិ** កែវមណី", ជាដើម ។

**៣-កសិណបឋវី ឬ អារម្មណបឋវី** បានដល់ បឋវីកសិណ ឬដីដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន ។

**៤-សម្មតិបឋវី ឬ បកតិបឋវី** បានដល់ ធាតុដីដែលសន្មត ហៅថា ដី ដុំដី ទីដី ផ្ទៃដី ផែនដី ។

## ២- អាបោធាតុ

អាបោធាតុ ធាតុទឹក មាន ២ លក្ខណៈ គឺ ៖

**១-បគ្ឃរណអាបោ** ធាតុទឹកដែលមានលក្ខណៈហូរជ្រាប

**២-អាពន្ធនអាបោ** ធាតុទឹកដែលមានលក្ខណៈជាប់ស្អិត

វត្ថុណា មានអាបោធាតុច្រើន វត្ថុនោះ ក៏រាវទិឹងហូរទៅ, បើមានអាបោធាតុតិច ក៏ធ្វើឱ្យវត្ថុនោះ ជាប់ស្អិតគ្នាជាដុំ គឺ ជាប់ស្អិត បរមាណូនៃបឋវីធាតុ ឱ្យជាដុំជាប់គ្នា ជារូបរាង

សណ្ឋានផ្សេង ៗ ដូចជាផែនដី ភ្នំ ដើមត្នោត ទំពាំង ភ្លុកដំរីជាដើម, បើក្នុងវត្ថុណា មានអាបោធាតុច្រើនជាងបឋវីធាតុ ក៏ធ្វើឱ្យបឋវីធាតុមានភាពរឹងតិច និងធ្វើឱ្យបឋវីធាតុ ដែលកើតរួមគ្នានោះហូរទៅ ដូចទឹកក្នុងទន្លេ ស្ទឹងជាដើម ។

ម្យ៉ាងទៀត អាបោធាតុ ដែលត្រូវតេជោធាតុ ដុតពេលធ្វើឱ្យក្ដៅ រហូតដល់អាចហូរទៅបាន ដូចជាដែក មាស ប្រាក់ និង ក្រមួនឃ្មុំជាដើម ប្រព្រឹត្តទៅដោយអំណាចនៃតេជោ ធ្វើឱ្យហូរ, អាបោធាតុ ដែលមានលក្ខណៈជាប់ស្អិតនោះ ព្រោះមានតេជោធាតុ ផ្សំនៅតិច ។

**អាបោ** មានវចនត្ថៈថា **អាបេតិ សហជាតរូបានិ បត្ថរតិ អប្បាយតិ វា ព្រូហេតិ វឌ្ឍេតីតិ = អាបោ** : ដែលឈ្មោះថា **អាបោ** ដោយអត្ថថា ជ្រួតជ្រាប គឺ ផ្សើមទៅកាន់រូប ដែលកើតរួមគ្នា ។ ម្យ៉ាងទៀត ឈ្មោះថា **អាបោ** ដោយអត្ថថា ធ្វើឱ្យសហជាតរូបជិតស្និទ្ធ កពូន ឬចម្រើន ដុះដាល ធាត់ធំ ។

ន័យមួយទៀត **សហជាតរូបានិ អវិប្បកិណ្ណានិ កត្វា ភុសោ បាតិ រក្ខតីតិ = អាបោ** : ធាតុ រមែងឃុំគ្រងរក្សាយ៉ាងក្រៃលែងនូវសហជាតរូបទាំងឡាយ មិនឱ្យខ្ចាត់ខ្ចាយ ព្រោះហេតុនោះ ធាតុនោះ ទើបឈ្មោះថា **អាបោ** ។

## លក្ខណាទិចតុក្កៈរបស់អាបោ

**១-បគ្ឃរណលក្ខណា** មានការហូរ សើមជ្រាប ជាលក្ខណៈ

**អាពន្ធនលក្ខណា** វា ឬ មានការជាប់ស្អិត ជាលក្ខណៈ

**២-ឧបព្យូហនរសា** មានការបូលទៅកពូន ជាកិច្ច

**៣-សង្គហបច្ចុប្បដ្ឋានា** មានការគោងរួមផ្ដុំទុក ជាផល

**៤-អវសេសធាតុត្តយបទដ្ឋានា** មានធាតុ ៣ ដែលនៅសល់ ជាហេតុជិត ។

## អាបោធាតុមាន ៤ យ៉ាង

**១-បរមត្ថអាបោ ឬ លក្ខណអាបោ** បានដល់ ធាតុទឹកដែលជាបរមត្ថ

**២-សសម្ភារអាបោ ឬ សុត្តន្តអាបោ** បានដល់ ធាតុទឹក ព្រមទាំងគ្រឿងប្រកប ។

<u>អាបោធាតុ</u> ដែលមានក្នុងរាងកាយ ហៅថា **អជ្ឈត្តិកអាបោ** ដែលមានខាងក្រៅរាងកាយ ហៅថា **ពាហិរអាបោ** ។

**អជ្ឈត្តិកអាបោ** ជាឧបាទិន្នរូប មានក្នុងកាយរបស់សត្វ <u>ក្នុងធាតុវិភង្គ</u> ចែកទុក ១២យ៉ាង ដោយចែកជា ២ពួក គឺ

| ពួកមេទឆក្កៈ | | ពួកមុត្តឆក្កៈ | |
|---|---|---|---|
| **១-បិត្តំ** | ទឹកប្រមាត់ | **៧-អស្សុ** | ទឹកភ្នែក |
| **២-សេម្ហំ** | ស្លេស្ម៍ | **៨-វសា** | ខ្លាញ់រាវ |
| **៣-បុព្វោ** | ទឹកខ្ទុះ | **៩-ខេឡោ** | ទឹកមាត់ |
| **៤-លោហិតំ** | ឈាម | **១០-សិង្ឃានិកា** | ទឹកសម្បោរ |
| **៥-សេទោ** | ញើស | **១១-លសិកា** | ទឹករំអិល |
| **៦-មេទោ** | ខ្លាញ់ខាប់ | **១២-មុត្តំ** | ទឹកមូត្រ ។ |

**ពាហិរអាបោ** បានដល់ ធាតុទឹកខាងក្រៅ ជាអនុបាទិន្នរូប

<u>**ក្នុងធាតុវិភង្គ**</u> សម្ដែងទុកច្រើន មានពាក្យថា ៖

**មូលរសោ** រសគល់ **ខន្ធរសោ** រសដើម **តចរសោ** រសសំបក **បត្តរសោ** រសស្លឹក **បុប្ផរសោ** រសផ្កា **ផលរសោ** រសផ្លែ ជាដើម ។

**៣-កសិណអាបោ** ឬ **អារម្មណអាបោ** បានដល់ អាបោកសិណ ឬ ទឹកដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន មានទឹកក្នុងបាត្រ ក្នុងអាង ក្នុងផ្តិលជាដើម ។

**៤-សម្មតិអាបោ** ឬ **បកតិអាបោ** បានដល់ ធាតុទឹកដែលសន្មតគ្នាថា ទឹកផឹក ទឹកងូតជាដើម ។

## ៣- តេជោធាតុ

តេជោធាតុ បានដល់ ធាតុភ្លើង មាន ២ លក្ខណៈ គឺ ៖

**១-ឧណ្ហតេជោ** បានដល់ ភ្លើង គឺ ចំហាយដែលក្តៅ

**២-សីតតេជោ** បានដល់ ភ្លើង គឺ ចំហាយដែលត្រជាក់

**តេជោ** មានវចនត្ថៈថា **តេជេតិ បរិបាចេតីតិ = តេជោ :** ធាតុ ដែលឈ្មោះថា តេជោ ព្រោះអត្ថថា ធ្វើឱ្យក្តៅ ឱ្យឆ្អិន គឺ ធ្វើភូតរូប ៣ ដែលនៅសល់ឱ្យក្តៅ ឬត្រជាក់ ដោយភាវៈរបស់ខ្លួន ។

<u>វិសុទ្ធិមគ្គ</u> សម្តែងវចនត្ថៈថា **យោ បរិបាចនភាវោ វា ឧណ្ហភាវោ វា អយំ = តេជោធាតុ :** ភាវៈ គឺ ការទុំជោរក្តី ភាវៈ គឺ ភាពក្តៅក្តី យ៉ាងណា នេះ ហៅថា តេជោធាតុ ។

### លក្ខណាទិចតុក្កៈរបស់តេជោ

| | |
|---|---|
| **១-ឧណ្ហត្តលក្ខណា** | មានភាពក្តៅ ជាលក្ខណៈ |
| **២-បរិបាចនរសា** | មានការដុតរោល ជាកិច្ច |

**៣-មទ្ទវានុប្បទានបច្ចុប្បដ្ឋានា** មានការបន្ថែមភាពទន់ ជាផល
**៤-អវសេសធាតុត្តយបទដ្ឋានា** មានធាតុ ៣ ដែលនៅសល់ ជាហេតុជិត ។

## តេជោធាតុមាន ៤ យ៉ាង

**១-បរមត្ថតេជោ** ឬ **លក្ខណតេជោ** បានដល់ ធាតុភ្លើងដែលជាបរមត្ថ ។
**២-សសម្ភារតេជោ** ឬ **សុត្តន្តតេជោ** បានដល់ ធាតុភ្លើងព្រមទាំងចំណែកប្រកប

ដែលជាខាងក្នុង ហៅថា **អជ្ឈត្តិកតេជោ** ជាឧបាទិន្នរូប,
ដែលជាខាងក្រៅ ហៅថា **ពាហិរតេជោ** ជាអនុបាទិន្នរូប ។

<u>ក្នុងធាតុវិភង្គ</u> សម្ដែងអជ្ឈត្តិកតេជោ ទុក៤យ៉ាង គឺ ៖

**១-ឧស្មាតេជោ** ភ្លើងដែលធ្វើឱ្យរាងកាយក្ដៅ
**២-បាចកតេជោ** ភ្លើងរំលាយអាហារ
**៣-ជីរណតេជោ** ភ្លើងដែលធ្វើឱ្យទ្រុឌទ្រោម មានធ្មេញបាក់ជាដើម

**៤-សន្តាបនតេជោ** ភ្លើងដែលធ្វើឱ្យក្តៅ រហូតដល់មានជម្ងឺ

<u>ក្នុងធាតុវិភង្គ</u> សម្តែង **ពាហិរតេជោ** នោះ ទុកថា : **កដ្ឋគ្គិ** ភ្លើងឧស **សកលិកគ្គិ** ភ្លើងកំកាច់(កម្ទេចឈើ) **តិណគ្គិ** ភ្លើងស្មៅ **គោមយគ្គិ** ភ្លើងអាចម៍គោ **ថុសគ្គិ** ភ្លើងអង្កាមឬចំបើង **សង្ការគ្គិ** ភ្លើងសំរាមជាដើម ។

**៣-កសិណតេជោ** ឬ**អារម្មណតេជោ** បានដល់ តេជោកសិណ ឬ ភ្លើងដែលជាអារម្មណ៍របស់សមថៈ ។

**៤-សម្មុតិតេជោ** ឬ**បកតិតេជោ** បានដល់ ភ្លើងដែលសន្មតដូចភ្លើងអគ្គិសនី ភ្លើងចង្កៀងជាដើម ។

## ៤-វាយោធាតុ

**វាយោធាតុ** បានដល់ ធាតុខ្យល់ មាន២លក្ខណៈ គឺ ៖

**១- វិត្ថម្ភនវាយោ** ខ្យល់ដែលធ្វើឱ្យតឹង

**២- សមុទីរណវាយោ** ឬ **សមីរណវាយោ** ខ្យល់ដែល

ធ្វើឱ្យកម្រើក

**វិត្ថម្ភនវាយោ** គឺ ធាតុខ្យល់ ដែលធ្វើឱ្យតឹងនោះ ជាធាតុខ្យល់ ដែលធ្វើឱ្យរូបកើតព្រមជាមួយខ្លួន តាំងមាំ មិនកម្រើកខាងក្នុងរាងកាយរបស់សត្វ ដូចខណៈប្រឹងដៃជើង ឬមិនប៉ប្រិចភ្នែកជាដើម, ចំណែកធាតុខ្យល់ដែលមានខាងក្រៅសត្វ ដូចខ្យល់ក្នុងពោះវៀនកង់រថយន្ត សប់ខ្យល់ចូលទៅហើយ ឬខ្យល់ក្នុងបាល់ ដែលសប់ហើយជាដើម ។

ក្នុងសេចក្តីនេះ មានវចនត្ថៈថា **វាយតិ សហជាតធម្មេ អបតមានេ កត្វា វហតីតិ = វាយោ :** ធាតុណា រមែងបក់ផាត់ រមែងនាំទៅនូវរូបដែលកើតព្រមជាមួយខ្លួន ធ្វើមិនឱ្យកម្រើកញ័រ ព្រោះហេតុនោះ ធាតុនោះ ឈ្មោះថា វាយោ បានដល់ ខ្យល់ដែលធ្វើឱ្យតឹង ។

**សមុទីរណវាយោ** ខ្យល់ប្លែងចេញ ឬ**សមីរណវាយោ** ខ្យល់ដែលធ្វើឱ្យកម្រើកញ័រ, ជាធាតុខ្យល់ដែលជាហេតុឱ្យឥរិយាបថតូចធំ កម្រើកញ័រ ដូចជាធ្វើឱ្យប៉ប្រិចភ្នែក កម្រើកម្រាមដៃ

ម្រាមជើង ធ្វើឱ្យអាហារធ្លាក់ចុះទៅកាន់ក្រពះ រហូតដល់ជួយបញ្ចេញ វត្ថុស្មោគគ្រោគចេញអំពីរាងកាយជាដើម, ចំណែកធាតុខ្យល់ខាងក្រៅ ក៏ធ្វើឱ្យវត្ថុផ្សេង ៗកម្រើកញ័រទៅ ។

**វាយោ** ក្នុងសេចក្ដីនេះ មានវចនត្ថៈថា **វាយតិ ទេសន្តរុប្បត្តិហេតុភាវេន ភូតសង្ឃាតំ បាបេតីតិ = វាយោ** ធាតុណាតែងបក់ តែងញុំាងប្រជុំមហាភូតរូបដែលកើតព្រមនឹងខ្លួនឱ្យដល់ទីដទៃ ដោយសេចក្ដីជាឧប្បត្តិហេតុ ព្រោះហេតុនោះ ធាតុនោះ ទើបឈ្មោះថា វាយោ, បានដល់ ធាតុខ្យល់ដែលធ្វើឱ្យឃ្លាតឆ្ងាយទៅទីផ្សេង ។

<u>**ក្នុងវិសុទ្ធិមគ្គ**</u> ពោលថា **យោ វិត្ថម្ភនភាវោ វា សមុទីរណភាវោ វា អយំ វាយោធាតុ** ភាវៈដែលតឹងក្ដី ភាវៈដែលកម្រើកញ័រក្ដី យ៉ាងណា នេះហៅថា **វាយោធាតុ** ។

## លក្ខណាទិចតុក្កៈរបស់វាយោ

**១-វិត្ថម្ភនលក្ខណោ** មានការតឹង ជាលក្ខណៈ

**២-សមុទីរណរសោ** មានការញ័រ ជាកិច្ច

**៣-អភិនីហារបច្ចុប្បដ្ឋានោ** មានការនាំចេញ ជាផល

**៤-អវិសេសធាតុត្តយបទដ្ឋានោ** មានធាតុ ៣ ដែលនៅសល់ ជាហេតុជិត ។

## វាយោធាតុ មាន ៤ យ៉ាង

**១-បរមត្ថវាយោ** ឬ**លក្ខណវាយោ** បានដល់ ធាតុខ្យល់ដែលមានសភាវៈជាបរមត្ថ

**២-សសម្ភារវាយោ** ឬ **សុត្តន្តវាយោ** បានដល់ ធាតុខ្យល់ ព្រមទាំងចំណែកប្រកប មានទាំងខាងក្នុង និងខាងក្រៅ ។ នៅខាងក្នុងហៅថា **អជ្ឈត្តិកវាយោ** ដែលជាខាងក្រៅ ហៅថា **ពាហិរវាយោ** ។

<u>ក្នុងធាតុវិភង្គ</u> សម្ដែង**អជ្ឈត្តិកវាយោ** ទុក ៦ យ៉ាងគឺ ៖

**១-ឧទ្ធង្គមា វាតា** ខ្យល់បក់ពីក្រោមឡើងលើ

**២-អធោគមា វាតា** ខ្យល់បក់ពីលើចុះក្រោម

**៣-កុច្ឆិសយា វាតា** ខ្យល់ដេកនៅក្នុងផ្ទៃ ( ខ្យល់ខាងក្រៅពោះវៀន )

៤-**កោដ្ឋាសយា វាតា** ខ្យល់ក្នុងក្រពះ( ខ្យល់ខាងក្នុងពោះវៀន )
៥-**អង្គមង្គានុសារិនោ វាតា** ខ្យល់ផ្សព្វផ្សាយសព្វអវយវៈតូចធំ
៦-**អស្សាសោ បស្សាសោ** ខ្យល់ដកដង្ហើមចូល-ចេញ

ក្នុងធាតុវិភង្គ សម្ដែង **ពាហិរវាយោ** ទុកថា **បុរត្ថិមវាតា** ខ្យល់បក់មក អំពីទិសខាងកើត, **បច្ឆិមា វាតា** ខ្យល់បក់មកអំពីទិសខាងលិច, **ឧត្តរា វាតា** ខ្យល់បក់មកអំពីទិសខាងជើង, **ទក្ខិណា វាតា** ខ្យល់បក់មកអំពីទិសខាងត្បូង, **សរជា វាតា** ខ្យល់មានធូលី, **អរជា វាតា** ខ្យល់មិនមានធូលីជាដើម ។

៣-**កសិណវាយោ** ឬ **អារម្មណវាយោ** បានដល់ វាយោកសិណ ឬខ្យល់ដែលជាអារម្មណ៍របស់សមថកម្មដ្ឋាន ។

៤-**សម្មុតិវាយោ** ឬ **បកតិវាយោ** បានដល់ ខ្យល់ធម្មតាដែលបក់ផាត់ទៅមក ។

## ធាតុទាំង ៤ មិនប្រែប្រួល

តេជោធាតុវាយោធាតូនម្បិ សេសធាតូសុ

សកសកកិច្ចករណេ ឯសេវ នយោ ។ តេជោធាតុ ហិ បឋវីធាតុំ ផុសិត្វា ឈាបេតិ ។ សា បន ន ឧណ្ហា ហុត្វា ឈាយតិ ។ យទិ ឧណ្ហា ហុត្វា ឈាយេយ្យ ឧណ្ហត្តលក្ខណា នាម ភវេយ្យ ។ អាបោធាតុំ បន អផុសិត្វាវ តាបេតិ ។ សាបិ តបមានា ន ឧណ្ហា ហុត្វា តបតិ ។ យទិ ឧណ្ហា ហុត្វា តបេយ្យ ឧណ្ហត្តលក្ខណា នាម ភវេយ្យ ។ វាយោធាតុំ បន ផុសិត្វាវ តាបេតិ ។ សាបិ តបមានា ន ឧណ្ហា ហុត្វា តបតិ ។ យទិ ឧណ្ហា ហុត្វា តបេយ្យ ឧណ្ហត្តលក្ខណា នាម ភវេយ្យ ។ វាយោធាតុ បឋវីធាតុំ ផុសិត្វា វិត្ថម្ភេតិ. តថា តេជោធាតុំ អាបោធាតុំ បន អផុសិត្វាវ វិត្ថម្ភេតិ ។

ក្នុងតេជោធាតុ និងវាយោធាតុ តែងធ្វើកិច្ចរបស់ខ្លួន ក្នុងធាតុដ៏សេសក៏ន័យនេះដែរ ។ ពិតមែនហើយ តេជោធាតុប៉ះនឹងបឋវីធាតុហើយ ក៏ធ្វើឱ្យបឋវីធាតុក្តៅ ចំណែកបឋវីធាតុនោះ មិនមែនជាភ្លើងទេ, បើថា បឋវីធាតុជាធាតុភ្លើងមែននោះ បឋវីធាតុគប្បីមានសភាពក្តៅជាលក្ខណៈ ។ ម៉្យាងទៀត តេជោធាតុប៉ះនឹង

អាបោធាតុហើយ ទើបធ្វើឱ្យអាបោក្តៅ សូម្បីអាបោធាតុនោះ ក៏មិនមែនជាភ្លើងដែរ, បើថា អាបោធាតុជាធាតុភ្លើងហើយក្តៅមែននោះ អាបោធាតុគប្បីមានសភាពក្តៅ ជាលក្ខណៈ ។ មួយទៀត តេជោធាតុនោះប៉ះវាយោធាតុនោះឯង ទើបវាយោក្តៅ, សូម្បីវាយោនោះកាលដែលក្តៅ ក៏មិនមែនជាធាតុភ្លើង, បើថា វាយោធាតុជាធាតុភ្លើងមែននោះ វាយោធាតុគប្បីមានសភាពក្តៅជាលក្ខណៈ ។ វាយោធាតុ កាលប៉ះនឹងបឋវីធាតុហើយ រមែងតឹងឡើង; ប៉ះនឹងតេជោ ក៏ធ្វើឱ្យតឹងឡើងដែរ, តែវាយោធាតុនោះសូម្បីមិនប៉ះអាបោធាតុក៏ដោយ ក៏ធ្វើឱ្យអាបោធាតុតឹងបាន ។

**ឧប្ផុរសំ បចិត្វា ផាណិតបិណ្ឌេ ករិយមានេ អាបោធាតុ ថទ្ធា ហោតិ ន ហោតីតិ ។ ន ហោតិ ។ សា ហិ បគ្ឃរណលក្ខណា ។ បឋវីធាតុ កក្ខឡលក្ខណា ។ ឧមត្តំ បន អាបោ អធិមត្តបឋវីគតិកំ ជាតំ ។ សា ហិ រសាការេន ឋិតភាវំ វិជហតិ. លក្ខណំ ន វិជហតិ ។ ផាណិតបិណ្ឌេ វិលីយមានេបិ បឋវីធាតុ ន វិលីយតិ ។ កក្ខឡលក្ខណា ហិ បឋវីធាតុ**

បត្ថរណលក្ខណា អាបោធាតុ ។ ឱមត្តា បន បថវី អធិមត្តា អាបគតិកា ហោតិ ។ សា បិណ្ឌាការេន ឋិតភាវំ វិជហតិ. លក្ខណំ ន វិជហតិ ។ ចតុន្នញ្ហិ មហាភូតានំ ភាវញ្ញថត្តមេវ ហោតិ. លក្ខណញ្ញថត្តំ នាម នត្ថិ ។ តស្ស អភាវោ អដ្ឋានបរិកប្បសុត្តេន ទីបិតោ ។

សួរថា កាលបុគ្គលរម្ងាស់ទឹកអំពៅធ្វើជាស្ករ អាបោធាតុរឹងឬទេ ឆ្លើយថា មិនមែនរឹងទេ ព្រោះអាបោធាតុនោះ មានការហូរនិងជ្រួតជ្រាប ជាលក្ខណៈ បថវីធាតុមានសភាពរឹង ជាលក្ខណៈ ប៉ុន្តែថា អាបោធាតុមានបរិមាណតិច ក៏ទឹងប្រព្រឹត្តទៅតាមបថវីធាតុដែលច្រើនក្រៃលែង ពិតមែន អាបោធាតុនោះរមែងលះភាវៈដែលតាំងនៅដោយអាការជារស(ទឹក)បាន តែមិនលះលក្ខណៈ សូម្បីកាលដុំស្ករអំពៅរលាយ បថវីធាតុមិនរលាយទេ ព្រោះបថវីមានសភាពរឹង ជាលក្ខណៈ អាបោធាតុមានការហូរចេញ ជាលក្ខណៈ ។ ប៉ុន្តែបើថា បថវីធាតុមានបរិមាណទាបវិញ ក៏ប្រព្រឹត្តទៅតាមអាបោធាតុដែលមានបរិមាណច្រើន ។ បថវីធាតុ

នោះ រមែងលះភាវៈដែលតាំងនៅដោយអាការជាដុំបាន តែមិនលះលក្ខណៈខ្លួន ព្រោះថា មហាភូតរូបទាំង ៤ រមែងដល់សភាពប្រែប្រួលប្រព្រឹត្តទៅប៉ុណ្ណោះ ដែលឈ្មោះថា សភាពប្រែប្រួលរបស់លក្ខណៈមិនបានមាន សេចក្តីមិនមាននៃសេចក្តីប្រែប្រួលដោយលក្ខណៈនោះ ទ្រង់សម្តែងទុកដោយអដ្ឋានបរិកប្បសូត្រ ។ សេចក្តីនេះ សមដោយព្រះតម្រាស់ដែលត្រាស់ទុកថា ៖

**“សិយា. អានន្ទ. ចតុន្នំ មហាភូតានំ អញ្ញថត្តំ. បឋវីធាតុយា ។បេ ។ វាយោធាតុយា ន ត្វេវ ពុទ្ធេ អវេច្ចប្បសាទេន សមន្នាគតស្ស អរិយសាវកស្ស សិយា អញ្ញថត្តំ** : ម្នាលអានន្ទ សេចក្តីប្រែប្រួល មានចំពោះតែមហាភូតរូប ៤ គឺ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតុ ឯសេចក្តីប្រែប្រួលរបស់អរិយសាវក ដែលប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធ មិនមានសោះឡើយ”[១] ។

---

១. អង្គុ. តិក. អានន្ទវគ្គ. ៤១. ៧៧/៣០២ ។

## ពួកទី ២ : បសាទរូប ៥

បសាទរូប គឺ **បសាទ + រូប** ប្រែថា រូបថ្លា ។

<u>ក្នុងបរមត្ថទីបនី</u> សម្ដែងវចនត្ថៈទុកថា ៖

**បសីទន្តីតិ = បសាទា** ឈ្មោះថា ប្រសាទ ព្រោះអត្ថថា ផូរផង់ ស្រស់ថ្លា ។

<u>ក្នុងអភិធម្មត្ថវិភាវិនីដីកា</u> សម្ដែងវចនត្ថៈថា

**ចតុមហាភូតានំ បសន្នភាវហេតុលក្ខណត្តា = បសាទរូបំ** : ឈ្មោះថា ប្រសាទរូប ព្រោះហេតុដែលមហាភូត រូប ៤ មានការផូរផង់ ជាលក្ខណៈ ។

### បសាទរូប ៥ គឺ

ចក្ខុប្រសាទរូប សោតប្រសាទរូប ឃានប្រសាទរូប ជិវ្ហាប្រសាទរូប កាយប្រសាទរូប ។

## ១-ចក្ខុបសាទរូប

ប្រសាទរូបណា មានការថ្លា ដូចកញ្ចក់ឆ្លុះស្រមោល ដែលអាស្រ័យមហាភូតរូប ៤ នៅក្នុងសសម្ភារចក្ខុ ជាប់ចំពោះក្នុងសសម្ភារចក្ខុនេះ ឈ្មោះថា ចក្ខុប្រសាទរូប ។ ចក្ខុប្រសាទរូបនេះ ផ្សាយពេញក្រពេញភ្នែករហូតដល់ ៧ ជាន់ ដូចប្រេងដែលស្រោចចុះលើសំឡី ៧ ជាន់ ក្នុងមណ្ឌលរង្វង់ភ្នែកដែលឃើញរូប ដូចជាផ្ទៃកើតឡើងនៃសរីរៈ សណ្ឋានរបស់បុគ្គលដែលនៅចំពោះមុខ ក្នុងកណ្ដាលនៃរង្វង់ភ្នែកខ្មៅដែលព័ទ្ធជុំវិញ ដោយគ្រាប់ភ្នែកពណ៌សរបស់សសម្ភារចក្ខុនោះ មានឧបការៈដែលធាតុ ៤ ឧបការៈ(ជួយជ្រោមជ្រែង) សម្រេចហើយដោយកិច្ច គឺ ឱ្យទ្រង់ទុក ឱ្យសើមជានិច្ច ឱ្យក្ដៅ ឱ្យកម្រើកញ័រទៅមក ប្រៀបដូចនាងស្នំ ៤ នាក់ ចាំបម្រើ ឧបការៈរក្សាព្រះរាជកុមារ គឺ ម្នាក់ធ្វើនាទីចាំចិញ្ចឹមឧបត្ថម្ភ, ម្នាក់ឱ្យស្រង់ទឹកសរីរៈ ម្នាក់ឱ្យប្រដាប់តាក់តែង, ម្នាក់នៅចាំបក់ផ្លិតឱ្យកុមារ ដូច្នេះ ចក្ខុប្រសាទរូបនេះ ដែល

ចិត្ត ឧតុ និងអាហារឧបត្ថម្ភ ដែលអាយុ គឺ ជីវិតិន្ទ្រិយអនុបាល រក្សាព័ទ្ធជុំវិញដោយគោចររូប មានវណ្ណៈ និងគន្ធៈជាដើម ។

ចក្ខុប្រសាទរូបនេះ មានប្រមាណប៉ុនក្បាលចៃ ឱ្យសម្រេចជាវត្ថុនិងទ្វារ តាមសមគួរដល់វិថីចិត្ត មានចក្ខុវិញ្ញាណជាដើម ។

ដូចពាក្យដែលព្រះធម្មសេនាបតី សារីបុត្តពោលទុកថា

**សត្វ រមែងឃើញនូវរូបទាំងឡាយ ដោយចក្ខុប្រសាទរូបណា ចក្ខុប្រសាទរូបនេះ តូច ល្អិត មានប្រមាណប៉ុនក្បាលចៃ ដូច្នេះ ។**

**ចក្ខុ** មានវចនត្ថៈថា ៖

**ចក្ខុវិញ្ញាណដ្ឋិតំ ហុត្វា សមវិសមំ ចក្ខតិ អាចិក្ខន្តំ វិយ ហោតីតិ** = **ចក្ខុ** ប្រែថា រូបណា ជាទីតាំងនៃចក្ខុវិញ្ញាណ ប្រាប់ គឺ រមែងដូចជាប្រាប់ថា ពណ៌ល្អនិងមិនល្អ ព្រោះហេតុនោះ រូបដែលដូចជាប្រាប់នោះ ទើបឈ្មោះថា **ចក្ខុ** បានដល់ ចក្ខុប្រសាទរូប ។

## លក្ខណាទិចតុក្កៈរបស់ចក្ខុប្រសាទរូប

**១-រូបាភិឃាតារហភូតប្បសាទលក្ខណំ** មានភាពថ្លានៃភូតរូបគួរប៉ះ ខ្ទប់ជាមួយពណ៌ ជាលក្ខណៈ

**២-រូបេសុ អាវិញ្ឆនរសំ** មានការទាញរករូបារម្មណ៍ ជាកិច្ច

**៣-ចក្ខុវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវចក្ខុវិញ្ញាណ ជាផល

**៤-ទដ្ឋុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតអំពីកម្មដោយភាពជាអ្នកប្រាថ្នាដើម្បីនឹងឃើញ ជាហេតុ ជាបទដ្ឋាន ។

## ចក្ខុមាន ២ ប្រភេទ

១-មំសចក្ខុ បានដល់ ភ្នែកសាច់ មាន ២ យ៉ាង

២-បញ្ញាចក្ខុ បានដល់ ភ្នែក គឺបញ្ញា មាន៥ យ៉ាង ។

បណ្តាចក្ខុទាំង ២ ប្រភេទនោះ មំសចក្ខុ ២ គឺ

ប្រសាទចក្ខុ ក៏គឺចក្ខុប្រសាទនុ៎ះឯង ចំណែកសសម្ភារចក្ខុ បានដល់ ដុំសាច់ដែលនៅក្នុងគ្រាប់ភ្នែក ។

មំសចក្ខុនេះ ដោយសង្ខេបមានចំណែកប្រកប ១៤ រូប គឺ មហាភូតរូប ៤ វណ្ណៈ គន្ធៈ រសៈ ឱជា សម្ភវៈ (ការកើតឡើង) សណ្ឋាន (ការតាំងនៅដោយប្រពៃ) ជីវិត ភាវៈ កាយប្រសាទ និងចក្ខុប្រសាទ ។

ដោយពិស្តារ ក៏មានចំណែកប្រកប ៤៤ រូប បានដល់រូបទាំង ១០ នេះ គឺ មហាភូតរូប ៤ វណ្ណៈ គន្ធៈ រសៈ ឱជា សណ្ឋាន សម្ភវៈ ដែលអាស្រ័យហេតុ ៤ កើតឡើង, រូបទាំង ១០ នេះ កើតដោយសមុដ្ឋាន ៤ ទើបជា ៤០ រូប និងសសម្ភារចក្ខុ មានកម្មជាសមុដ្ឋានតែម្យ៉ាង ៤ រូបទៀត គឺ ជីវិត ភាវៈ កាយប្រសាទ និងចក្ខុប្រសាទ រួមជា ៤៤ រូប ។

**បញ្ញាចក្ខុ ៥ គឺ**

១.ពុទ្ធចក្ខុ ព្រះនេត្ររបស់ព្រះពុទ្ធ ដែលជ្រាបនិស្ស័យបារមីរបស់សត្វ

២.សមន្តចក្ខុ ព្រះនេត្រដែលដឹងធម៌ដោយជុំវិញ

៣.ញាណចក្ខុ ព្រះនេត្រដែលជាប្រាជ្ញាត្រាស់ដឹងធម៌

៤.ទិព្វចក្ខុ ព្រះនេត្រទិព្វដែលអាចឃើញបានឆ្ងាយ

៥.ធម្មចក្ខុ ព្រះនេត្រឃើញធម៌ដែលជាត្រៃលក្ខណ៍

បណ្ដាចក្ខុ ៥ ទាំងនេះ គឺ ៖

ចក្ខុ ដែលត្រាស់ថា "**អទ្ទសំ ខោ អហំ. ភិក្ខវេ. ពុទ្ធចក្ខុនា លោកំ វោលោកេន្តោ សត្តេ អប្បរជក្ខេ** ។បេ ។ : ម្នាលភិក្ខុទាំងឡាយ កាលតថាគតកំពុងប្រមើលមើលសត្វលោក ដោយពុទ្ធចក្ខុ ក៏បានឃើញនូវពួកសត្វដែលមានធូលីតិចក្នុងភ្នែក ។ល ។"[១] នេះ ឈ្មោះថា **ពុទ្ធចក្ខុ** បានដល់ អាសយានុសយញ្ញាណ និងឥន្ទ្រិយបរោបរិយត្តិញ្ញាណ គឺ មហាកិរិយាញ្ញាណសម្បយុត្តចិត្ត ៤ ។

ចក្ខុ ដែលត្រាស់ថា "**សមន្តចក្ខុ វុច្ចតិ សព្វញ្ញុតញ្ញាណំ** : ព្រះសព្វញ្ញុតញ្ញាណ ហៅថា **សមន្តចក្ខុ**"[២] បានដល់ បញ្ញា

---

១. មជ្ឈិ. មូល. បាសិរាសិសូត្រ. ២១. ៦១/១៤៩ ។

២. ខុទ្ទ. មហា. តុវដកសុត្តនិទ្ទេស. ៦៦. ២៩/៤០ ។

ដែលដឹងធម៌ទាំងពួង ទាំងបញ្ញត្តិ និងបរមត្ថ (គឺ មហាកិរិយាញាណសម្បយុត្តចិត្ត ៤) ។

ចក្ខុ ដែលត្រាស់ថា "ចក្ខុកើតឡើងហើយ ញាណកើតឡើងហើយ"[១]នេះ ឈ្មោះថា **ញាណចក្ខុ** បញ្ញាក្នុងអរហត្តមគ្គចិត្ត ។

ចក្ខុ ដែលត្រាស់ថា "**អទ្ទសំ ខោ អហំ. ភិក្ខវេ. ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន បញ្ចវគ្គិយេ ភិក្ខូ ពារាណសិយំ វិហរន្តេ ឥសិបតនេ មិគទាយេ** : ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញពួកបញ្ចវគ្គិយភិក្ខុ នៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី ដោយទិព្វចក្ខុដ៏បរិសុទ្ធស្អាត កន្លងលើសចក្ខុរបស់មនុស្សសាមញ្ញ"[២] នេះ ឈ្មោះថា **ទិព្វចក្ខុ** (គឺ អភិញ្ញាចិត្ត ២) ។

---

១. វិន. មហា. មហាខន្ធក. ៦. ១៥/៣១ ។

២. មជ្ឈិ. មូល. បាសិរាសិសូត្រ. ២១. ៦២/១៥៣ ។

ចក្ខុ ដែលត្រាស់ថា “**ឧបាលិស្ស គហបតិស្ស តស្មឹ យេវាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ** : ធម្មចក្ខុ គឺ សោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង ដល់ឧបាលិគហបតី ក្នុងកន្លែងអង្គុយនោះឯង”[១] នេះ ឈ្មោះថា **ធម្មចក្ខុ** ( បញ្ញាក្នុងមគ្គ ៣ ខាងក្រោម ) ។

ក្នុងធម្មសង្គណី[២] សម្ដែងពាក្យវេវចនរបស់ចក្ខុ ១៤ បទ គឺ ហៅថា ចក្ខុ ព្រោះជាអ្នកត្រួតត្រាក្នុងការឃើញ

ហៅថា ចក្ខាយតន ព្រោះជាទីប្រជុំចុះនៃកំណើតរបស់ខ្លួន

ហៅថា ចក្ខុធាតុ ព្រោះជាសភាវៈសូន្យ ទាំងមិនមែនជា

---

១. មជ្ឈិ. មជ្ឈិ. ឧបាលិវាទសូត្រ. ២៣. ៧៤/១១៤ ក្នុងសទ្ធម្មប្បកាសិនី នៃបដិសម្ភិទាមគ្គ សម្ដែងថា ពាក្យថា ធម្មចក្ខុ ក្នុងទីខ្លះ បានដល់ ញាណក្នុងបឋមមគ្គ. ក្នុងទីខ្លះ បានដល់ ញាណក្នុងមគ្គ ៣ ខាងដើម. ក្នុងទីខ្លះ បានដល់ ញាណក្នុងមគ្គទាំង ៤ ។

២. អភិ. សង្គ. រូបសង្គហ. ៧៩. ១៦/២១ ។

សត្វ

ហៅថា ចក្ខុន្ទ្រិយ ព្រោះមាននាទីខាងការឃើញ
ហៅថា លោក ព្រោះជារបស់សម្រាប់វិនាស
ហៅថា ទ្វារ ព្រោះជារបស់សម្រាប់បើកបិទ
ហៅថា សមុទ្រ ព្រោះបំពេញបានដោយក្រ
ហៅថា បណ្ឌរៈ ព្រោះជារបស់ថ្លាបរិសុទ្ធ
ហៅថា ខេត្ត ព្រោះជាកន្លែងកើតផស្សៈជាដើម
ហៅថា វត្ថុ ព្រោះជាទីតម្កល់ផស្សៈជាដើម
ហៅថា នេត្រ ព្រោះបង្ហាញទីស្មើនិងទីមិនស្មើ
ហើយនាំអត្តភាពទៅ
ហៅថា នយនៈ ព្រោះដូចគ្នានឹងនេត្រ
ហៅថា ត្រើយអាយ ព្រោះរាប់បញ្ចូលខាងក្នុងកាយខ្លួន
ហៅថា ស្រុកទំនេរ ព្រោះជារបស់សាធារណដល់ជន
ច្រើន ទាំងគ្មានម្ចាស់ ។

សោតជាដើម ក៏ន័យនេះ ។

## ២.សោតបសាទរូប

សោតប្រសាទរូប បានដល់ ប្រសាទនៃត្រចៀកដែលមានភាពថ្លា អាចទទួលសំឡេងជាអារម្មណ៍ ជាបច្ច័យឱ្យកើតសោតវិញ្ញាណ ។

**សោត** មានវចនត្ថៈថា **សោតវិញ្ញាណដ្ឋិតំ ហុត្វា សទ្ទំ សុណាតីតិ = សោតំ :** រូបណា ជាទីតាំងរបស់សោតវិញ្ញាណរមែងស្តាប់សំឡេង ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា សោត បានដល់ សោតប្រសាទរូប ។

ន័យមួយទៀត **សទ្ទំ សុណន្តិ ឯតេនាតិ វា សទ្ទំ សុយន្តិ ឯតេនាតិ = សោតំ :** ចិត្តនិងចេតសិក រមែងបានឮសំឡេង ដោយរូបនេះ ព្រោះហេតុនោះ រូបដែលជាហេតុឱ្យចិត្តនិងចេតសិក បានឮនេះ ទើបឈ្មោះថា **សោត** ឬ សត្វទាំងឡាយ រមែងបានឮសំឡេង ដោយអាស្រ័យរូបនេះ ដោយហេតុនោះ រូបនេះ ទើបឈ្មោះថា **សោត** ។

សោតប្រសាទរូបនេះ តាំងនៅក្នុងប្រទេសដែលមានសណ្ឋាន ដូចវង់ចិញ្ចៀន មានរោមក្រហមល្អិតដុះឡើង ខាងក្នុងប្រហោង សសម្ភារសោត ដែលធាតុ ៤ មានសេចក្តីដូចពោលមក ឧបត្ថម្ភហើយ ដែលចិត្ត ឧតុ និងអាហារឧបត្ថម្ភ ដែលអាយុគឺ ជីវិតអនុបាលរក្សា ដែលគោចររូបទាំងឡាយ មានពណ៌ជាដើម ព័ទ្ធជុំវិញហើយ ឱ្យសម្រេចជាវត្ថុនិងទ្វារតាំងនៅតាមសមគួរដល់ វិថីចិត្តទាំងឡាយ មានសោតវិញ្ញាណជាដើម ។

## លក្ខណាទិចតុក្កៈរបស់សោតប្រសាទរូប

១- **សទ្ទាភិឃាតារហភូតប្បសាទលក្ខណំ** មានភាពថ្លានៃភូតរូប គួរដល់ការប៉ះខ្ទប់ជាមួយសំឡេង ជាលក្ខណៈ

២- **សទ្ទេសុ អាវិញ្ឆនរសំ** មានការទាញរកសំឡេង ជាកិច្ច

៣- **សោតវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវ សោតវិញ្ញាណ ជាផល

៤- **សោតុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើត អំពីកម្មដោយភាពជាអ្នកប្រាថ្នាដើម្បីនឹងស្តាប់ ជាបទដ្ឋាន ។

## សោតមាន ៣ យ៉ាង

**១-ទិព្វសោត** បានដល់ សោតញ្ញាណ ឬទិព្វសោតអភិញ្ញា ២

**២-តណ្ហាសោត** បានដល់ សោត គឺ តណ្ហា

**៣-មំសសោត** បានដល់ ប្រសាទសោត និងសសម្ភារសោតៈ ។

ក្នុងធាតុបទីបិកា ពោលសោត ៧ ន័យ ៖

**១-សោត** សំដៅដល់ **រូប** មានបាលីថា **សោតាយតនំ បេតំ សោតធាតុ បេសា សោតិន្ទ្រិយំ បេតំ** : ហៅថា សោតាយតនៈក៏បាន ហៅថា សោតធាតុ ក៏បាន ហៅថា សោតិន្ទ្រិយ ក៏បាន ។[១]

**២-សោត** សំដៅដល់ **សោតវិញ្ញាណ** មានបាលីថា **សោតេន សទ្ទំ សុត្វា** : ឮសំឡេងដោយត្រចៀក ។[២]

---

១. អភិ. សង្គ. រូបសង្គហ. ៧៩. ១៧/២៥ ។

២. សំយុ. សឡា. អាសីវិសវគ្គ. ៣៥. ៣៤៥/៤៤៨ ។

៣-**សោត** សំដៅដល់ **ទិព្វសោត** មានបាលីថា **ទិព្វាយ សោតធាតុយា** : ដោយទិព្វសោតធាតុ ។

៤-**សោត** សំដៅដល់ **កិលេស** មានបាលីថា **យានិ សោតានិ លោកស្មឹ សតិ តេសំ និវារណំ** : សតិជាគ្រឿងទប់ខ្សែតណ្ហាទាំងឡាយនោះ ដែលមាននៅក្នុងលោក ។[១]

៥-**សោត** សំដៅដល់ **ក្រសែទឹក** មានបាលីថា **អទ្ទស ខោ ភគវា មហន្តំ ទារុក្ខន្ធំ សោតេន វុយ្ហមានំ** : ព្រះមានព្រះភាគ ទ្រង់បានទតឃើញកំណាត់ឈើធំ កំពុងអណ្តែតតាមក្រសែទឹកក្នុងឆ្នេរទន្លេគង្គា ។[២]

៦-**សោត** សំដៅដល់ **អរិយមគ្គ** មានបាលីថា **អរិយស្សេតំ អាវុសោ អដ្ឋង្គិកស្ស មគ្គស្ស អធិវចនំ យទិទំ**

---

១. ខុទ្ទ. សុត្ត. បារាយនវគ្គ. ៥៤. ១១២/៣៣៥; ខុទ្ទ. ចូឡ. ៦៧. ៧១/២៤ ប្រែថា "ខ្សែទាំងឡាយ ណាក្នុងលោក សតិជាគ្រឿងបិទខ្សែទាំងនោះ" ។
២. សំយុ. សឡា. អាសីវិសវគ្គ. ៣៥. ៣២០/៤០៨ ។

**សោតោ** : ម្នាលអាវុសោ សោតៈនេះ ជាឈ្មោះនៃអរិយមគ្គ ប្រកបដោយអង្គ ៨ ។[១]

**៧-សោត** សំដៅដល់ **ការបន្តនៃចិត្ត** មានបាលីថា **បុរិសស្ស ច វិញ្ញាណសោតំ បជានាតិ** : ទាំងដឹងច្បាស់នូវការបន្តនៃចិត្ត(វិញ្ញាណសោត) របស់បុរស ។[២]

## ៣-ឃានបសាទរូប

ឃានប្រសាទរូប ជារូបកើតអំពីកម្ម មានភាពថា អាចទទួលការប៉ះខ្លុប់ក្លិន ។

**ឃាន** មានវចនត្ថៈថា **ឃាយតីតិ = ឃានំ** : ឈ្មោះថា **ឃាន** ព្រោះអត្ថថា ស្រូបក្លិន បានដល់ ឃានប្រសាទរូប នេះ សម្ដែងដោយបរិយាយ ។

---

១. សទ្ធម្មប្បកាសិនី អដ្ឋកថានៃបដិសម្ភិទាមគ្គ ។

២. ទីឃ. បាដិ. សម្បសាទនីយសូត្រ. ១៨. ៧៩/២១២ ។

ន័យមួយទៀត សម្ដែងដោយនិប្បរិយាយ( ដោយត្រង់ )

**ឃាន** មានវចនត្ថៈថា **ឃាយន្តិ ឯតេនាតិ ឃានំ វា ឃាយីយន្តិ ឯតេនាតិ = ឃានំ :** ចិត្តនិងចេតសិក រមែងស្រូបក្លិនដោយរូបនេះ ព្រោះហេតុនោះ រូបនោះ ទើបជាហេតុស្រូបក្លិនរបស់ចិត្ត និងចេតសិកនេះ ទើបឈ្មោះថា **ឃាន** ឬសត្វទាំងឡាយ រមែងហិតក្លិនដោយរូបនេះ ព្រោះហេតុនោះ រូបនេះ ទើបឈ្មោះថា **ឃាន** បានដល់ ឃានប្រសាទរូប ។

## ឃាន ( មំសឃាន ) ២ គឺ

ប្រសាទឃាន ១ និងសសម្ភារឃាន ១ ។

**ប្រសាទឃាន** គឺ ឃានប្រសាទរូបដែលកើតឡើងក្នុងប្រទេសដែលមានសណ្ឋានដូចក្រចកពពែ ខាងក្នុងប្រហោងនៃសសម្ភារឃានៈ ។ បានទទួលការឧបត្ថម្ភ ការអនុបាលរក្សា ការព័ទ្ធជុំវិញ ដោយគោចររូបជាដើម ដូចគ្នានឹងចក្ខុប្រសាទនុំះឯងឱ្យសម្រេចជាវត្ថុ និងទ្វារ តាំងនៅតាមសមគួរដល់វិថីចិត្តទាំង

ឡាយ មានឃានវិញ្ញាណជាដើម ។

## លក្ខណាទិចតុក្កៈរបស់ឃានប្រសាទរូប

**១-គន្ធាភិឃាតារហភូតប្បសាទលក្ខណំ** មានភាពថ្លានៃភូតរូបគួរដល់ការប៉ះខ្ទប់ជាមួយក្លិន ជាលក្ខណៈ

**២-គន្ធេសុ អាវិញ្ឆនរសំ** មានការទាញរកគន្ធារម្មណ៍ ជាកិច្ច

**៣-ឃានវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវឃានវិញ្ញាណ ជាផល

**៤-ឃាយិតុកាមតានិទាន កម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតអំពីកម្មដោយ ភាពជាអ្នកប្រាថ្នាដើម្បីនឹងហិត ជាបទដ្ឋាន ។

## ៤-ជិវ្ហាបសាទរូប

ជិវ្ហាប្រសាទរូប ជារូបកើតអំពីកម្ម មានភាពអាចទទួលរសារម្មណ៍ គឺ រសផ្សេងៗ ។

**ជិវ្ហា** មានវចនត្ថៈថា **ជីវិតំ អវ្ហាយតីតិ** = **ជិវ្ហា** : ឈ្មោះ

ថា ជិវ្ហា ព្រោះអត្ថថា នាំមកនូវជីវិត (គឺ រូបហៅរករស) បាន ដល់ ជិវ្ហាប្រសាទរូប ។

ម្យ៉ាងទៀត មានវចនត្ថៈថា **ជីវិតំ អវ្ហាយន្តិ ឯតេនាតិ** = **ជិវ្ហា** : ចិត្តនិង ចេតសិក រមែងនាំមកនូវជីវិតដោយរូបនេះ ព្រោះហេតុនោះ រូបនេះ ទើបឈ្មោះថា **ជិវ្ហា** បានដល់ ជិវ្ហាប្រសាទរូប ។

**ជិវ្ហា ( មំសជិវ្ហា ) ២ គឺ** ប្រសាទជិវ្ហា១ និងសសម្ភារជិវ្ហា១ ។

**បសាទជិវ្ហា** គឺ ជិវ្ហាប្រសាទរូបដែលកើតឡើងតាំងនៅក្នុងប្រទេសនៃសសម្ភារជិវ្ហា នៅមានសណ្ឋានដូចត្របកផ្កាឧប្បល ដែលធាតុ ៤ ។ល ។ ឧតុ ចិត្ត និងអាហារឧបត្ថម្ភហើយ ដែលអាយុ គឺ ជីវិតរូបអនុបាលរក្សា ដែលព័ទ្ធជុំវិញដោយគោចររូបទាំងឡាយ មានពណ៌ជាដើម ហើយឱ្យសម្រេចជាវត្ថុ និងទ្វារតាំងនៅតាមសមគួរដល់វិថីចិត្តទាំងឡាយ មានជិវ្ហាវិញ្ញាណជាដើម ។

## លក្ខណាទិចតុក្កៈរបស់ជិវ្ហាប្រសាទរូប

១- **រសាភិឃាតារហភូតប្បសាទលក្ខណំ** មានភាពថ្លានៃភូតរូបគួរដល់ការប៉ះខ្ទប់ជាមួយរស ជាលក្ខណៈ

២- **រសេសុ អាវិញ្ឆនរសំ** មានការទាញរករស ជាកិច្ច

៣- **ជិវ្ហាវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវជិវ្ហាវិញ្ញាណ ជាផល

៤- **សាយិតុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតអំពីកម្ម ដោយភាពជាអ្នកប្រាថ្នាដើម្បីនឹងលិទ្ធជញ្ជក់រស ជាបទដ្ឋាន ។

## ៥-កាយបសាទរូប

កាយប្រសាទរូប ជារូបដែលកើតអំពីកម្ម មានភាពថ្លាអាចទទួលនូវការប៉ះខ្ទប់នឹងផោដ្ឋព្វារម្មណ៍ គឺ ភាពត្រជាក់ ក្ដៅ ទន់ រឹង និងតឹង ញ័រ ។

**កាយ** មានវចនត្ថៈថា **កុច្ឆិតានំ កេសាទីនំ បាបធម្មានញ្ច**

**អាយោតិ = កាយោ :** ធម៌ណា ជាទីប្រជុំនៃកោដ្ឋាសមានសក់ជាដើម និងជាទីប្រជុំនៃបាបធម៌ ដែលបណ្ឌិតស្អប់ខ្ពើម ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **កាយ** បានដល់ រូបកាយ និង នាមកាយ ។

**កាយ ៤ យ៉ាង**

**១-ប្រសាទកាយ** គឺ កាយប្រសាទរូប

**២-រូបកាយ** គឺ រូបធម៌ទាំងអស់

**៣-នាមកាយ** គឺ ចិត្តនិងចេតសិក

**៤-បញ្ញត្តិកាយ** គឺ សមូហប្បញ្ញត្តិ

ក្នុងទីនេះ សំដៅដល់ កាយប្រសាទរូបដែលមានភាពថ្លាផ្សាយទៅទូទាំងសរីរៈ ដូចជ័រសរសៃកប្បាស ។

**ក្នុងសម្មោហវិនោទនី** ពោលថា ៖

កាយនេះ ជាចំណែករបស់បឋវីធាតុដែលប្រព្រឹត្តក្នុងទីនោះ ៗ

ដូចជរសេរសែកប្បាសទៅតាមជាន់ស្រទាប់ក្នុងកប្បាស ដូច្នោះ ។

កាយប្រសាទរូបនេះ វៀរត្រង់ទីតាំងនៃតេជោធាតុដែលកើតអំពីកម្ម (បាចកតេជោ) ដែលជាទីរួមនៃអាហារថ្មី ក្រោមពោះវៀនធំ ដែលជាស្ថានទីរបស់តេជោធាតុ និងវៀរចុងសក់ ចុងរោម និងស្បែកក្រិនតាំងនៅទូទៅ ម្យ៉ាងទៀត កាយប្រសាទរូបសូម្បីតាំងនៅទូទៅយ៉ាងនេះ ក៏មិនលាយជាមួយប្រសាទរូបដទៃព្រោះលក្ខណៈផ្សេងគ្នា កាលទទួលឧបការៈឧបត្ថម្ភ ការអនុបាលរក្សា ការព័ទ្ធជុំវិញជាដើម មានន័យដូចពោលហើយ ទើបសម្រេចជាវត្ថុ និងទ្វារតាំងនៅតាមសមគួរដល់វិថីចិត្តទាំងឡាយមានកាយវិញ្ញាណជាដើម ។ រូបកាយ និងនាមកាយ មានអត្ថច្បាស់ហើយ ។ ចំណែកបញ្ញត្តិកាយ គឺ សមូហប្បញ្ញត្តិនោះបានដល់ បញ្ញត្តិធម៌ដែលរួមគ្នា ដូចពាក្យថា **ហត្ថិកាយ** កងទ័ពដំរី **អស្សកាយ** កងទ័ពសេះ **រថកាយ** កងទ័ពរថ **បត្តិកាយ** កងទ័ពទាហានថ្មើរជើងជាដើម ។

## កាយ ៤ យ៉ាងទៀត

<u>ក្នុងបរមត្ថទីបនី</u> ( ខុទ្ទ. ឥតិវុត្តក ) ពោលថា ៖

**១- ចោបនកាយ** បានដល់ កាយឃ្លាតកម្រើកញ័រ ឬការឱ្យកម្រើកញ័រ

**២- ករជកាយ** បានដល់ កាយកើតអំពីធូលីក្នុងទឹក

**៣- សមូហកាយ** បានដល់ កាយដែលប្រជុំគ្នា

**៤- ប្រសាទកាយ** បានដល់ កាយប្រសាទរូប

បណ្តាកាយទាំង ៤ នោះ ការសង្រួមកាយនិងវាចាដែលកម្រើកញ័រ ឈ្មោះថា **ចោបនកាយ ។** កាយក្រៅពីនេះ គឺកាយដែលកើតអំពីធូលីក្នុងទឹក ឈ្មោះថា **ករជកាយ ។** **សមូហកាយ** បានដល់ វិញ្ញាណកាយ ៦ មានចក្ខុវិញ្ញាណជាដើម និងផស្សកាយ ៦ មានចក្ខុសម្ផស្សជាដើម មួយទៀត លោកពោលវេទនាខន្ធជាដើម ក្នុងកាយបស្សទ្ធិ និងកាយលហុតា និងពោលកាយ គឺ បឋវីធាតុជាដើម ដោយន័យមានជាដើមថា

បុគ្គលខ្លះក្នុងលោកនេះ រមែងពិចារណាឃើញថា **បឋវីកាយ អាបោកាយ តេជោកាយ វាយោកាយ កេសាកាយ លោមាកាយ,,,** ដោយសេចក្ដីជារបស់មិនទៀង... ការពាល់ត្រូវ ផោដ្ឋព្វៈបាន ដោយកាយ ឈ្មោះថា **ប្រសាទកាយ** បានដល់ **កាយបសាទរូប** នុ៎ះឯង ។

លក្ខណាទិចតុក្កៈរបស់កាយប្រសាទរូប

**១-ផោដ្ឋព្វាភិឃាតារហភូតប្បសាទលក្ខណំ** មានភាពថ្លានៃភូតរូបគួរដល់ការប៉ះខ្ទប់នឹងផោដ្ឋព្វារម្មណ៍ ជាលក្ខណៈ

**២-ផោដ្ឋព្វេសុ អាវិញ្ឆនរសំ** មានការទាញរកផោដ្ឋព្វារម្មណ៍ ជាកិច្ច

**៣-កាយវិញ្ញាណស្ស អាធារភាវបច្ចុប្បដ្ឋានំ** មានការទ្រទ្រង់នូវកាយវិញ្ញាណ ជាផល

**៤-ផុសិតុកាមតានិទានកម្មជភូតបទដ្ឋានំ** មានភូតរូបដែលកើតអំពីកម្មដោយភាពជាអ្នកប្រាថ្នា ដើម្បីនឹងពាល់ត្រូវ ជាបទដ្ឋាន ។

## ពួកទី៣ : វិសយរូប ៧

វិសយរូប ឬហៅថា គោចររូប បានដល់ រូបដែលជាអារម្មណ៍របស់ចិត្ត និងចេតសិក ដែលកើតតាមទ្វារភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ។

វិសយរូប ៤ គឺ វណ្ណៈ សទ្ទៈ គន្ធៈ រសៈ

ចំណែកផោដ្ឋព្វៈ គឺ រូបដែលប៉ះខ្ទប់កាយ បានដល់បឋវីផោដ្ឋព្វៈ ១ តេជោផោដ្ឋព្វៈ ១ និងវាយោផោដ្ឋព្វៈ ១ រួម ៣, រូបរួមទាំងអស់ ជាវិសយរូប ៧ រូប ។

**គោចររូប** មានវចនត្ថៈថា ៖

**គោចររូបនាម បញ្ចវិញ្ញាណ វិសយភាវតោ** : រូប (ពណ៌)ជាដើម ឈ្មោះថា គោចររូប ព្រោះជាអារម្មណ៍របស់បញ្ចវិញ្ញាណ ។

**គាវោ ឥន្ទ្រិយានិ ចរន្តិ ឯត្ថាតិ = គោចរំ** : ដែលឈ្មោះថា គោចររូប ព្រោះអត្ថថា ជាទីត្រាច់ទៅនៃគោ គឺ ឥន្ទ្រិយទាំង

ឡាយ ។

<u>ក្នុងអភិធម្មត្ថវិភាវិនី</u> ពោលគោចររូបទាំង ៥ នេះ

មានសេចក្តីជាអារម្មណ៍នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ជាលក្ខណៈ ឬថា រូបទាំងនេះមានការប៉ះខ្ទប់ប្រសាទរូប ៥ មានចក្ខុប្រសាទរូបជាដើម ជាលក្ខណៈ ។

## ១- រូបារម្មណ៍ "ពណ៌"

រូប មានវចនត្ថៈថា **រូបយតិ ហទយង្គតភាវំ បកាសេតីតិ** = **រូបំ** ឈ្មោះថា រូប ព្រោះអត្ថថា សម្តែង គឺ ប្រកាសភាពជាអារម្មណ៍ទៅកាន់ហទយ, គឺរូបដែលធ្វើឱ្យដឹងសេចក្តីផ្សេង ៗ ។

ម្យ៉ាងទៀត **រូបយតិ ទព្វំ បកាសេតីតិ** = **រូបំ** ប្រែថា រូបណា រមែងសម្តែងវត្ថុ គឺ ប្រកាសវត្ថុដែលគួរប្រព្រឹត្ត ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា **រូប** បានដល់ រូបារម្មណ៍ ។

### លក្ខណាទិចតុក្កៈរបស់រូប

**១- ចក្ខុបដិហននលក្ខណំ** មានការប៉ះខ្ទប់នឹងចក្ខុប្រសាទ ជា

លក្ខណៈ

២- **ចក្ខុវិញ្ញាណស្ស វិសយភាវរសំ** មានភាពជាអារម្មណ៍ឱ្យចក្ខុវិញ្ញាណ ជាកិច្ច

៣- **តស្សេវ គោចរបច្ចុប្បដ្ឋានំ** មានភាពជាទីគោចររបស់ចក្ខុវិញ្ញាណនុ៎ះឯង ជាផល

៤- **ចតុមហាភូតបទដ្ឋានំ** មានមហាភូត ៤ ជាហេតុជិត ។

## ២-សទ្ទារម្មណ៍ "សំឡេង"

សទ្ទារម្មណ៍ បានដល់ សំឡេងដែលជាអារម្មណ៍របស់សោតវិញ្ញាណ ។

**សទ្ទ** មានវចនត្ថៈថា **សទ្ទិយតិ ឧច្ចរិយតីតិ = សទ្ទោ** រូបណា ដែលគេថ្លែងចេញ គឺ រមែងឱ្យលាន់ឮ ព្រោះហេតុនោះ រូបនោះ ឈ្មោះថា **សទ្ទ** បានដល់ សំឡេងដែលកើតអំពីចិត្ត ។

ម្យ៉ាងទៀត មានវចនត្ថៈថា **សប្បតិ សោតវិញ្ញេយ្យភាវំ**

**គច្ឆតីតិ = សទ្ទោ** រូបណា រមែងថ្លែងចេញ គឺ រមែងដល់ភាវៈឱ្យសោតវិញ្ញាណដឹង ព្រោះហេតុនោះ រូបនោះ ឈ្មោះថា **សទ្ទ** បានដល់ សំឡេងដែលកើតអំពីចិត្ត ឬឧតុ ជាសទ្ទារម្មណ៍ ។

## លក្ខណាទិចតុក្កៈរបស់សទ្ទរូប

**១-សោតបដិហននលក្ខណំ** មានការប៉ះខ្ទប់នឹងសោតប្រសាទ ជាលក្ខណៈ

**២-សោតវិញ្ញាណស្ស វិសយភាវរសំ** មានភាពជាអារម្មណ៍ឱ្យសោតវិញ្ញាណ ជាកិច្ច

**៣-តស្សេវ គោចរបច្ចុប្បដ្ឋានំ** មានគោចររបស់សោតវិញ្ញាណនុ៎ះឯង ជាផល

**៤-ចតុមហាភូតបទដ្ឋានំ** មានមហាភូត ៤ ជាហេតុជិត ។

## ៣_គន្ធារម្មណ៍ "ក្លិន"

គន្ធារម្មណ៍ បានដល់ ក្លិនដែលជាអារម្មណ៍របស់ឃានវិញ្ញាណ ។

**គន្ធ** មានវចនត្ថៈថា **គន្ធយតិ អត្តនោ វត្ថុំ សូចេតីតិ = គន្ធោ** ឈ្មោះថា គន្ធ ព្រោះអត្ថថា បញ្ចេញក្លិន គឺ រមែងប្រាប់នូវវត្ថុរបស់ខ្លួន ។

### គន្ធៈ ៤ យ៉ាង

**១, សីលគន្ធៈ** គឺ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ

**២, សមាធិគន្ធៈ** គឺ សម្មាវាយាម សម្មាសតិ សម្មាសមាធិ

**៣, បញ្ញាគន្ធៈ** គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ

**៤, អាយតនគន្ធៈ** គឺ គន្ធារម្មណ៍

### លក្ខណាទិចតុក្កៈរបស់គន្ធៈ

**១, ឃានបដិហននលក្ខណំ** មានការប៉ះខ្ទប់នឹងឃានប្រសាទ ជា

លក្ខណៈ

២, **ឃានវិញ្ញាណស្ស វិសយភាវរសំ** មានភាពជាអារម្មណ៍ ឱ្យឃានវិញ្ញាណ ជាកិច្ច

៣, **តស្សេវ គោចរបច្ចុប្បដ្ឋានំ** មានគោចររបស់ឃានវិញ្ញាណនុ៎ះឯង ជាផល

៤, **ចតុមហាភូតបទដ្ឋានំ** មានមហាភូត ៤ ជាហេតុជិត ។

## ៤-រសារម្មណ៍ "រស"

រសារម្មណ៍ បានដល់ រសដែលជាអារម្មណ៍របស់ជិវ្ហាវិញ្ញាណ

**រស** មានវចនត្ថៈថា **រសិយតិ អស្សាទិយតីតិ = រសោ** ឈ្មោះថា រស ព្រោះអត្ថថា ជិវ្ហាវិញ្ញាណ រមែងត្រេកអរ គឺពេញចិត្ត ។

មួយន័យទៀត **រសតិ តន្តិ = រសោ** បុគ្គលរមែងត្រេកអរនូវវិស័យ (អារម្មណ៍)នោះ ព្រោះហេតុនោះ វិស័យ

( អារម្មណ៍ ) នោះ ទើបឈ្មោះថា រស ( រស ប្រែថា វិស័យជាទីត្រេកអរ ) ។

## រស មាន ៤ យ៉ាង

**១, ធម្មរស** បានដល់ មគ្គចិត្តុប្បាទ ៤

**២, អត្ថរស** បានដល់ ផលចិត្តុប្បាទ ៤

**៣, វិមុត្តិរស** បានដល់ ព្រះនិព្វាន

**៤, អាយតនរស** បានដល់ រសារម្មណ៍ ដូចរសប្រៃ រសផ្អែមជាដើម ។

ក្នុងសម្មោហវិនោទនី ពោលថា ធម្មៈ បានដល់បច្ច័យ ៥ គឺ ហេតុដែលឱ្យកើតផល, អរិយមគ្គ, ភាសិត, កុសល, និងអកុសល ។ អត្ថៈ បានដល់ ផល ៥ កើតអំពីហេតុ គឺ សភាវៈដែលកើតព្រោះបច្ច័យ, និព្វាន, អត្ថនៃភាសិត, វិបាក, និងកិរិយា ។

ក្នុងអង្គុត្តរនិកាយ អដ្ឋកនិបាត ព្រះមានព្រះភាគត្រាស់ថា

“ម្នាលបហារាទ ធម្មវិន័យនេះ មានរសតែមួយ គឺវិមុត្តិរស”[១] ។

ក្នុងធម្មបទ តណ្ហាវគ្គ. ថា “**សព្វរសំ ធម្មរសោ ជិនាតិ** : ធម្មរស ឈ្នះរសទាំងពួង”[២] បានដល់ មគ្គ ៤ ផល ៤ និព្វាន ១ ជាធម្មរស ។

## លក្ខណាទិចតុក្កៈរបស់រស

**១, ជិវ្ហាបដិហននលក្ខណំ** មានការប៉ះខ្ទប់នឹងជិវ្ហាប្រសាទ ជាលក្ខណៈ

**២, ជិវ្ហាវិញ្ញាណស្ស វិសយភាវរសំ** មានភាពជាអារម្មណ៍ឱ្យជិវ្ហាវិញ្ញាណ ជាកិច្ច

**៣, តស្សេវ គោចរបច្ចុប្បដ្ឋានំ** មានគោចររបស់ជិវ្ហាវិញ្ញាណនុ៎ះឯង ជាផល

**៤, ចតុមហាភូតបទដ្ឋានំ** មានមហាភូត ៤ ជាហេតុជិត ។

---

១. អង្គ. អដ្ឋ. មហាវគ្គ. ៤៨. ១៩/៩៦ ។

២. ខុទ្ទ. ធម្ម. តណ្ហាវគ្គ. ៥២. ៣៤/៩៦ ។

## ៥_ផោដ្ឋព្វារម្មណ៍ "សម្ផស្ស"

ផោដ្ឋព្វារម្មណ៍ បានដល់ អារម្មណ៍ដែលមកប៉ះខ្ទប់កាយប្រសាទ មាន ៣ គឺ

បឋវីផោដ្ឋព្វៈ តេជោផោដ្ឋព្វៈ និង វាយោផោដ្ឋព្វៈ

**ផោដ្ឋព្វ** មានវិចនត្ថៈថា **ផុសិយតីតិ ផោដ្ឋព្វំ** = **ផោដ្ឋព្វំ** ឈ្មោះថាផោដ្ឋព្វៈ ព្រោះអត្ថថា ដែលភូតរូប ៣ (វៀរអាបោធាតុ) គប្បីប៉ះខ្ទប់ ។

មហាភូតរូប ៣ ដែលជាផោដ្ឋព្វារម្មណ៍ មានអត្ថបានសម្ដែងទុកហើយ ។

មួយទៀត លក្ខណាទិចតុក្កៈរបស់ផោដ្ឋព្វៈ ៣ មានបឋវីផោដ្ឋព្វៈជាដើម ពោលទុកហើយ ក្នុងលក្ខណាទិចតុក្កៈរបស់បឋវី_តេជោ_វាយោធាតុ[១] ។

---

១. នៅទំព័រ ៣៧. ៤៥. ៤៨. ដោយលំដាប់ ។

## ពួកទី៤ : ភាវរូប ២

ភាវៈ ២ បានដល់ ១ ឥត្ថីភាវៈ ភាពជាស្រី ២ បុរិសភាវៈ ភាពជាប្រុស ។

-ឥត្ថីភាវរូប គឺ រូបដែលសម្ដែងភាពជាស្រី

-បុរិសភាវរូប គឺ រូបដែលសម្ដែងភាពជាប្រុស

រូបទាំង ២ នេះជាសុខុមរូប កើតអំពីកម្មជាសមុដ្ឋាន មានពេញសរីរៈទាំងអស់ ដូចកាយិន្ទ្រិយ ។

### ១-ឥត្ថីភាវរូប

**ឥត្ថីភាវ** មានវចនត្ថៈថា **ឥត្ថិយា ភាវោ** = **ឥត្ថីភាវោ** : ភាវៈនៃស្រី ឈ្មោះថា ភាពជាស្រី ។

### លក្ខណាទិចតុក្កៈរបស់ឥត្ថីភាវរូប

**១, ឥត្ថីភាវលក្ខណំ** មានភាពជាស្រី ជាលក្ខណៈ

**២, ឥត្ថីតិ បកាសនរសំ** មានការប្រកាសថា ជាស្រី ជាកិច្ច

**៣, ឥត្ថីលិង្គាទីនំ ការណភាវបច្ចុប្បដ្ឋានំ** មានភាពជាហេតុនៃភេទ

ស្រីជាដើម ជាផល

៤, **ចតុមហាភូតបទដ្ឋានំ** មានមហាភូតរូប ៤ ជាហេតុជិត ។

ក្នុងអភិធម្មត្ថវិភាវិនី ពោលថា **ឥត្ថីលិង្គនិមិត្តកុត្តាកប្ប-ហេតុភាវលក្ខណំ = ឥត្ថត្តំ** : ភាពជាស្រី មានភាវៈនៃស្រី គឺ ភេទស្រី, និមិត្ត "សំឡេង និងការប្រាថ្នា" កុត្តៈ "ការកែក្រាយ" អាកប្បៈ "ទ្រង់ទ្រាយ" ជាហេតុ ជាលក្ខណៈ ។

តែក្នុងអដ្ឋកថា ពោលពណ៌នាភេទស្រីទុក ដោយប្រការដទៃ គឺ ពាក្យរបស់អដ្ឋកថានោះ លោកអាចារ្យទាំងឡាយ រួបរួមទុកយ៉ាងនេះថា ៖

| | |
|---|---|
| ទ្រង់ទ្រាយមានដៃជាដើម | ឈ្មោះថា **ភេទ**. |
| អាការមានការញញឹមជាដើម | ឈ្មោះថា **និមិត្ត**. |
| ការលេងដោយចង្អេរជាដើម | ឈ្មោះថា **កុត្តៈ**. |
| កិរិយាមានការដើរជាដើម | ឈ្មោះថា **អាកប្បៈ**. |

## ២. បុរិសភាវៈ

*បុរិសភាវ* មានវិចនត្ថៈថា *បុរិសស្ស ភាវោ = បុរិសភាវោ* ភាវៈនៃប្រុស ឈ្មោះថា ភាពជាប្រុស ។

### លក្ខណាទិចតុក្កៈរបស់បុរិសភាវរូប

**១, បុរិសភាវលក្ខណំ** មានភាពជាប្រុស ជាលក្ខណៈ
**២, បុរិសោតិ បកាសនរសំ** មានការប្រកាសថា ជាប្រុស ជាកិច្ច
**៣, បុរិសលិង្គាទីនំ ការណភាវបច្ចុប្បដ្ឋានំ** មានភាពជាហេតុនៃភេទប្រុសជាដើម ជាផល
**៤, ចតុមហាភូតបទដ្ឋានំ** មានមហាភូតរូប ៤ ជាហេតុជិត ។

<u>ក្នុងអភិធម្មត្ថវិភាវិនី</u> ពោលថា **បុរិសលិង្គាទិហេតុភាវ-លក្ខណំ = បុរិសត្តំ** : ភាពជាប្រុស មានភាវៈនៃប្រុស គឺ ភេទជាដើមជាហេតុ ជាលក្ខណៈ ។

ពោលដោយន័យនៃភាពជាប្រុសដែលផ្សេងពីស្រី មាន

៤ យ៉ាង គឺ ៖

**ភេទ** បានដល់ ទ្រង់ទ្រាយ មានដៃជាដើម

**និមិត្ត** បានដល់ គ្រឿងចំណាំ មានពុកមាត់ ពុកចង្កា

**កុត្តៈ** បានដល់ និស្ស័យ គឺ ការប្រព្រឹត្តិផ្សេង ៗ

**អាកប្បៈ** បានដល់ កិរិយា មានការឈរ ការដើរ... ។

ភាវៈទាំង ២ គឺ ភាពជាស្រីនិងប្រុសរបស់បុគ្គលអ្នកកើតក្នុងសម័យដើមកប្ប រមែងតាំងឡើងក្នុងបវត្តិកាល, ក្នុងខាងក្រោយតមក ភាវរូបទាំង ២ នេះ តាំងនៅក្នុងបដិសន្ធិកាល សូម្បីតាំងឡើងក្នុងបដិសន្ធិកាល រមែងកម្រើក គឺ រមែងផ្លាស់ប្តូរបាន ក្នុងបវត្តិកាល, ក្នុងសេចក្តីនេះ មានព្រះតម្រាស់ដែលត្រាស់ទុកក្នុងបឋមបារាជិកថា "សម័យនោះឯង ភិក្ខុមួយរូបក្លាយភេទខ្លួន ប្រែទៅជាស្រី ភិក្ខុនីមួយរូប ក្លាយភេទខ្លួន ប្រែទៅជា

ប្រុស”[១] ដូច្នេះ ។

បណ្ដាភេទទាំង ២ នោះ ភេទប្រុសជាឧត្តមភេទ ភេទស្រីជាហីនភេទ, ភេទប្រុសរមែងអន្តរធាន ព្រោះអកុសលមានកម្លាំងខ្លាំង ភេទស្រីរមែងតាំងឡើងដោយកុសលមានកម្លាំងខ្សោយ, តែភេទស្រីដែលអន្តរធានទៅ រមែងអន្តរធាន ព្រោះអកុសលមានកម្លាំងខ្សោយ ភេទប្រុសរមែងតាំងឡើងដោយកុសល មានកម្លាំងខ្លាំង គឺ ភាវៈទាំង ២ រមែងអន្តរធានទៅដោយអកុសល និងរមែងតាំងឡើងដោយកុសល ។

១. វិន. បារា. មេថុនធម្មសិក្ខាបទ. ១. ៥៦/១១៥-៦ ។

## ពួកទី ៥ ហទយរូប

ហទយរូប មាន២ គឺ ១.មំសហទយរូប ២.វត្ថុហទយរូប

**មំសហទយរូប** គឺ សសម្ភារហទយរូប បានដល់ ហទយរូបដែលជាដុំសាច់បេះដូង មានលក្ខណៈដូចផ្កាឈូកក្រពុំសំយុងចុះ ចំណែកហទយរូបដែលជាវត្ថុ (ទីអាស្រ័យកើត) របស់មនោធាតុ និងមនោវិញ្ញាណធាតុនោះ ជាសុខុមរូបដែលកើតអំពីកម្មជាសមុដ្ឋាន តាំងនៅក្នុងប្រឡោះ ខាងក្នុងសាច់បេះដូង ដែលមានលក្ខណៈដូចអណ្តូង ទំហំប្រមាណប៉ុនគ្រាប់បុន្នាគ ក៏ហទយរូបនេះ មានលោហិតប្រមាណមួយទូកដៃ នៅចិញ្ចឹមរក្សាខាងក្នុងប្រឡោះនេះ, ហទយវត្ថុនេះ ជាទីអាស្រ័យកើតឡើងនៃមនោធាតុ និងមនោវិញ្ញាណធាតុ ។

ហទយ មានវចនត្ថៈថា **ហទន្តិ សត្តា តំ តំ អត្ថំ វា បូរេន្តិ ឯតេនាតិ = ហទយំ :** សត្វទាំងឡាយ រមែងគិត រមែងញ៉ាំងប្រយោជន៍ និងវត្ថុដែលមិនមែនប្រយោជន៍នោះ ៗ ឱ្យពេញបានដោយរូបនោះ ព្រោះហេតុនោះ រូបនោះ ទើបឈ្មោះថា ហទយៈ ។

មួយទៀតថា **ហទយមេវ មនោធាតុមនោវិញ្ញាណធាតូនំ និស្សាយត្តា វត្ថុ ចាតិ = ហទយវត្ថុ** : ហទយនុ៎ះឯងជាវត្ថុ ព្រោះជាទីអាស្រ័យរបស់មនោធាតុ និងមនោវិញ្ញាណធាតុ ព្រោះហេតុនោះ ហទយនោះ ទើបឈ្មោះថា ហទយវត្ថុ ។

## លក្ខណាទិចតុក្កៈរបស់ហទយរូប

**១-មនោធាតុមនោវិញ្ញាណធាតូនំ និស្សយលក្ខណំ** មានភាពជាទីអាស្រ័យរបស់មនោធាតុនិងមនោវិញ្ញាណធាតុ ជាលក្ខណៈ

**២-តាសញ្ញេវ ធាតូនំ អាធារណរសំ** មានការទ្រទ្រង់ធាតុទាំង ២ នុ៎ះឯង ជាកិច្ច

**៣-ធាតុព្វហនបច្ចុប្បដ្ឋានំ** មានការលើកឡើងនូវធាតុទាំងនោះ ជាផល

**៤-ចតុមហាភូតបទដ្ឋានំ** មានមហាភូតរូប ៤ ជាហេតុជិត

<u>ក្នុងសម្មោហវិច្ឆេទនី</u> ពោលថា ហទយវត្ថុមានសណ្ឋាន ដូចផ្កាបុទុមក្រហមក្រពុំ ដែលបុគ្គលបកត្របកក្រៅចេញ ហើយដាក់ផ្កាប់មុខទុក, បេះដូងរបស់អ្នកមានបញ្ញារីកបន្តិច, របស់អ្នកមាន

បញ្ញាតិចក្រពុំ, តាំងនៅក្នុងចន្លោះដោះទាំង ២ ក្នុងសរីរៈ មានក្រពះ ថ្លើម វាវ តម្រងបស្សាវៈជាដើមហែហម, មានលោហិតប្រមាណកន្លះទូកដៃដែលឃាំងនៅក្នុងអណ្តូង ដែលមានខ្នាតធំល្មមជាទីតាំងនៃគ្រាប់បុន្នាគ ខាងក្នុងនៃសាច់សសម្ភារហទយនោះ ។

ក៏លោហិតដែលឃាំងនៅនោះ គឺ របស់អ្នករាគចរិតជាពណ៌ក្រហម, របស់អ្នកទោសចរិតជាពណ៌ខ្មៅ, របស់អ្នកមោហចរិតជាពណ៌ដូចទឹកលាងសាច់, របស់អ្នកវិតក្កចរិត ជាពណ៌ដូចសណ្តែកខ្មៅ, របស់អ្នកសទ្ធាចរិតជាពណ៌ដូចផ្កាកណ្ណិកា, របស់អ្នកពុទ្ធិចរិតជាពណ៌ថ្លា មិនល្អក់ សបរិសុទ្ធ មានសេចក្តីរុងរឿងដូចជាតិមណីដែលច្នៃហើយដូច្នោះ ។

ហទយវត្ថុនោះ ដែលមហាភូតរូបទាំងឡាយឧបការៈហើយ ដែលអាយុតាមរក្សា ដែលគោចររូបមានពណ៌ជាដើមហែហមហើយ ដែលចិត្តឧតុអាហារឧបត្ថម្ភ រមែងញុំាងភាពជាវត្ថុរបស់មនោធាតុ និងមនោវិញ្ញាណធាតុ និងធម៌ដែលកើតរួមជាមួយនឹងធាតុទាំង ២ នោះ ឱ្យសម្រេចទៅតាមសមគួរ ។

## វិនិច្ឆ័យ ហទយវត្ថុ

មួយទៀត បណ្ឌិតគប្បីជ្រាបសេចក្ដីដែលហទយវត្ថុនោះ សូម្បីមិនបានត្រាស់ក្នុងរូបកណ្ឌ ក៏ឈ្មោះថា **មាន** ដោយអាគម (បករណ៍) និងយុត្តិ ។

ក្នុងអាគម និងយុត្តិនោះ ព្រះបាលីបដ្ឋានថា ៖

**យំ រូបំ និស្សាយ មនោធាតុ ច មនោវិញ្ញាណធាតុ ច បវត្តន្តិ តំ រូបំ មនោធាតុយា មនោវិញ្ញាណធាតុយា ច តំ សម្បយុត្តកានញ្ច ធម្មានំ និស្សយប្បច្ចយេន បច្ចយោ ។**

មនោធាតុក្ដី មនោវិញ្ញាណធាតុក្ដី អាស្រ័យរូបណា ហើយប្រព្រឹត្តទៅ រូបនោះ ជាបច្ច័យនៃមនោធាតុផង នៃមនោវិញ្ញាណធាតុផង នៃពួកធម៌ដែលប្រកបដោយមនោវិញ្ញាណធាតុផង ដោយនិស្សយប្បច្ច័យ ។ ដូច្នេះ ឈ្មោះថា **អាគម** ។

*ក្នុងអភិធម្មត្ថវិភាវិនី* សម្ដែងយុត្តិយ៉ាងនេះ ថា ៖

ធាតុទាំង ២ របស់ពួកកាមាវចរសត្វ និងរូបាវចរសត្វ

ដែលមាននិប្ផន្នរូប និងហទយវត្ថុ ដែលអាស្រ័យភូតរូប ជាទីទទួលវេង ព្រោះភាវៈនៃធាតុទាំងនោះ មានភាវៈជារបស់ជាប់ដោយរូប ដូចចក្ខុវិញ្ញាណជាដើម ធាតុទាំងនោះ មិនអាស្រ័យចក្ខុប្រសាទជាដើម ព្រោះចក្ខុប្រសាទជាដើម ជាទីទទួលវេងធាតុដទៃ មិនអាស្រ័យគោចររូបជាដើម ព្រោះគោចររូបទាំងនោះ ប្រព្រឹត្តទៅខាងក្រៅ មិនអាស្រ័យជីវិតរូប ព្រោះជីវិតរូប ប្រកបក្នុងកិច្ចដទៃ និងមិនអាស្រ័យភាវរូប ២ ព្រោះសូម្បីកាលភាវរូបទាំងពីរនោះមិនមាន ក៏ប្រព្រឹត្តទៅបាន ព្រោះដូច្នោះ ហទយវត្ថុនោះ ទើបជាវត្ថុដទៃ ក្រៅពីប្រសាទរូបជាដើម បណ្ឌិតគប្បីជ្រាបថា ជាឧបាទាយរូបអាស្រ័យមហាភូតរូប ក៏ហទយវត្ថុនេះ ដែលព្រះមហាឥសី មិនបានត្រាស់ទុកក្នុងបាលីធម្មសង្គណី ដោយប្រភេទនៃទេសនាវត្ថុទុកៈ និងអារម្មណ៍ទុកៈ ដូច្នេះ ។

## ពួកទី ៦ : ជីវិតរូប

ជីវិតរូប ឬ ជីវិតិន្ទ្រិយរូប មានវចនត្ថៈថា **ជីវន្តិ សហជាតធម្មា ឯតេនាតិ = ជីវិតំ** : សហជាតធម៌ទាំងឡាយ រមែងរស់នៅដោយរូបនេះ ព្រោះហេតុនោះ រូបនេះ ទើបឈ្មោះថា **ជីវិត** ។

**តទេវ កម្មជរូបបរិបាលនេ អធិបច្ចយោគតោ ឥន្ទ្រិយន្តិ = ជីវិតិន្ទ្រិយំ** ជីវិតនុ៎ះឯង ឈ្មោះថា **ឥន្ទ្រិយ** ព្រោះប្រកបដោយភាពជាធំ ក្នុងការគ្រប់គ្រងកម្មជរូប ព្រោះហេតុនោះ ជីវិតរូបនោះ ទើបឈ្មោះថា **ជីវិតិន្ទ្រិយ** ។

ក៏កម្មជរូបកើតអំពីកម្ម (ចេតនាដែលជាអតីតកាល កម្មជាបច្ច័យឱ្យរូបកើតឡើងហើយ ដើម្បីនឹងឱ្យកម្មជរូបនោះតាំងនៅប្រព្រឹត្តទៅព្រមនឹងសហជាតរូប កម្មនោះ ទើបសាងជីវិតរូបដើម្បីរក្សាកម្មជរូបព្រមទាំងសហជាតរូប ឱ្យប្រព្រឹត្តទៅជរាបដល់អស់អាយុ ។ ចំណែកចិត្តជរូប ឧតុជរូប និងអាហារជរូបទាំង

អស់នោះ មិនមានជីវិតរូបឃុំគ្រងរក្សា ព្រោះចិត្តជរូបជាដើមនេះ មានសមុដ្ឋាន ជាបច្ចុប្បន្ន ដែលជីវិតរូបរក្សាកម្មជរូបឱ្យប្រព្រឹត្តទៅបាននោះ ដូចទឹករក្សាផ្កាឈើក្នុងថូផ្កា ដូច្នោះ ។

## លក្ខណាទិចតុក្កៈរបស់ជីវិតរូប

**១-សហជាតរូបានុបាលនលក្ខណំ** មានការតាមរក្សារូបដែលកើតព្រមគ្នា ជាលក្ខណៈ

**២-តេសំ បវត្តនរសំ** មានការញ៉ាំងរូបទាំងនោះឱ្យប្រព្រឹត្តទៅ ជាកិច្ច

**៣-តេសញ្ញេវ ឋបនបច្ចុប្បដ្ឋានំ** មានការឱ្យរូបទាំងនោះតាំងនៅជាផល

**៤-យាបយិតព្វភូតបទដ្ឋានំ** មានមហាភូតរូប ដែលគប្បីឱ្យប្រព្រឹត្តទៅបាន ជាហេតុជិត ។

## ពួកទី៧ ៖ អាហាររូប

**អាហាររូប** បានដល់ កពឡិង្ការាហារ ( អាហារ គឺ ពំនូត បាយដែលបរិភោគ ) ឬកវឡីការាហារ មានបាយ និងទឹកជាដើម កាលសត្វបរិភោគអាហារចូលទៅហើយ បាចកតេជោ គឺ ធាតុភ្លើង ក៏ធ្វើនាទីរំលាយអាហារ ចម្រាញ់យកតែឱជា ( អាហារដែលល្អិត ) ទៅចិញ្ចឹមរាងកាយ ។

កពឡិង្ការាហារ មានវចនត្ថៈថា **កវឡំ កត្វា អជ្ឈោហរិយតីតិ = កវឡីការោ អាហារោ** ៖ ឈ្មោះថា កវឡីការាហារ ព្រោះអត្ថថា ដែលបុគ្គលធ្វើឱ្យជាពំនូត ហើយបរិភោគ ។

កពឡិង្ការាហារដែលពោលនេះ សំដៅដល់ អាហារទាំងអស់ដែលសត្វបរិភោគ, តែថា ក្នុងទីនេះ ប្រាថ្នាយកចំពោះអាហាររូប គឺ ឱជាដែលមាននៅក្នុងអាហារផ្សេង ៗ ដែលសត្វបរិភោគហើយ ធ្វើការរំលាយល្អហើយ ចិញ្ចឹមរាងកាយនោះ ឱ្យ

ចម្រើន ។

**ឱជា** មានវចនត្ថៈថា **អត្តនោ ឧទយានន្តរំ រូបំ ជនេតីតិ = ឱជា**[១] ឈ្មោះថា ឱជា ព្រោះអត្ថថា ធ្វើឱ្យរូបកើតជាប់តគ្នាទៅដោយសេចក្តីចម្រើនរបស់ខ្លួន ។

ឱជារូប ធ្វើឱ្យរាងកាយរបស់សត្វមានកម្លាំង និងឱ្យចម្រើន ធំធាត់, ចំណែករាងកាយដែលចម្រើនធំធាត់ហើយឱជារូបនេះ ក៏ធ្វើឱ្យកាយបរិបូណ៌ និងមានជីវិតតទៅ ។

## លក្ខណាទិចតុក្កៈរបស់អាហាររូប

១- **ឱជាលក្ខណំ** មានការធ្វើឱ្យរូបចម្រើន ជាលក្ខណៈ

២- **រូបាហរណរសំ** មានការនាំមកនូវរូប ជាកិច្ច

៣- **កាយុបត្ថម្ភនបច្ចុប្បដ្ឋានំ** មានការឧបត្ថម្ភកាយ ជាផល

៤- **អជ្ឈោហរិតព្វបទដ្ឋានំ** មានអាហារដែលគួរបរិភោគ ជា

---

១. ក្នុងអត្ថយោជនា តតិយភាគថា **ឧទ្ធំ អនន្តរំ ជនេតីតិ = ឱជា** ។

ហេតុជិត ។

រូបធម៌ ៧ ពួក តាមដែលពោលមកហើយនេះ ហៅថា សភាវរូប សលក្ខណរូប និប្ផន្នរូប រូបរូប និង សម្មសនរូប កាលបែកចេញមួយពួក ៗ បាន ១៨ រូប គឺ មហាភូតរូប ៤ ប្រសាទរូប ៥ គោចររូប ៤ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ និងអាហាររូប ១ រូបទាំង ១៨ នេះ កាលបែកដោយឋាន គឺ ទីតាំងនៅក្នុងរាងកាយរបស់សត្វ ក៏បែកបានជា ២ ប្រភេទ គឺ ៖

**សព្វដ្ឋានិករូប** រូបដែលតាំងនៅក្នុងកាយទាំងអស់

**បទេសិករូប** រូបដែលតាំងនៅចំពោះក្នុងទីខ្លះ ៗ

បណ្តារូបទាំង ២ ប្រភេទនោះ គឺ ៖

-**សព្វដ្ឋានិករូប** មាន ១២ រូប គឺ មហាភូតរូប ៤ កាយប្រសាទរូប ១ វណ្ណរូប ១ គន្ធរូប ១ រសរូប ១

ភាវរូប ២ ជីវិតរូប ១ និងអាហាររូប ១ ។

**បទេសិករូប** មាន ៦ រូប គឺ ចក្ខុប្រសាទរូប ១ សោតប្រសាទរូប ១ ឃានប្រសាទរូប ១ ជិវ្ហាប្រសាទរូប ១ សទ្ទរូប ១ ហទយរូប ១ ។

មួយទៀត **សទ្ទរូប** អាចារ្យខ្លះពោលថា "ជាសព្វដ្ឋានិក" ដោយប្រាថ្នាយកថា រាងកាយចំណែកណា ប៉ះខ្ទប់វត្ថុ មានរបស់រឹងជាដើម នឹងកើតសំឡេងឮឡើងបាន ទើបលោកពោលថា "សំឡេងជាសព្វដ្ឋានិក" ។ តែក្នុងទីនេះ លោកអាចារ្យអ្នករចនាប្រាថ្នាយកសំឡេងដែលកើតផ្លូវវាចា ទើបបានពោលថា "សំឡេងជាបទេសិករូប" ។

សេចក្ដីថា មតិរបស់អាចារ្យទាំង ២នេះ មិនជំទាស់គ្នា ។

## ពួកទី៨ ៖ បរិច្ឆេទរូប

អាកាសធាតុ ឈ្មោះថា បរិច្ឆេទរូប ។

**អាកាស** មានវិចនត្ថៈថា **ន កស្សតីតិ = អកាសោ អកាសោយេវ អាកាសោ** ទីប្រទេស ឈ្មោះថា **អកាស** ព្រោះអត្ថថា ដែលបុគ្គលធ្វើឱ្យជាស្នាមមិនបាន, អកាសនុ៎ះឯង ឈ្មោះថា **អាកាស** ។

**និជ្ជីវដ្ឋេន ធាតុ ចាតិ = អាកាសធាតុ** និងអាកាសនោះ ឈ្មោះថា ធាតុ ព្រោះអត្ថថា មិនមែនជីវិត ព្រោះហេតុនោះ ទើបឈ្មោះថា **អាកាសធាតុ** ។

បណ្តាសព្វវត្ថុ ( រូបធម៌ ) ទាំងឡាយ ដែលមានចិត្តគ្រប់គ្រងក្តី មិនមានចិត្តគ្រប់គ្រងក្តី បើមិនមានអាកាសធាតុ ( ចន្លោះទទេ ) ឃាំងហើយ វត្ថុនោះ ៗ ក៏នឹងប្រាកដជាប់គ្នា ជាផ្ទាំងទៅអស់ និងមិនអាចកំណត់ចំនួន ចំណែក ភាគ រូប សណ្ឋាន និង

រាប់បាន ដូច្នេះ រូប គឺ អាកាសធាតុដែលជាគ្រឿងកំណត់រូបដែលមានក្នុងកលាបផ្សេង ៗនោះ រមែងធ្វើឱ្យរូបក្នុងកលាបនោះប្រាកដបាន ដូច្នេះ រូបក្នុងចក្ខុទសកកលាបជាដើម ដោយជារូបតែមួយ ៗ មិនលាយគ្នា នេះឈ្មោះថា បរិច្ឆេទរូប (ឬហៅថា បរិច្ឆេទាកាស) ។

## អាកាស ៤ យ៉ាង

**១-អជដាកាស** អាកាសមិនស្ទុក

**២-បរិច្ឆិន្នាកាស** អាកាសដែលកំណត់

**៣-កសិណុគ្ឃាដិមាកាស** អាកាសដែលបើករូបកសិណចេញហើយ

**៤-បរិច្ឆេទាកាស** អាកាស គឺ ចន្លោះទទេ រវាងរូប

បណ្ដាអាកាសទាំង ៤ នោះ គឺ **អជដាកាស** បានដល់អាកាសដែលមិនស្ទុក ត្រឹមតែជាចន្លោះ ទទេ ។ សូម្បីពាក្យថា

**តុច្ឆាកាស** ( អាកាសដែលទទេ ) ក៏ជាឈ្មោះរបស់អជដាកាសនុ៎ះឯង ។

ក៏អាកាសនេះ មានទាំងខាងក្រោម និងខាងលើ ។ ខាងក្រោម មានតាំងអំពីខាងក្រោមខ្យល់ដែលទ្រទឹកចុះទៅ; ខាងលើមានតាំងអំពីអរូបព្រហ្មឡើងទៅ ។

**បរិច្ឆិន្នាកាស** បានដល់ ចន្លោះទទេ ដែលកំណត់ខេត្តដែនដូចអាកាសដែលជាប្រហោង មានផ្ទៃមេឃ ប្រឡោះបង្អួចប្រហោងមាត់ បំពង់ក រន្ធច្រមុះ និងរន្ធត្រចៀក ។

**កសិណុគ្ឃាដិមាកាស** បានដល់ ចន្លោះទទេនៃរូបកសិណដែលព្រះយោគាវចរបើកចេញហើយ ។

**បរិច្ឆេទាកាស** បានដល់ ប្រហោងទទេ ដែលឃាំងរវាងរូបនិងរូប ឬរូបកលាបនិងរូបកលាប ។

ក្នុងគម្ពីរកថាវត្ថុ លោកពោលអាកាសទុកតែ៣យ៉ាង ។

## លក្ខណាទិចតុក្កៈរបស់បរិច្ឆេទរូប

**១-រូបបរិច្ឆេទលក្ខណំ** មានការកំណត់នូវរូប ជាលក្ខណៈ

**២-រូបបរិយន្តប្បកាសនរសំ** មានការប្រកាសទីបំផុតរបស់រូប ជាកិច្ច

**៣-រូបបរិយាទបច្ចុប្បដ្ឋានំ** មានខេត្តដែនរបស់រូប ជាផល

**អសម្ផុដ្ឋភាវឆិទ្ទវិវរភាវបច្ចុប្បដ្ឋានំ វា** ឬមានមហាភូតរូបមិនពាល់ត្រូវ គឺ ជាប្រហោង និងជារន្ធ ជាផល

**៤-បរិច្ឆិន្នរូបបទដ្ឋានំ** មានរូបដែលអាកាសឃាំងទុកជាហេតុជិត ។

គឺ កាលជាដូច្នេះ ទើបកំណត់បានថា ខាងលើ មានត្រឹមនេះ ខាងក្រោម ខាងស្តាំ ខាងឆ្វេង មានត្រឹមនេះ ។

## ពួកទី ៩ : វិញ្ញត្តិរូប ២

វិញ្ញត្តិរូប ២ គឺ កាយវិញ្ញត្តិរូប ១ និងវចីវិញ្ញត្តិរូប ១, រូប ២ នេះ ជាវិការៈរបស់និប្ផន្នរូប ដែលមានចិត្តជាសមុដ្ឋានធ្វើឱ្យកាយ និងវាចាកម្រើកញ័រ ។

* ក៏បុថុជ្ជន ព្រះសេក្ខបុគ្គល និងអសេក្ខបុគ្គល រមែងឱ្យវិញ្ញត្តិរូបទាំង ២ កើតដោយចិត្ត ៣២ គឺ កាមាវចរកុសលចិត្ត ៨ អភិញ្ញាចិត្ត ២ អកុសលចិត្ត ១២ មហាកិរិយាចិត្ត ៨ បរិត្តកិរិយាចិត្ត ២ ។

### ១-កាយវិញ្ញត្តិ

**កាយវិញ្ញត្តិ** មានវចនត្ថៈថា **ចលមានកាយេន អធិប្បាយំ វិញ្ញាបេតិ សយញ្ច តេន វិញ្ញាយតីតិ = កាយវិញ្ញត្តិ :** ធម្មជាតិណា រមែងញ៉ាំងអ្នកដទៃ ឱ្យដឹងសេចក្តីប្រាថ្នា ដោយកាយដែលកម្រើកញ័រ និងខ្លួនឯងក៏ដឹងសេចក្តីប្រាថ្នា ដោយកាយដែលកម្រើកញ័រនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា កាយ

វិញ្ញត្តិ ។

## លក្ខណាទិចតុក្កៈរបស់កាយវិញ្ញត្តិរូប

១- **វិញ្ញាបនលក្ខណំ** មានការធ្វើឱ្យដឹង ជាលក្ខណៈ

២- **អធិប្បាយបកាសនរសំ** មានការប្រកាសនូវបំណងប្រាថ្នា ជាកិច្ច

៣- **កាយវិប្ផន្ទនហេតុភាវបច្ចុប្បដ្ឋានំ** មានហេតុនៃការកម្រើកញ័រកាយ ជាផល

៤- **ចិត្តសមុដ្ឋានវាយោធាតុបទដ្ឋានំ** មានវាយោធាតុតាំងឡើងអំពីចិត្ត ជាហេតុជិត ។

<u>**ក្នុងអដ្ឋសាលិនី**</u> អធិប្បាយពាក្យ "លក្ខណៈ" ថា ព្រះមានព្រះភាគទ្រង់សម្តែងសភាវលក្ខណៈទុក ៦ បទ (សង្គណី) មានពាក្យថា តឹង កិរិយាដែលតឹងដោយល្អជាដើម ។ និងសម្តែងបច្ចុប្បដ្ឋាន គឺ ផល ទុក ៦ បទ មានពាក្យថា ឈានទៅខាងមុខ ការថយក្រោយជាដើម ។

ពិតមែន ចិត្តកាលកើតឡើងថា យើងនឹងឈានទៅខាងមុខជាដើម រមែងញ៉ាំងរូបឱ្យតាំងឡើង ៨ រូប (គឺ អវិនិព្ភោគរូប៨) ក្នុងខណៈនៃចិត្ត ដែលកើតឡើងនោះ វាយោធាតុ មានចិត្តជាសមុដ្ឋាន ក្នុងខាងក្នុងរូបកលាបទាំង ៨ រូបនោះ រមែងឧបត្ថម្ភ ទ្រទ្រង់ទុកញ៉ាំងរូបកាយ ដែលកើតព្រមជាមួយខ្លួននោះ ឱ្យកម្រើកញ័រ ឱ្យឈានទៅខាងមុខ និងឱ្យថយត្រឡប់ជាដើម ។

ក្នុងរូបកលាបទាំង ៨ នោះ វាយោធាតុដែលតាំងឡើងដោយចិត្តជំបូង ក្នុងបណ្ដាជវនចិត្ត ៧ ក្នុងអាវជ្ជនវិថីមួយ រមែងអាចឧបត្ថម្ភតម្រង់ទុកនូវរូបកាយ ដែលកើតជាមួយខ្លួន តែមិនអាចឱ្យរូបកាយកម្រើកញ័រ សូម្បីក្នុងជវនចិត្តទី ២-៦ ក៏ន័យនេះដូចគ្នា, ចំណែកវាយោធាតុដែលតាំងឡើងដោយជវនចិត្តទី ៧ បានវាយោធាតុដែលតាំងឡើងដោយជវនចិត្តទាំង ៦ ខាងដើមជាបច្ច័យឧបត្ថម្ភហើយ រមែងអាចជួយទ្រទ្រង់ទុក ដើម្បីញ៉ាំងរូបដែលកើតជាមួយខ្លួនឱ្យកម្រើកញ័រ មានការឱ្យឈានទៅមុខ ឱ្យ

ថយត្រឡប់ជាដើម ព្រោះហេតុនោះ ទើបឈ្មោះថា ការដើរទៅ ការដើរមក ឈ្មោះថា ការដើរទៅមកនេះ ប្រៀបដូចរទេះដែលគប្បីអូសទៅដោយទឹម ៧ ដូច្នេះ ។

## ២-វចីវិញ្ញត្តិរូប

***វចីវិញ្ញត្តិរូប*** បានដល់ ការបញ្ចេញវាចា ឱ្យអ្នកដទៃដឹងនូវសេចក្តី ដូចការហៅឈ្មោះ និងការសន្ទនាជាដើម ឬការបញ្ចេញវាចាធម្មតា ដូចបញ្ចេញសំឡេងឧទាន សំឡេងច្រៀងស្រាលតិច ៗ និងការអានសៀវភៅជាដើម ។

*វចីវិញ្ញត្តិ មានវចនត្ថៈថា* ***សវិញ្ញាណកសទ្ទសង្ខាតវាចាយ អធិប្បាយំ វិញ្ញាបេតិ សយញ្ច តាយ វិញ្ញាយតីតិ = វចីវិញ្ញត្តិ*** *ឈ្មោះថា* ***វចីវិញ្ញត្តិ*** *ព្រោះអត្ថថា ញុំាងអ្នកដទៃ ឱ្យដឹងសេចក្តីប្រាថ្នា ដោយវាចាពោល គឺ សំឡេងដែលប្រព្រឹត្តទៅដោយវិញ្ញាណ និងខ្លួនឯងក៏ដឹងដោយវាចានោះ ។*

## លក្ខណាទិចតុក្កៈរបស់វចីវិញ្ញត្តិរូប

១- **វិញ្ញាបនលក្ខណំ** មានការធ្វើឱ្យដឹងសេចក្ដីប្រាថ្នា ជាលក្ខណៈ

២- **អធិប្បាយបកាសនរសំ** មានការប្រកាសបំណងប្រាថ្នា ជាកិច្ច

៣- **វចីឃោសហេតុភាវបច្ចុប្បដ្ឋានំ** មានហេតុ គឺ សំឡេងលាន់ឮ ជាផល

៤- **ចិត្តសមុដ្ឋានបឋវីធាតុបទដ្ឋានំ** មានបឋវីធាតុតាំងឡើងអំពីចិត្ត ជាហេតុជិត ។

បណ្ដាអត្ថ ៤ មានលក្ខណៈជាដើមនោះ

ពាក្យថា **បច្ចុប្បដ្ឋានំ** ប្រែថា ជាផលនោះ គឺ

កាលចិត្តកើតឡើងថា "យើងនឹងពោលពាក្យនេះ ៗ" ដូច្នេះ រមែងញ៉ាំងរូប (អវិនិព្ភោគរូប ៨) គឺ បឋវីធាតុអាបោធាតុ តេជោធាតុ វាយោធាតុ វណ្ណៈ គន្ធៈ រសៈ និងឱជាឱ្យតាំងឡើង ៗ បឋវីធាតុដែលមានចិត្តជាសមុដ្ឋាន ក្នុងខាងក្នុងនៃរូបកលាបទាំង ៨ នោះឯង ប៉ះខ្ទប់នូវឧបាទិន្នរូបសំឡេង ទើបកើត

ឡើង ព្រោះការប៉ះខ្ទប់នោះ នេះឈ្មោះថា សំឡេងមានចិត្តជាសមុដ្ឋាន មិនមែនវិញ្ញត្តិ តែវិការៈមួយនៃបឋវីធាតុដែលមានចិត្តគិត ថ្លែងចេញនូវពាក្យជាសមុដ្ឋាន ជាបច្ច័យឱ្យប៉ះខ្ទប់ជាមួយឧបាទិន្នរូប ដែលប្រព្រឹត្តទៅក្នុងឋានកើតនៃអក្សរ ។

ឈ្មោះថា **វចីវិញ្ញត្តិ** ។ ពាក្យដែលនៅសល់ គប្បីជ្រាបដោយន័យដែលពោលទុកក្នុងរឿងកាយ **វិញ្ញត្តិ** នុ៎ះឯង ។

<u>ក្នុងអភិធម្មត្ថវិភាវិនី</u> ពោលនូវវចីវិញ្ញត្តិ ដែលផ្សេងអំពីកាយវិញ្ញត្តិ ទុកថា ៖

**វចីវិញ្ញត្តិរូប** រមែងមិនបានន័យ (ដូចកាយវិញ្ញត្តិដែល) មានពាក្យជាដើមថា "តាំងឡើងដោយជវនចិត្តទី ៧"ជាដើមទេ ព្រោះមិនមានកិច្ច គឺ ការជួយគាំទ្រជាដើម ដែលជាកិច្ចរបស់វាយោធាតុ ដែលត្រូវធ្វើមុនឡើយ, ព្រោះសំឡេង រមែងកើតព្រមជាមួយការប៉ះខ្ទប់របស់បឋវីធាតុ និងឧបាទិន្នរូបប៉ុណ្ណោះ និងការប៉ះខ្ទប់ រមែងមានបាន សូម្បីក្នុងបឋមជវនចិត្តជាដើម ។

# ពួកទី១០ : វិការរូប ៣

**វិការរូប ៣ គឺ ១- រូបលហុតា** ភាពស្រាលនៃរូប

**២- រូបមុទុតា** ភាពទន់នៃរូប

**៣- រូបកម្មញ្ញតា** ភាពគួរដល់ការងារនៃរូប ។

**វិការ** មានវិចនត្ថៈថា **វិសេសោ អាការោ = វិការោ** : អាការវិសេសរបស់និប្ផន្នរូប ឈ្មោះថា វិការៈ ។

**វិការរូប ៣** មានវិចនត្ថៈថា ៖

**១-លហុភាវោ = លហុតា** ប្រែថា ភាពស្រាល ឈ្មោះថា **លហុតា** ។ **រូបស្ស លហុតា = រូបលហុតា** : ភាពស្រាលរបស់និប្ផន្នរូប ឈ្មោះថា **រូបលហុតា** ។

**២-មុទុភាវោ = មុទុតា** ភាពទន់ ឈ្មោះថា **មុទុតា** ។ **រូបស្ស មុទុតា = រូបមុទុតា** ភាពទន់របស់និប្ផន្នរូប ឈ្មោះថា **រូបមុទុតា** ។

**៣-កម្មនិ សាធុ = កម្មញ្ញំ** ភាពល្អក្នុងការងារ ឈ្មោះថា

**កម្មញ្ញ** ។ **កម្មញ្ញភាវោ** = **កម្មញ្ញតា** ភាវៈនៃការងារដែលល្អ ឈ្មោះថា **កម្មញ្ញតា** បានដល់ រូបដែលមានភាពគួរដល់ការងារ ។

បណ្ដារូបទាំង ៣ ពួកនោះ រូបលហុតា គឺ ភាពមិនធ្ងន់នៃនិប្ផន្នរូប ប្រៀបដូចអ្នកដែលមិនមានរោគបៀតបៀន ។

រូបមុទុតា គឺ ភាពមិនរឹងនៃនិប្ផន្នរូប ដូចស្បែកសត្វដែលជម្រះល្អហើយ ។

រូបកម្មញ្ញតា គឺ ភាពសមគួរនៃនិប្ផន្នរូប សមគួរដល់ការធ្វើការងារផ្សេង ៗ ដូចមាសដែលគេរំលាយល្អហើយ សមគួរដល់ការធ្វើគ្រឿងប្រដាប់ផ្សេង ៗ ដូច្នោះ ។

មួយទៀត រូបទាំង ៣ នេះ រមែងកើតជាមួយវត្ថុមានជីវិតប៉ុណ្ណោះ និងមិនប្រាសចាកអំពីគ្នា តែថា មានសេចក្ដីផ្សេងគ្នា ដោយរូបដែលមានច្រើនក្រៃលែង ដោយវិការនោះ ៗ ។

## លក្ខណាទិចតុក្កៈរបស់លហុតារូប

**១- អទន្ធតា លក្ខណា** មានការមិនយឺត ជាលក្ខណៈ

**២- រូបានំ គរុភាវវិនោទនរសា** មានការបន្ទោបង់ភាពធ្ងន់នៃរូប ជាកិច្ច

**៣- លហុបរិវត្តា បច្ចុប្បដ្ឋានា** មានការផ្លាស់ប្តូរ( កម្រើកបាន ) រហ័ស ជាផល

**៤- លហុរូបបទដ្ឋានា** មានរូបស្រាល ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់រូបមុទុតា

**១-អថទ្ធតា លក្ខណា** មានការមិនរឹង ជាលក្ខណៈ

**២-រូបានំ ថទ្ធភាវវិនោទនរសា** មានការបន្ទោបង់ភាពរឹងនៃរូប ជាកិច្ច

**៣-សព្វកិរិយាសុ អវិធិតា បច្ចុប្បដ្ឋានា** មានការមិនជំទាស់គ្នា ក្នុងការធ្វើកិច្ចទាំងពួង ជាផល

**៤- មុទុរូបបទដ្ឋានា** មានរូបទន់ ជាហេតុជិត ។

## លក្ខណាទិចតុក្កៈរបស់កម្មញ្ញតា

១- **កម្មញ្ញភាវលក្ខណា** មានការគួរដល់ការងារ ជាលក្ខណៈ

២- **អកម្មញ្ញភាវវិនោទនរសា** មានការកំចាត់នូវភាពមិនគួរដល់ការងារ ជាកិច្ច

៣- **អទុព្វលភាវបច្ចុប្បដ្ឋានា** មានភាពមិនទុព្វល ជាផល

៤- **កម្មញ្ញរូបបទដ្ឋានា** មាននិប្ផន្នរូបដែលគួរដល់ការងារ ជាហេតុជិត ។

## ពួកទី ១១ : លក្ខណរូប ៤

លក្ខណៈរបស់និប្ផន្នរូប មាន ៤ គឺ

**១-ឧបចយរូប** គឺ រូបសន្សំដែលកើតគ្រាដំបូង **២-សន្តតិរូប** គឺ រូបដែលកើតបន្ត **៣-ជរតារូប** គឺ រូបដែលជរា

**៤-អនិច្ចតារូប** គឺ រូបដែលរលត់

លក្ខណរូបទាំង ៤ នេះ ជាគ្រឿងកំណត់វិនិច្ឆ័យ ឱ្យជ្រាបបានដល់ធម៌ដែលជាសង្ខតៈ និងអសង្ខតៈ គឺថា រូបធម៌

ណា មានខណៈ ៣ មានឧប្បាទក្ខណៈជាដើម និងមាន សាមញ្ញលក្ខណៈ ៣ មានអនិច្ចលក្ខណជាដើម ធម៌ទាំងអស់នោះ ក៏ជាសង្ខតធម៌ តែបើបរមត្ថធម៌ណា មិនប្រកបដោយលក្ខណៈ តាមដែលពោលហើយនោះ ធម៌នោះ ក៏ជាអសង្ខតធម៌ ។

**លក្ខណៈ** មានវចនត្ថៈថា **លក្ខីយន្តិ វិនិច្ឆយន្តិ ធម្មា ឥមេ សង្ខតាតិ ឯតេនាតិ = លក្ខណំ** ធម៌ទាំងឡាយ ដែលបណ្ឌិត តែងកំណត់វិនិច្ឆ័យបានថា ធម៌ទាំងនេះជាសង្ខតៈ (ឬអសង្ខត) ដោយរូបនេះ ព្រោះហេតុនោះ រូបដែលកំណត់វិនិច្ឆ័យបាននោះ ទើបឈ្មោះថា លក្ខណៈ បានដល់ លក្ខណៈ ៤ របស់ និប្ផន្នរូប ។

<u>ក្នុងអភិធម្មត្ថវិភាវិនី</u> ពោលថា **លក្ខណរូបន្នាម ធម្មានំ តំ តំ អវត្ថានវិសេស លក្ខណហេតុត្តា** ឈ្មោះថា លក្ខណរូប ព្រោះហេតុដែលឱ្យកំណត់ធម៌ទាំងឡាយ បានដោយអំណាចនៃ ការតាំងចុះនូវធម៌នោះ ៗ ។

## ១.ឧបចយរូប

បណ្ដាលក្ខណរូបទាំង ៤ នោះ ឧបចយរូប បានដល់រូបដែលកកើតឡើងគ្រាដំបូងរបស់កម្មជរូបក្នុងបដិសន្ធិកាល

**ឧបចយរូប** មានវចនត្ថៈថា **អាទិតោ ឧបរិតោ ច ចយោតិ = ឧបច្ចយោ** ការកើតឡើងដំបូង និងក្រោយ ៗរបស់និប្ផន្នរូប ឈ្មោះថា ឧបចយ ។

បដិសន្ធិខណៈ របស់គព្ភសេយ្យកសត្វទាំងឡាយនោះ កម្មជរូបដែលកើតឡើងគ្រាដំបូង ឈ្មោះថា ឧបចយៈ[១] តអំពីបដិសន្ធិខណៈទៅ ជាឧបចយៈដែលកើតឡើងគ្រាក្រោយ ព្រោះការកើតឡើងនៃកម្មជរូបនោះ នៅមិនទាន់គ្រប់ ដែលកើតជាប់តគ្នាទៅ រហូតដល់ ១១ សប្ដាហ៍ ទើបមានកម្មជរូបទាំងឡាយ

---

១. ក្នុងអភិធម្មត្ថវិភាវិនី ពោលថា ជាតិរូប(ឧបចយៈនិងសន្ដតិរូប) និងអនិច្ចតារូប មានអាយុ ប៉ុននឹងឧប្បាទក្ខណៈ និងភង្គខណៈរបស់ចិត្ត តែជរតារូបមានអាយុប៉ុននឹងឋិតិខណៈ ៤៩ ។

មានចក្ខុទសកកលាបជាដើម កើតឡើងគ្រប់ ការកើតឡើងរបស់កម្មជរូប ផ្នែកក្រោយនេះ ក៏ឈ្មោះថា ឧបចយរូបដែរ ។

ចំណែកសត្វដែលជាសំសេទជកំណើត និងឧបបាតិកកំណើត មានកម្មជរូប ដែលជាឧបចយកើតឡើងចំពោះក្នុងបដិសន្ធិខណៈប៉ុណ្ណោះ មិនកើតក្នុងបវត្តិកាល ព្រោះកម្មជរូបទាំងឡាយ កើតបរិបូណ៌ហើយ ក្នុងបដិសន្ធិខណៈ ។

## លក្ខណាទិចតុក្កៈរបស់រូបឧបចយៈ

**១-អាចយលក្ខណោ** មានការកើតគ្រាដំបូង ជាលក្ខណៈ

**២-បុព្វន្តតោរូបានំ ឧម្មុជ្ជាបនរសោ** មានការធ្វើរូបទាំងឡាយឱ្យកើតឡើងតាំងអំពីខាងដើម ជាកិច្ច

**៣-និយាតនបច្ចុប្បដ្ឋានោ បរិបុណ្ណភាវបច្ចុប្បដ្ឋានោ វា** មានការប្រគល់ឱ្យ ជាផល ឬមានសេចក្តីដែលរូបទាំងឡាយបរិបូណ៌ហើយ ជាផល

**៤-ឧបចិតរូបបទដ្ឋានោ** មានរូបកើតអំពីកម្មដែលសន្សំហើយ

ជាហេតុជិត ។

## ២. សន្តតិរូប

បណ្តាលក្ខណរូបទាំង ៤ នោះ សន្តតិរូប បានដល់ កម្មជរូប ដែលកើតបន្តអំពីឧបចយរូប ។

**សន្តតិ** មានវចនត្ថៈថា **សំ បុនប្បុនំ តតិ = សន្តតិ** ការកើតព្រម គឺរឿយ ៗ របស់និប្ផន្នរូប ឈ្មោះថា **សន្តតិ** ។ម្យ៉ាងទៀត **សម្ពន្ធា តតិ = សន្តតិ** ការកើតឡើង គឺ ការបន្តរបស់និប្ផន្នរូប ឈ្មោះថា **សន្តតិ** ។

<u>ក្នុងអដ្ឋសាលិនី</u> និង<u>គម្ពីរវិសុទ្ធិមគ្គ</u> បានប្រៀបធៀបឧបចយរូប និងសន្តតិរូបទុកថា ៖

ដូចអ្នកជីកអណ្តូងជិត ៗទន្លេ ជីកហើយ ទឹកក៏ហូរចូលមកក្នុងគ្រាដំបូង តអំពីនោះ ក៏ហូរចូលមករហូតដល់ពេញនេះ ប្រៀបដូចនឹងឧបចយរូប ដែលកកើតដំបូងក្នុងបដិសន្ធិខណៈ ហើយនឹងកើតជាប់តគ្នាទៅ រហូតអវយវៈបរិបូណ៌ ។

កាលទឹកពេញអណ្ដូងហើយ ក៏ហូរចេញអំពីអណ្ដូងទៅតាមផ្ទៃដី នេះ ប្រៀបដូចនឹងសន្តតិរូប គឺ រូបដែលកើតជាប់តគ្នាទៅរហូតដល់អស់អាយុ ។

## លក្ខណាទិចតុក្កៈរបស់រូបសន្តតិ

**១-បវត្តិលក្ខណា** មានបវត្តិ គឺមានសេចក្ដីចម្រើន ជាលក្ខណៈ

**២-អនុបពន្ធនរសា** មានការបន្តគ្នាដោយលំដាប់ ជាកិច្ច

**៣-អនុប្បច្ឆេទបច្ចុប្បដ្ឋានា** មានការមិនដាច់អំពីគ្នា ជាផល

**៤-អនុពន្ធនរូបបទដ្ឋានា** មានរូបដែលនៅបន្តគ្នាបាន ជាហេតុជិត ។

ឧបចយរូប និងសន្តតិរូបទាំង ២ នេះ ជាឈ្មោះរបស់ជាតិរូប ( រូបដែលកើត ) ដូចគ្នា ។

ដូច្នេះ ក្នុងបទភាជនី... ព្រះមានព្រះភាគ ទើបទ្រង់ត្រាស់ថា **"យោ រូបស្ស ឧបចយោ សោ រូបស្ស សន្តតិ** : យ៉ាងណា ជាឧបចយរូប យ៉ាងនោះ ជាសន្តតិរូប" គឺ ដូចគ្នាដោយអត្ថ តែ

ដែលទ្រង់លើកឡើងសម្តែងទុកទាំង ២ យ៉ាងនេះ ព្រោះសេចក្តីផ្សេងគ្នានៃអាហារ ។

## ៣_ជរតារូប

បណ្តាលក្ខណរូបទាំង ៤ នោះ **ជរតារូប** បានដល់ រូបដែលជរា គឺ ការចាស់របស់និប្ផន្នរូប ។

**ជរតា** មានវចនត្ថៈថា **យថាសកំ ខណមត្តដ្ឋាយីនំ រូបានំ និរោធា-ភិមុខភាវវសេន ជិរណំ = ជរា. សាយេវ ជរតា** ការចាស់នៃរូបទាំងឡាយ ដែលមានប្រក្រតីតាំងនៅមួយខណៈ ៗ របស់ខ្លួន ដោយអំណាចនៃភាពជាធម៌ បែរមុខទៅរកសេចក្តីរលត់ ឈ្មោះថា ជរា, ជរានុ៎ះឯង ឈ្មោះថា **ជរតា** ។

### លក្ខណាទិចតុក្កៈរបស់រូបជរតា

១_ **រូបបរិបាកលក្ខណា** មានការទុំជោរនៃរូប ជាលក្ខណៈ

២- **ឧបនយនរសា** មានការបង្អោនទៅជិតសេចក្ដីស្លាប់ ជាកិច្ច

៣- **សភាវានបគមេបច្ចុ នវភាវាបគមនច្ចុបដ្ឋានា វីហិបុរាណភាវេវ វិយ** មានការប្រាសចាកភាពជារបស់ថ្មី សូម្បីភាវៈរបស់ខ្លួននៅមិនប្រាកដទៅក៏ដោយ ជាផល ដូចសភាពជារបស់ចាស់នៃសំបកស្រូវ ដូច្នោះ

៤- **បរិបច្ចមានរូបបទដ្ឋានា** មានរូបដែលកំពុងចាស់ទ្រុឌទ្រោម ជាហេតុជិត ។

បណ្ដាចតុជនិប្ផន្នរូប គឺ ៖

សភាវរូបដែលកើតអំពីសមុដ្ឋាន ៤ មានកម្មជាដើម មានអាយុ ៥១ ខណៈតូចរបស់ចិត្ត គឺ កើតឡើង ១ ខណៈ រលត់ទៅ ១ ខណៈ ចំណែកខណៈ ដែលតាំងនៅមានដល់ ៤៩ ខណៈរបស់ចិត្ត ។ ក្នុងខណៈដែលនិប្ផន្នរូបតាំងនៅ ៤៩ ខណៈនោះ ហៅថា ជរតារូប ឬហៅថា ឋិតិខណៈរូប ជរារូប ។

## ជរតា ឬជរា ២ យ៉ាង

១ **អវីចិជរា** ជរាដែលមិនមានប្រាកដ ឬ **បដិច្ឆន្នជរា** ជរាដែលបិទបាំង

២ **សវីចិជរា** ជរាដែលមានប្រាកដ ឬ **អប្បដិច្ឆន្នជរា** ជរាដែលមិនបិទបាំង

បណ្ដាជរាទាំង ២ នោះ អវីចិជរា ជាជរាដែលដឹងបានដោយលំបាក ព្រោះជាជរាមិនមានប្រាកដក្នុងរវាងអនុបាទិន្នសង្ខារយ៉ាងណា ដូចកែវមណី មាស ព្រះចន្ទ និងព្រះអាទិត្យជាដើម ជរាទាំងនោះ នឹងប្រាកដជាក់ ក្នុងវេលាដែលកប្បវិនាស សូម្បីជរារបស់សត្វមានជីវិតទាំងឡាយ ក្នុងវេលាដែលនៅជាមន្ទទសក (១០ ឆ្នាំនៃភាពទន់ខ្វី)ជាដើម និងជរារបស់វត្ថុដែលមិនមានជីវិតទាំងឡាយ មានពន្លកដើមឈើ ផ្កាឈើ និងផ្លែជាដើម ក៏ជាជរាដែលដឹងបានលំបាកទុំះឯង ។

សវីចិជរា ជាជរាដែលដឹងបានងាយ ព្រោះមានអាការ

ប្រាកដជាក់ច្បាស់ មានសក់ស្កូវ និងធ្មេញបាក់ជាដើម ព្រោះសេចក្ដីពិការនៃពណ៌ជាដើម ។

## ៤-អនិច្ចតារូប

បណ្ដាលក្ខណរូបទាំង ៤ នោះ អនិច្ចតារូប បានដល់ រូបដែលកំពុងបែកធ្លាយ ។

**អនិច្ចតា** មានវចនត្ថៈថា **និច្ចធុវសភាវេន ន ឥច្ចំ អនុបគន្តព្វន្តិ = អនិច្ចំ. តស្ស ភាវោ អនិច្ចតា** រូប ដែលឈ្មោះថា អនិច្ច ព្រោះអត្ថថា ដែលបុគ្គលមិនគប្បីដល់ គឺ មិនគប្បីចូលដល់សភាពទៀង និងយឺនយូរ ។ ភាវៈនៃរូបដែលមិនទៀងជាដើមនោះ ឈ្មោះថា អនិច្ចតា ។ ( អភិធម្មត្ថវិភាវិនី )

### លក្ខណាទិចតុក្កៈរបស់រូបអនិច្ចតា

**១-បរិភេទលក្ខណា** មានការបែកធ្លាយ ជាលក្ខណៈ

២- **សំសីទនរសា** មានការលិចចុះ ជាកិច្ច

៣-**ខយវយបច្ចុប្បដ្ឋានា** មានការអស់ទៅ វិនាសទៅ ជាផល

៤-**បរិភិជ្ជមានរូបបទដ្ឋានា** មានរូបកំពុងបែកធ្លាយ ជាហេតុជិត ។

លក្ខណៈ ៤ ក៏គឺ ជាតិ ជរា និងមរណៈនុំះឯង

**ក្នុងអភិធម្ម** សម្តែងជាតិ ជរា មរណៈ ដោយបរមត្ថសច្ចៈ កាលសម្តែងដោយសម្មតិសច្ចៈ ក៏បានដល់ សត្វដែលប្រសូតចាកគភ៌របស់មាតា ហៅថា **ជាតិ** ។ ខណៈដែលសត្វនោះអស់ជីវិត ហៅថា **មរណៈ** ។ ក្នុងរវាងជាតិ និងមរណៈហៅថា ជរា ។ ជាតិ ជរា និងមរណៈទាំង ៣ នេះ បណ្ឌិតគប្បីឃើញដូចសត្រូវ ៣ នាក់ ដេញតាមបៀតបៀនជានិច្ចចុះ ។

**ចប់ រូបន័យទី ១ រូបសមុទ្ទេស**

# រូបន័យទី ២ រូបវិភាគ

រូបវិភាគន័យ ជាន័យដែលសម្ដែងរូប ២៨ ដោយពិស្ដារ គឺ បែករូបទាំងអស់ទុកជាពួក ៗ មិនឱ្យច្របូកច្របល់ ។

<u>ក្នុងសង្គណី</u> ហៅថា មាតិកា តាំងអំពីឯកមាតិកា រហូតដល់ឯកាទសក ( ទី ១ → ទី១១ )

ក្នុងទីនេះ សម្ដែងត្រឹមតែ ២ មាតិកា គឺ មាតិកាទី ១ និងទី ២ ដោយហៅតាមឈ្មោះ អភិធម្មត្ថវិភាវិនីថា "ឯកវិធន័យ" ( ន័យដែលសម្ដែងរូបមានអត្ថតែមួយ ) និងទុកន័យ ( គឺ ន័យដែលសម្ដែងរូបផ្សេងគ្នា ជាពីរពួក )

## ឯកវិធន័យ

រូបទាំងអស់ ២៨ មានឈ្មោះ ៨ យ៉ាង

-ឈ្មោះថា **អហេតុកៈ** ព្រោះមិនមានអលោភហេតុជាដើមមកសម្បយុត្ត

-ឈ្មោះថា **សប្បច្ចយៈ** ព្រោះមានកម្មជាដើមជាបច្ច័យ
-ឈ្មោះថា **សាសវៈ** ព្រោះប្រព្រឹត្តទៅជាមួយកាមាសវៈជាដើម ដែលប្រារព្ធខ្លួនប្រព្រឹត្តទៅ
-ឈ្មោះថា **សង្ខតៈ** ព្រោះមានកម្មជាដើមតាក់តែង
-ឈ្មោះថា **លោកិយៈ** ព្រោះជាធម៌សង្គ្រោះចូលក្នុងសង្ខារលោកនៃឧបាទានក្ខន្ធ
-ឈ្មោះថា **កាមាវចរៈ** ព្រោះជាទីត្រាច់ទៅនៃកាមតណ្ហា
-ឈ្មោះថា **អនារម្មណៈ** ព្រោះអត្ថថា មិនដឹងអារម្មណ៍
-ឈ្មោះថា **អប្បហាតព្វៈ** ព្រោះមិនមែនជាធម៌ត្រូវលះដោយតទង្គប្បហានជាដើម ។

## អធិប្បាយ

ឈ្មោះថា **អហេតុកៈ** ព្រោះមិនមានហេតុយ៉ាងណាមួយក្នុងហេតុ ៦ មានអលោភហេតុជាដើម មកសម្បយុត្ត (បានការកើតព្រមគ្នាជាដើម ព្រោះដូច្នោះ រូបទាំងអស់ ទើបបានន័យមួយ

គឺ ន័យដែលជាអហេតុក មិនបានន័យ ដែលជាសហេតុក ។

ឈ្មោះថា **សប្បច្ចយៈ** ព្រោះរូបមានបច្ច័យ គឺ មានកម្ម ចិត្ត ឧតុ និងអាហារ ជាសមុដ្ឋាន ទើបកើតឡើង រូបដែលមិនមានបច្ច័យឱ្យកើតឡើង មិនមាន, ព្រោះដូច្នោះ ទើបបានន័យដែលជាសប្បច្ចយតែមួយ មិនបានន័យដែលជាអប្បច្ចយ ។

ឈ្មោះថា **សាសវៈ** ព្រោះរូបទាំងអស់ជាអារម្មណ៍របស់កាមាសវៈ ភវាសវៈ ទិដ្ឋាសវៈ និងអវិជ្ជាសវៈ រូបដែលមិនជាអារម្មណ៍របស់អាសវៈទាំងនេះ មិនមាន ។

ឈ្មោះថា **សង្ខតៈ** ព្រោះរូបទាំងឡាយ ត្រូវតាក់តែងដោយកម្ម ចិត្ត ឧតុ និងអាហារ ចំណែករូបដែលមិនត្រូវតាក់តែងដោយកម្មជាដើមទាំងនេះ រមែងមិនមាន ។

ឈ្មោះថា **លោកិយៈ** ព្រោះជាធម៌ជាប់ទាក់ទងក្នុងសង្ខារលោកនៃឧបាទាន មានការបែកធ្លាយ រូបដែលមិនបែកធ្លាយ រមែងមិនមាន ។

ឈ្មោះថា **កាមាវចរៈ** ព្រោះជាទីដែលត្រាច់ទៅនៃកាម

តណ្ហា ឬជាអារម្មណ៍របស់កាមាវចរតែម្យ៉ាង មិនជាអារម្មណ៍របស់មហគ្គតចិត្ត និងលោកុត្តរចិត្ត ព្រោះមហគ្គតចិត្ត មានបញ្ញត្តិនិងនាមជាអារម្មណ៍ លោកុត្តរចិត្តក៏មានព្រះនិព្វានជាអារម្មណ៍ ។

ឈ្មោះថា **អានារម្មណៈ** ព្រោះរូបមិនមានអារម្មណ៍ គឺមិនមានការដឹងអារម្មណ៍, មិនដូចចិត្ត និងចេតសិក ដូច្នេះ រូបទើបជាអនារម្មណ៍តែម្យ៉ាង ។

ដែលឈ្មោះថា **អប្បហាតព្វៈ** ព្រោះរូបទាំងពួង មិនមែនកិលេស ដែលនឹងគប្បីប្រហារ ដោយតទង្គប្បហានជាដើម រូប ដែលជាបហាតព្វៈ ទើបមិនមាន ។

រូបទាំងអស់ ២៨ នេះ ជាន័យដែលសម្តែងដោយចំណែកមួយ មិនមានប្រភេទផ្សេងយ៉ាងណាឡើយ ដូច្នេះ ទើបហៅថា **ឯកវិធន័យ** ( ន័យដែលសម្តែងអត្ថតែម្យ៉ាង ) ។

## នុកន័យ

## សង្គហគាថា

៥. ឥច្ចេវមដ្ឋវីសតិ វិធម្បិ ច វិចក្ខណា
អជ្ឈត្តិកាទិភេទេន វិភជន្តិ យថារហំ ។

បណ្ឌិតអ្នកឃើញប្រចក្ស រមែងចែករូបទុក សូម្បីទាំង ២៨ យ៉ាង ដោយសេចក្ដីផ្សេងគ្នានៃរូប មានអជ្ឈត្តិករូបជាដើម តាមសមគួរ ដោយប្រការដូច្នេះ ។

## ដោយចែករូប ២៨ ជា ១១ គូ

## គូទី១. អជ្ឈត្តិករូប និង ពាហិររូប

*អជ្ឈត្តិករូប* ប្រែថា រូបខាងក្នុង បានដល់ ប្រសាទរូប ៥ មានចក្ខុប្រសាទជាដើម ។

*ពាហិររូប* ប្រែថា រូបខាងក្រៅ បានដល់ រូបដែលនៅសល់ ២៣ រូប ។

ដែលឈ្មោះថា **អជ្ឈត្តិករូប** ព្រោះសម្ងឹងដល់ខ្លួន ពោលគឺអត្តភាពដែលជាខាងក្នុងប្រសាទរូប ៥ នេះ ប្រៀបដូចមនុស្សក្នុងផ្ទះ ចំណែករូបដែលនៅសល់ សូម្បីនៅក្នុងអត្តភាពជាមួយគ្នា ក៏ប្រៀបដូចមនុស្សក្រៅផ្ទះ, ម្យ៉ាងទៀត រូបមានចក្ខុប្រសាទជាដើមនោះ ឈ្មោះថា អជ្ឈត្តិករូប ព្រោះមានឧបការៈល្អច្រើនក្រៃលែងដល់អត្តភាពដោយពិសេស ដូចជានិយាយបានថា "បើពួកយើងមិនមាន ពួកលោកក៏នឹងដូចជាកំណាត់ឈើ" ។

ម្យ៉ាងទៀត ដែលឈ្មោះថា អជ្ឈត្ត ព្រោះពឹងអាស្រ័យចិត្ត គឺ ខ្លួនឱ្យប្រព្រឹត្តទៅដោយជាបញ្ចទ្វារនៃចិត្តនោះ ។ អជ្ឈត្តនុ៎ះឯងឈ្មោះថា អជ្ឈត្តិក, ចំណែករូប ដែលនៅសល់ ហៅថា ពាហិររូប ព្រោះកើតខាងក្រៅអំពីអជ្ឈត្តិករូបនោះ ។

## គូទី២. វត្ថុរូប និង អវត្ថុរូប

វត្ថុរូប ប្រែថា រូបដែលជាទីអាស្រ័យ ឱ្យចិត្តនិងចេតសិកកើតឡើង មាន ៦ បានដល់ ប្រសាទរូប ៥ មានចក្ខុវត្ថុជាដើម

និងហទយវត្ថុ ១ ចំណែកដែលសល់ ២២ ជាអវត្ថុរូប ព្រោះមិនជាទីអាស្រ័យឱ្យចិត្ត និងចេតសិកកើតឡើងទេ ។

## គូទី៣. ទ្វាររូប និង អទ្វាររូប

ទ្វាររូប ប្រែថា រូបដែលជាទ្វារ មាន ៧ រូប បានដល់ប្រសាទរូប ៥ មានចក្ខុទ្វារជាដើម និងវិញ្ញត្តិរូប ២ មានកាយវិញ្ញត្តិរូបជាដើម ។ ពិតមែន ការកើតឡើងរបស់វិថីចិត្តនៃបញ្ចទ្វារ មានចក្ខុវិញ្ញាណជាដើម ត្រូវមានប្រសាទរូប ៥ ជាឧប្បត្តិហេតុ ចក្ខុវិញ្ញាណជាដើម ទើបកើតឡើង ព្រោះដូច្នោះ ប្រសាទរូប ៥ នេះ ទើបឈ្មោះថា ឧប្បត្តិទ្វារ គឺ ទ្វារជាទីកើតឡើងនៃវិថីចិត្ត ។ មួយទៀត ការធ្វើសុចរិត និងទុច្ចរិតដែលប្រព្រឹត្តទៅផ្លូវកាយ និងវាចានោះ បើវៀរវិញ្ញត្តិរូប ២ ចេញហើយ រមែងកើតឡើងមិនបាន ដូច្នេះ វិញ្ញត្តិរូប ២ នេះ ទើបឈ្មោះថា **កម្មទ្វារ** គឺ ទ្វារនៃការធ្វើកម្ម, ចំណែករូបដែលសល់ ២១ ជាទ្វារមិនបាន ហៅថា **អទ្វាររូប** ។

## គូទី៤. ឥន្ទ្រិយរូប និង អនិន្ទ្រិយរូប

ឥន្ទ្រិយរូប គឺ រូបដែលជាធំ មាន ៨ រូប បានដល់ ប្រសាទរូប ៥ មានឈ្មោះថា ចក្ខុន្ទ្រិយជាដើម ភាវរូប ២ គឺ ឥត្ថិន្ទ្រិយ ១ បុរិសិន្ទ្រិយ ១ និងជីវិតរូប គឺ ជីវិតិន្ទ្រិយ ១ ចំណែករូបដែលនៅសល់ ២០ រូប ជារូបដែលមិនជាធំ ហៅថា អនិន្ទ្រិយរូប ។

ពិតមែន ប្រសាទរូប ៥ មានចក្ខុន្ទ្រិយជាដើម ឈ្មោះថា ជាធំក្រៃលែង ក្នុងចក្ខុទ្វារជាដើម ព្រោះកាលខ្លួនមានសុខភាពល្អ ឬទន់ខ្សោយជាដើម ក៏ឱ្យវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម ដល់សេចក្តីជាសភាពល្អ ឬទន់ខ្សោយជាដើម គឺ ធ្វើឱ្យចក្ខុវិញ្ញាណ ឃើញបានឆ្ងាយ ឃើញបានជិត និងឃើញបានច្បាស់ បើចក្ខុប្រសាទទន់ខ្សោយ ក៏ធ្វើឱ្យការឃើញមិនច្បាស់ជាដើម ។ សូម្បីសោតប្រសាទជាដើម ក៏ន័យនេះឯង ។ ភាវរូប ២ គឺ ឥត្ថិន្ទ្រិយរូប រូបដែលជាធំក្នុងភាពជាស្រីកាលកើត ក៏កើតឡើងដោយបច្ច័យរបស់ខ្លួន មិនលាយច្រឡំដោយភេទដទៃ និងកើត

ពេញសរីរៈ សូម្បីបុរិសិន្ទ្រិយរូប រូបដែលជាធំក្នុងភាពជាប្រុស ក៏ដោយន័យនេះឯង ។

**ជីវិតរូប** ក៏គឺជីវិតិន្ទ្រិយរូប រូបដែលជាធំក្នុងការរក្សាកម្មជរូបដែលកើតព្រមជាមួយខ្លួន គឺ កម្មជរូបកើត ក៏គឺជីវិតរូបកើតព្រមគ្នា ជីវិតរូបនេះឯង រក្សាកម្មជរូបឱ្យមានអាយុ ៥១ ខណៈតូចរបស់ចិត្ត ការកើតឡើងរបស់កម្មជរូបនោះ អាស្រ័យអតីតកម្ម មិនបានអាស្រ័យជីវិតរូប, ចំណែករូបដែលនៅសល់ ២០ នោះ មិនជាឥន្ទ្រិយ ហៅថា **អនិន្ទ្រិយរូប** ។

## គូទី៥. ឱឡារិករូប និង សុខុមរូប

**ឱឡារិករូប** ប្រែថា រូបគ្រោតគ្រាត គឺ រូបដែលប្រាកដច្បាស់ មាន ១២ រូប បានដល់ ប្រសាទរូប ៥ វិសយរូប ៧ គឺ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈ ៣ មានបឋវីផោដ្ឋព្វៈជាដើម, ចំណែករូបដែលនៅសល់ ១៦ រូប ជារូបដែលល្អិត ដឹងបានលំបាក ហៅថា **សុខុមរូប** រូបដែលល្អិត ។

## គូទី៦. សន្តិកេរូប និង ទូរេរូប

***សន្តិកេរូប*** ប្រែថា រូបជិត គឺ រូបដែលដឹងបានងាយ មាន ១២ រូប បានដល់ ប្រសាទរូប ៥ និង វិសយរូប ៧, ចំណែករូបដែលនៅសល់ ១៦ ជារូបដែលដឹងលំបាកជាង ហៅថា ***ទូរេរូប*** គឺ រូបឆ្ងាយ ។

## គូទី៧. សប្បដិឃរូប និង អប្បដិឃរូប

***សប្បដិឃរូប*** ប្រែថា រូបប៉ះខ្ទប់ ជារូបដែលដឹងបានដោយការប៉ះខ្ទប់គ្នារបស់រូប ដូចចក្ខុប្រសាទប៉ះខ្ទប់រូប( ពណ៌ )ជាដើម ជាហេតុឱ្យចក្ខុវិញ្ញាណឃើញពណ៌ជាដើម មាន ១២ រូប គឺ ប្រសាទរូប ៥ វិសយរូប ៧, ចំណែករូបដែលនៅសល់ ១៦ រូប ជារូបដែលដឹងមិនបាន ដោយការប៉ះខ្ទប់ទេ ទើបហៅថា ***អប្បដិឃរូប*** គឺ រូបដែលមិនប៉ះខ្ទប់ ។

## គូទី៨. ឧបាទិន្នរូប និង អនុបាទិន្នរូប

ឧបាទិន្នរូប ជារូបដែលកើតអំពីអកុសលកម្ម និង លោកិយកុសលកម្ម មាន ១៨ រូប បានដល់ កម្មជរូប ១៨ គឺ មហាភូតរូប ៤ ប្រសាទរូប ៥ វណ្ណរូប ១ គន្ធរូប ១ រសរូប ១ អាហាររូប ១ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ និង បរិច្ឆេទរូប ១ រួម ១៨ រូប ។

__ក្នុងអភិធម្មត្ថវិភាវិនី__ ពោលទុកថា ៖

រូប ១៨ យ៉ាង ដែលកើតអំពីកម្ម ឈ្មោះថា ឧបាទិន្នរូប ព្រោះដែលកម្មប្រកបដោយតណ្ហានិងទិដ្ឋិ កាន់យកហើយ គឺ គោរពទុកដោយសេចក្តីជាផលរបស់ខ្លួន រូបក្រៅនេះ ១០ រូប ហៅថា អនុបាទិន្នរូប ពោលដោយអគ្គហិតគហណន័យ(រាប់ហើយមិនរាប់ទៀត) អនុបាទិន្នរូប បានដល់ ចិត្តជរូប ១៥ ឧតុជរូប ១៣ និងអាហារជរូប ១២ ។

## គូទី៩. សនិទស្សនរូប និង អនិទស្សនរូប

***សនិទស្សនរូប*** ប្រែថា រូបដែលឃើញ(ដោយភ្នែក) បាន, បានដល់ រូបារម្មណ៍ ១ គឺ ពណ៌ផ្សេង ៗ, ចំណែករូប ២៧ ដែលនៅសល់ មិនអាចមើលឃើញទេ ហៅថា ***អនិទស្សនរូប*** ។

## គូទី១០. គោចរគាហិករូប និង អគោចរគាហិករូប

***គោចរគាហិករូប*** ប្រែថា រូបដែលអាចទទួលអារម្មណ៍ បានដល់ ប្រសាទរូប ៥ ដែលទទួលការប៉ះខ្ទប់នឹងបញ្ចារម្មណ៍ មាន ២ យ៉ាង គឺ ៖

***១-អសម្បត្តគោចរគាហិករូប*** : រូបដែលអាចទទួលអារម្មណ៍ ដែលមិនមក ដល់ខ្លួន គឺ ចក្ខុប្រសាទរូប និងសោតប្រសាទរូប

***២-សម្បត្តគោចរគាហិករូប*** : រូបដែលអាចទទួលអារម្មណ៍មក ដល់ខ្លួន គឺ ឃានប្រសាទរូប ជិវ្ហាប្រសាទរូប និងកាយប្រសាទរូប ។

ចំណែករូបនៅសល់ ២៣ ជា ***អគោចរគាហិករូប*** គឺ រូប

ដែលទទួលការប៉ះខ្ទប់នឹងអារម្មណ៍មិនបាន ។

<u>**អដ្ឋកថាចាស់**</u> ពោលថា អារម្មណ៍ ដែលឈ្មោះថា សម្បត្ត ព្រោះអារម្មណ៍នោះ មកកាន់គន្លងនៃចក្ខុ ឬ សោត ។

ពិតមែន ពណ៌មណ្ឌលនៃព្រះចន្ទនិងព្រះអាទិត្យ នៅឆ្ងាយរហូតដល់ ៤២.០០០ យោជន៍ ក៏អាចមកប៉ះខ្ទប់ចក្ខុប្រសាទបាន, ពណ៌នោះ សូម្បីប្រាកដតាំងនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថា សម្បត្តដូចគ្នា ចក្ខុនោះ ទើបឈ្មោះថា មានអារម្មណ៍ដែលមកដល់ហើយ ព្រោះសេចក្តីដែលពណ៌ (រូប)នោះ ជាអារម្មណ៍ ។

ក្នុងសេចក្តីនេះ **ព្រះពុទ្ធឃោសាចារ្យ** ពោលថា ៖

អារម្មណ៍ដែលឈ្មោះថា សម្បត្ត ព្រោះអារម្មណ៍នោះ មកកាន់គន្លងក៏ពិត តែពណ៌មណ្ឌលព្រះចន្ទ និងព្រះអាទិត្យមិនមកដល់ចក្ខុប្រសាទទេ ក៏ប្រាកដ តាំងនៅក្នុងទីឆ្ងាយនោះឯង សូម្បីសំឡេង ក៏គប្បីជះមកបន្តបន្ទាប់គ្នា បើកើតក្នុងទីឆ្ងាយ រមែងបានឮក្នុងពេលយូរដែរ ព្រោះមកដោយការប៉ះខ្ទប់ត ៗគ្នា (ដូចយើង

ពួត្តរលាន់ក្រោយពីពន្លឺផ្លេកបន្ទោរ ) កាលប៉ះខ្ទប់ដល់សោតប្រសាទ ក៏មិនប្រាកដជា សំឡេងនោះ នៅក្នុងទិសខាងឯណោះ ៗ ព្រោះដូច្នោះ ចក្ខុនិងសោត ទើបមានអារម្មណ៍ ដែលជាអសម្បត្តប៉ុណ្ណោះ ។

## គូទី១១. អវិនិព្ភោគរូប និង វិនិព្ភោគរូប

***អវិនិព្ភោគរូប*** ប្រែថា រូបដែលមិនបែកគ្នា មាន ៨ គឺ មហាភូតរូប៤ វណ្ណរូប១ គន្ធរូប១ រសរូប១ អាហាររូប១ ។

រូប ៨ នេះ និងតូចប៉ុនបរមាណូ ១ ក៏មានរូប ៨ មិនថារូបនោះ នឹងកើតអំពីកម្ម ចិត្ត ឧតុ ឬអាហារក៏ដោយ រូបតូចរហូតដល់មើលដោយភ្នែកមិនឃើញ ក៏មានរូបដែលរួមគ្នា ៨ រូប ។ ចំណែករូបដែលនៅសល់ ២០ ជារូបដែលបែកពីគ្នាបាន ដូច្នោះ ទើបហៅថា ***វិនិព្ភោគរូប*** ។

**ចប់ រូបន័យទី ២ រូបវិភាគ**

## រូបន័យទី ៣ រូបសមុដ្ឋាន

*សមុដ្ឋាន មានវចនត្ថៈថា ៖*

**សមុដ្ឋហន្តិ ជាយន្តិ ឯតេនាតិ = សមុដ្ឋានំ** *រូបទាំងឡាយ រមែងតាំងឡើង គឺ រមែងកើតដោយធម៌នេះ ព្រោះហេតុនោះ ធម៌ដែលជាហេតុឱ្យរូបកើតនោះ ទើបឈ្មោះថា* **សមុដ្ឋាន** ។

### សង្គហគាថា

៦ អដ្ឋារស បណ្ណរស តេរស ទ្វាទសាតិ ច
កម្មចិត្តោតុកាហារ ជានិ ហោន្តិ យថាក្កមំ ។

៧ ជាយមានាទិរូបានំ សភាវត្តា ហិ កេវលំ
លក្ខណានិ ន ជាយន្តិ កេហិចីតិ បកាសិតំ ។

*រូបដែលកើតអំពីកម្ម ចិត្ត ឧតុ និងអាហារ មានតាមលំដាប់ គឺ កម្មជរូប ១៨ ចិត្តជរូប ១៥ ឧតុជរូប ១៣ អាហារជរូប ១២ ។ ព្រះមានព្រះភាគ ទ្រង់ប្រកាសថា លក្ខណរូប ៤ មានឧបចយរូបជាដើម*

**មិនកើតអំពីសមុដ្ឋានណា ៗឡើយ ព្រោះជាសភាវៈនៃរូបដែលកំពុងកើតជាដើមតែម្យ៉ាង ។**

## សមុដ្ឋាននៃរូបមាន ៤

១-អតីតកម្ម បានដល់ ចេតនា ២៥

២-ចិត្ត បានដល់ ចិត្តុប្បាទ ៧៥ (វៀរចិត្ត ១៤)

៣-ឧតុ បានដល់ ភាពក្តៅ និងភាពត្រជាក់

៤-អាហារ បានដល់ ឱជាដែលមានទៅទាំងខាងក្នុងទាំងខាងក្រៅ

## ១-កម្មសមុដ្ឋាន

**កម្ម** បានដល់ ចេតនា ២៥ ប្រភេទ គឺ ចេតនាក្នុងអកុសលចិត្ត១២ ក្នុងមហាកុសលចិត្ត៨ ក្នុងរូបាវចរកុសលចិត្ត៥ ដែលធ្វើស្រេចហើយ ក្នុងអតីតភព ឬក្នុងបច្ចុប្បន្នភព រមែងជាបច្ច័យឱ្យរូបកើតឡើង ក្នុងអជ្ឈត្តិកសន្តានរបស់សត្វទាំងឡាយគ្រប់ខណៈរបស់ចិត្ត តាំងអំពីបដិសន្ធិ គឺ តាំងអំពីឧប្បាទក្ខណៈ

ឋិតិខណៈ និងភង្គខណៈរបស់បដិសន្ធិចិត្តជាដើម កម្មជរូបទាំងនេះ នឹងប្រាកដនៅត្រឹម ៧ ខណៈចិត្តរបស់ចិត្ត ហើយក៏រលត់ទៅព្រម ជាមួយចិត្ត តអំពីនោះ ក៏មានកម្មជរូបថ្មីកើតឡើងទៀត ហើយក៏ រលត់ទៅព្រមជាមួយចិត្ត តាមដែលពោលហើយជាយ៉ាងនេះ រហូត ដល់ចុតិកើតឡើង ហើយរលត់ព្រមជាមួយចិត្តក្នុងភពនេះ ។

ចេតនាដែលជាកម្មទាំងអស់ មាន ៣៣ តែកម្មដែលធ្វើឱ្យ រូបកើតបាន មាន ២៥ ប៉ុណ្ណោះ ចំណែកកម្មដែលមិនធ្វើឱ្យរូប កើត មាន ៨ គឺ អរូបាវចរកុសលកម្ម ៤ និងលោកុត្តរកុសល កម្ម ៤ ។ អរូបាវចរកុសលកម្ម ដែលមិនធ្វើឱ្យរូបកើតឡើងក្នុង អរូបភព ព្រោះអ្នកចម្រើនអរូបកម្មដ្ឋាន ឃើញទោសក្នុងការមាន រូបរាងកាយ មិនមានសេចក្ដីប្រាថ្នារូប ទើបចម្រើនរូបវិរាគសញ្ញា កាលចុតិអំពីលោកនេះហើយ ក៏កើតក្នុងអរូបភព ភពដែលមិន មានរូប ។ ចំណែកលោកុត្តរកុសលចិត្ត ដែលមិនញ៉ាំងរូបឱ្យកើត ឡើងក្នុងភពថ្មី ព្រោះលោកុត្តរកុសលធម៌ ជាកម្មទម្លាយភពជាតិ

ក្នុងសង្សារវដ្ដ ដូច្នេះ ទើបមិនញុំាងរូបឱ្យកើតឡើង ។

រូបដែលមានកម្មជាសមុដ្ឋានមាន១៨ រូប គឺ មហាភូតរូប ៤ ប្រសាទរូប៥ គោចររូប៣ (វៀរសទ្ទរូប) ភាវរូប២ ហទយរូប១ ជីវិតរូប១ អាហាររូប១ បរិច្ឆេទរូប១ ។

**កម្មជរូបកើតបាន ២៧ ភូមិ គឺ ៖**

ក្នុងបញ្ចវោការភូមិ (ភូមិដែលមានខន្ធ ៥) កើតបាន ២៦ ភូមិ

ក្នុងឯកវោការភូមិ (ភូមិដែលមានខន្ធ ១) កើតបាន ១ ភូមិ

## ២-ចិត្តសមុដ្ឋាន

ចិត្តដែលធ្វើឱ្យរូបកើត មាន ៧៥ (វៀរទ្វិបញ្ចវិញ្ញាណ ១០ អរូបវិបាក ៤ បដិសន្ធិចិត្ត និងចុតិចិត្តរបស់ព្រះអរហន្ត) ចិត្តក្នុងបច្ចុប្បន្នភពដែលធ្វើរូបឱ្យកើត ហៅថា ចិត្តជរូប ។

ក៏ចិត្តជរូបនេះ រមែងកើតឡើងគ្រប់ ៗ ឧប្បាទក្ខណៈ

របស់ចិត្តប៉ុណ្ណោះ មានកម្លាំង ចំណែក ២ ខណៈក្រោយ ចិត្តមិនមានកម្លាំង ទើបមិនធ្វើឱ្យរូបកើតឡើង ចិត្តជរូបនោះ ផ្តើមកើតតាំងអំពីឧប្បាទក្ខណៈរបស់បឋមភវង្គចិត្តជាដើមទៅ ។

ចិត្តទាំងអស់មាន ៨៩ តែដែលធ្វើឱ្យរូបកើត មាន ៧៥ ចិត្តដែលមិនធ្វើរូបឱ្យកើត គឺ ទ្វិបញ្ចវិញ្ញាណ ១០ អរូបវិបាកចិត្ត ៤ ចិត្តដែលធ្វើបដិសន្ធិ និងចុតិចិត្តរបស់ព្រះអរហន្ត ព្រោះទ្វិបញ្ចវិញ្ញាណមានកម្លាំងខ្សោយ គឺ មិនប្រកបរួមជាមួយអង្គឈានទាំងឡាយ ដែលជាបច្ច័យពិសេសក្នុងការញ៉ាំងរូបឱ្យកើត ។ អរូបវិបាកចិត្តមិនញ៉ាំងរូបឱ្យកើត ព្រោះចម្រើនរូបវិរាគសញ្ញា ជាហេតុឱ្យប្រាសចាករូប និងរូបនោះ មិនមានឱកាស ។

បដិសន្ធិចិត្តទាំងអស់ (វៀរអរូបវិបាកចិត្ត ៤) គឺ ឧបេក្ខាសន្តីរណចិត្ត ២ មហាវិបាកចិត្ត ៨ និងរូបាវចរវិបាកចិត្ត ៥ ណាមួយ កាលផ្តើមកើតក្នុងភពថ្មី រមែងមានកម្លាំងខ្សោយ ទើបមិនអាចធ្វើរូបឱ្យកើតឡើង ។

ចុតិចិត្តរបស់ព្រះអរហន្ត ១៣ គឺ មហាវិបាកញាណសម្បយុត្តចិត្ត ៤ រូបាវចរវិបាកចិត្ត ៥ អរូបាវចរវិបាកចិត្ត ៤ នោះ (វៀរអរូបវិបាក ៤) បើធ្វើ (កិច្ច)ចុតិ ចិត្តរបស់បុគ្គលក្រៅអំពីព្រះអរហន្ត រមែងញុំាងរូបឱ្យកើតឡើងបាន ។

## ចិត្តជរូបមាន ៧ យ៉ាង

១- ចិត្តជរូប ដែលជាសាមញ្ញ

២- ចិត្តជរូប ដែលជាប់ទាក់ទងជាមួយការសើច

៣- ចិត្តជរូប ដែលជាប់ទាក់ទងជាមួយការយំ

៤- ចិត្តជរូប ដែលជាប់ទាក់ទងជាមួយការកម្រើកញ័រ

៥- ចិត្តជរូប ដែលជាប់ទាក់ទងជាមួយការនិយាយ

៦- ចិត្តជរូប ដែលជាប់ទាក់ទងជាមួយឥរិយាបថធំ ៤

៧- ចិត្តជរូប ដែលជាប់ទាក់ទងជាមួយឥរិយាបថ ៤ ដែលតាំងមាំ

១- **ចិត្តជរូបសាមញ្ញ** បានដល់ ចិត្តជរូបដែលប្រព្រឹត្តទៅតាមធម្មតា ក្នុងរាងកាយសត្វ ដូចមានការដកដង្ហើមចូល-ចេញ ការលោតរបស់បេះដូង ការលោតរបស់ជីពចរជាដើម មានរូបកើតបាន ៨ រូប ហៅថា អវិនិព្ភោគរូប ៨ ។

ចិត្តដែលធ្វើឱ្យចិត្តជរូបសាមញ្ញកើត មាន ៧៥ គឺ អកុសលចិត្ត ១២ អហេតុកចិត្ត ៨ (វៀរទ្វិបញ្ចវិញ្ញាណ ១០) កាមាវចរសោភណចិត្ត ២៤ មហគ្គតចិត្ត ២៣ (វៀរវិបាកចិត្ត ៤) លោកុត្តរចិត្ត ៨ ។

២- **ចិត្តជរូបដែលជាប់ទាក់ទងជាមួយការសើច** បានដល់ ចិត្តដែលធ្វើឱ្យញញឹមសើច ១៣ គឺ សោមនស្សលោភមូលចិត្ត ៤ សោមនស្សមហាកុសលចិត្ត ៤ សោមនស្សមហាកិរិយាចិត្ត ៤ សោមនស្សហសិតុប្បាទចិត្ត ១ ។

* បុថុជ្ជន ញញឹមសើចដោយចិត្ត៨ គឺ សោមនស្សលោភមូលចិត្ត៤ សោមនស្សមហាកុសលចិត្ត៤

* ព្រះសេក្ខបុគ្គល ញញឹមសើចដោយចិត្ត ៦ គឺ សោមនស្សលោភមូលចិត្ត ទិដ្ឋិគតវិប្បយុត្ត ២ សោមនស្សមហាកុសលចិត្ត ៤

* ព្រះអសេក្ខបុគ្គល ញញឹមដោយចិត្ត ៥ គឺ
សោមនស្សមហាកិរិយាចិត្ត ៤ សោមនស្ស
ហសិតុប្បាទចិត្ត ១

សោមនស្សហសិតុប្បាទចិត្តរបស់ព្រះអរហន្ត កាលកើត រមែងកើតព្រោះប្រសព្វជាមួយអារម្មណ៍ល្អិត ដែលបុគ្គលធម្មតាមិនអាចដឹងបាន ។ តែការញញឹមណា កើតព្រោះជួបជាមួយអារម្មណ៍គ្រោតគ្រាត ដែលបុគ្គលធម្មតា ក៏អាចដឹងបាន ការញញឹមនោះ រមែងកើតដោយមហាកិរិយាចិត្ត ។

៣- **ចិត្តជួររូបដែលជាប់ទាក់ទងជាមួយការយំ** បានដល់ទោសមូលចិត្ត ២ ។

៤- **ចិត្តជួររូបដែលជាប់ទាក់ទងជាមួយការកម្រើក** ( កាយ )

បានដល់ ចិត្តឱ្យកើតការកម្រើកផ្សេង ៗ ដោយឥរិយាបថតូច មានការបត់(ចូល) ការលា ឱន ងើប ក្រឡេកឆ្វេង-ស្តាំ ដើរទៅមុខ ថយក្រោយ ប៉ប្រិចភ្នែក ស្ងាប ដេក ទំពារ និងលេបអាហារជាដើម កើតដោយចិត្ត ៣២ គឺ ៖

+ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ អភិញ្ញាចិត្ត ២

៥- **ចិត្តជរូបដែលជាប់ទាក់ទងជាមួយការនិយាយ** បានដល់ ការបញ្ចេញសំឡេងអំពីមាត់កើតដោយចិត្ត ៣២ ដូចចិត្តជរូបដែលជាប់ទាក់ទងជាមួយការកម្រើក ខទី ៤ ។

៦- **ចិត្តជរូបដែលជាប់ទាក់ទងជាមួយឥរិយាបថធំ ៤** បានដល់ ការកម្រើកញ័រដោយឥរិយាបថធំ ៤ គឺ ឈរ ដើរ អង្គុយ និងដេក នេះក៏កើតដោយចិត្ត ៣២ ដូចទី ៤ ទុះឯង ។

៧- **ចិត្តជរូបដែលជាប់ទាក់ទងជាមួយឥរិយាបថ ៤ ដែលតាំងមាំ** បានដល់ ការដើរ ឈរ អង្គុយ និងដេក ដែលប្រព្រឹត្ត

ទៅតាមប្រក្រតីរបស់អ្នកមិនមានរោគភ័យ បៀតបៀនកើតដោយចិត្ត ៥៨ គឺ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ អភិញ្ញាចិត្ត ២ អប្បនាជវនចិត្ត ២៦ ។

<u>ក្នុងអភិធម្មត្ថវិភាវិនី</u>

**ឥរិយាបថ** មានវិគ្រោះថា **ឥរិយាយ កាយិកកិរិយាយ បវត្តិបថភាវតោ = ឥរិយាបថោ គមនាទិ :** ការដើរជាដើម ឈ្មោះថា ឥរិយាបថ ព្រោះជាផ្លូវនៃការប្រព្រឹត្តិទៅរបស់ការកម្រើកញ័រ គឺ កិរិយាផ្លូវកាយ អធិប្បាយថា ដោយអត្ថ បាន ដល់ ការប្រព្រឹត្តិទៅនៃរូបដែលធ្វើឱ្យមានការដើរបានជាដើមនោះ ។

ចិត្តជរូបមាន ១៥ គឺ មហាភូតរូប ៤ គោចររូប ៤ អាហាររូប ១ បរិច្ឆេទរូប ១ វិញ្ញត្តិរូប ២ វិការរូប ៣ ។

## ៣~ ឧតុសមុដ្ឋាន

ឧតុ បានដល់ តេជោធាតុ ដែលជាសីតតេជោ (ភាពត្រជាក់) ឧណ្ហតេជោ (ភាពក្តៅ) ដែលជាសមុដ្ឋាន មាននៅ

ពេញទូទៅក្នុងរាងកាយរបស់សត្វ និងមានទូទៅខាងក្រៅពីសត្វ ។

ឧតុដែលធ្វើឱ្យរូបកើតខាងក្នុងសន្តានរបស់សត្វ ហៅថា អជ្ឈត្តឧតុ បានដល់ ភាពក្តៅដែលកើតឡើងខាងក្នុងរាងកាយរបស់សត្វ, ឧតុជរូបនេះ រមែងកើតឡើងគ្រប់ ៗ ឋិតិខណៈរបស់ចិត្ត និងផ្តើមតាំងអំពីឋិតិខណៈរបស់បដិសន្ធិចិត្តជាដើមទៅ ។

ចំណែកឧតុដែលធ្វើរូបឱ្យកើតខាងក្រៅរបស់សត្វ ហៅថា ពហិទ្ធឧតុ បានដល់ ឧតុដែលនៅក្នុងវត្ថុដទៃ ដូចក្នុងផែនដី ក្នុងអាកាស ក្នុងទន្លេ ក្នុងអូរ ភ្នំ និងដើមឈើជាដើម រូបទាំងនេះរមែងមានឧតុជាសមុដ្ឋាន ឱ្យកើតឡើងបានរហូតទៅទាល់តែរូបនោះ បែកធ្លាយ រលាយអស់ ។

ឧតុជរូប គឺ រូបដែលកើតអំពីឧតុ មាន ១៣ រូប គឺ ៖

មហាភូតរូប ៤ គោចររូប ៤ អាហាររូប ១ បរិច្ឆេទរូប ១ វិការរូប ៣ ។

## ៤. អាហារសមុដ្ឋាន

អាហារដែលជាសមុដ្ឋាន ឈ្មោះថា អាហារសមុដ្ឋាន, រូបដែលកើតអំពីអាហារជាសមុដ្ឋាន ហៅថា អាហារជរូប ។

អាហារ គឺ ឱជាដែលមាននៅក្នុងពំនូតបាយផ្សេង ៗ ដែលសត្វបរិភោគចូលទៅ កាលត្រូវរំលាយដោយភ្លើងរំលាយអាហារ គឺ បាចកតេជោហើយ ក៏ធ្វើឱ្យអាហាររូបកើតឡើងក្នុងសន្តានរបស់សត្វ និងរមែងកើតគ្រប់ឋិតិខណៈ ដោយផ្តើមតាំងអំពីអាហារជរូប ដែលមាតាបរិភោគហើយ ជ្រួតជ្រាបចូលទៅក្នុងរាងកាយរបស់គព្ភសេយ្យកសត្វ និងចាប់ផ្តើមតាំងពីវេលាដែលឱជានៃស្លេស្ម៍ នៅក្នុងមាត់របស់សត្វ ជ្រួតជ្រាបទៅក្នុងសរីរៈរបស់សត្វសំសេទជៈ និងឧបបាតិកកំណើត ។

ឱជា គឺ អាហាររូប មាននៅទាំងខាងក្នុងសត្វ និងខាងក្រៅ

ដែលមានខាងក្នុងសត្វ ហៅថា **អជ្ឈត្តឱជា**

ដែលមានខាងក្រៅសត្វ ហៅថា **ពហិទ្ធឱជា** ។

ម្យ៉ាងទៀត ឱជាដែលមាននៅខាងក្នុងសន្តានសត្វទាំងឡាយ ហៅថា កម្មជ្ជឱជា, ឱជាដែលមាននៅក្នុងអាហារខាងក្រៅ ហៅថា ឧតុជ្ជឱជា ។

អជ្ឈត្តឱជា ក៏បានដល់ កម្មជ្ជឱជាដែលកើតនៅក្នុងកម្មជ្ជរូប ១៨ នោះឯង ។ ចំណែកពហិទ្ធឱជា ក៏គឺ ឧតុជឱជាដែលមាននៅក្នុងអវិនិព្ភោគរូប ៨ ក្នុងអាហារផ្សេង ៗខាងក្រៅ ។ ពហិទ្ធឱជានេះ កាលសត្វបរិភោគចូលទៅហើយ រំលាយដោយបាចកតេជោល្អហើយ ក៏ផ្សំជាមួយកម្មជ្ជឱជា ធ្វើឱ្យអាហាររូបកើតឡើង ប្រព្រឹត្តទៅរហូត ៧ ថ្ងៃ ។

បណ្តាឱជាទាំង ២ ប្រភេទនោះ អជ្ឈត្តឱជា ធ្វើនាទីជួយឧបត្ថម្ភអាហារជ្ជរូប ឱ្យកើតហៅថា ឧបត្ថម្ភកសត្តិ, ចំណែកពហិទ្ធឱជា ធ្វើនាទីឱ្យអាហារជ្ជរូបកើតឡើង ដោយត្រង់ ហៅថា

ជនកសត្តិ ។

កម្មជឱជា មានប្រយោជន៍ ក្នុងការឧបត្ថម្ភ ឱ្យអាហារជរូបកើតច្រើនជាងឧតុជឱជា ។

<u>ក្នុងវិសុទ្ធិមគ្គ</u> ពោលថា អាហារដែលបរិភោគហើយ ក្នុងមួយថ្ងៃ រមែងឧបត្ថម្ភរាងកាយឱ្យតាំងនៅបានរហូត ៧ ថ្ងៃ ។ សត្វដែលអាស្រ័យគភ៌មាតាកើតនោះ អាហារជរូប ផ្ដើមកើតក្នុងសប្ដាហ៍ទី ២ ឬទី ៣ រាប់តាំងអំពីបដិសន្ធិ គឺ កាលមាតាបរិភោគអាហារចូលទៅ ក្នុងចន្លោះនៃការតាំងគភ៌ ឱជាក៏នឹងជ្រួតជ្រាបចូលកាន់រាងកាយទារក ក្នុងគភ៌ដែលនៅជាអព្វុទៈ ឬជាបេសិ ហើយក៏ធ្វើឱ្យអាហារជរូប កើតឡើងដល់ទារកនោះ ។

ចំណែកសត្វដែលជាសំសេទជកំណើត ឬជាឧបបាតិកកំណើត កាលកើតឡើងគ្រាដំបូង ក៏មានរាងកាយបរិបូណ៌ដោយនៅមិនបានបរិភោគអាហារណា ៗ គ្រាន់តែអាស្រ័យការ

លេបស្លេស្ម៍ ឬទឹកមាត់របស់ខ្លួនឯង លូមស្លេស្ម៍ ឬទឹកមាត់កន្លង បំពង់កហើយ ឱជានៃស្លេស្ម៍ ឬទឹកមាត់នោះ ក៏ជ្រួតជ្រាបចូលកាន់រាងកាយ ជាអាហាររបស់រូប ។ កាលបរិភោគអាហារដែលជាខាងក្រៅចូលទៅហើយ អាហាររូបរបស់សត្វនេះ ក៏កើតឡើងជាប់បន្តគ្នាទៅ រហូតដល់អស់វេលា រហូតដល់ចុតិកាល ។

## អាហារជរូបមាន ១២ គឺ

មហាភូតរូប ៤ គោចររូប ៣ (វៀរសទ្ទរូប) អាហាររូប ១ បរិច្ឆេទរូប ១ វិការរូប ៣ ។

## សរុបរូបដែលកើតអំពីសមុដ្ឋាន ៤

រូបកើតអំពីកម្ម ជាសមុដ្ឋាន ឈ្មោះថា **កម្មជរូប** មាន ១៨រូប
រូបកើតអំពីចិត្ត ជាសមុដ្ឋាន ឈ្មោះថា **ចិត្តជរូប** មាន ១៥រូប
រូបកើតអំពីឧតុ ជាសមុដ្ឋាន ឈ្មោះថា **ឧតុជរូប** មាន១៣រូប
រូបកើតពីអាហារជាសមុដ្ឋាន ឈ្មោះថា **អាហារជរូប** មាន១២រូប

# សម្ដែងរូបសមុដ្ឋាន ៤

## ១_កម្មជរូប ១៨

ដោយប្រាកដ មានរូប ៩ គឺ ប្រសាទរូប ៥ ភាវរូប ២
ជីវិតរូប ១ ហទយរូប ១
ដោយមិនប្រាកដ មានរូប ៩ គឺ មហាភូតរូប ៤ គោចររូប ៣
(វៀរសទ្ទរូប) អាហាររូប ១
បរិច្ឆេទរូប ១ ។

## ២_ចិត្តជរូប ១៥

ដោយប្រាកដ មានរូប ២ គឺ វិញ្ញត្តិរូប ២
ដោយមិនប្រាកដ មានរូប ១៣ គឺ អវិនិព្ភោគរូប៨
សទ្ទរូប១ បរិច្ឆេទរូប១ វិការរូប៣

## ៣-ឧតុជរូប ១៣

ដោយប្រាកដ មិនមាន

ដោយមិនប្រាកដ មានរូប ១៣ គឺ អវិនិព្ភោគរូប៨ សទ្ទរូប១ បរិច្ឆេទរូប១ វិការរូប៣

## ៤-អាហារជរូប ១២

ដោយប្រាកដ មិនមាន

ដោយមិនប្រាកដ មានរូប ១២ គឺ អវិនិព្ភោគរូប៨ បរិច្ឆេទរូប១ វិការរូប៣

## ចំនួនរូប ដោយសមុដ្ឋាន ៥ ន័យ

<u>ន័យទី ១</u> ឯកសមុដ្ឋានិករូប រូបដែលកើតដោយសមុដ្ឋាន ១ មាន ១១ គឺ ៖

- រូបកើតអំពីកម្ម ៩ គឺ ប្រសាទរូប ៥ ជីវិតរូប ១ ភាវរូប ២ ហទយរូប ១

- រូបកើតអំពីចិត្ត ២ គឺ កាយវិញ្ញត្តិរូប និង វចីវិញ្ញត្តិរូប

ន័យទី ២ ទ្វិសមុដ្ឋានិករូប រូបដែលកើតដោយសមុដ្ឋាន ២ មាន ១ រូប គឺ ៖

-សទ្ទរូបដែលកើតអំពីចិត្តជាសមុដ្ឋាន និងកើតអំពី ឧតុជាសមុដ្ឋាន ។

ន័យទី ៣ តិសមុដ្ឋានិករូប រូបដែលកើតដោយសមុដ្ឋាន ៣ មាន ៣ រូប គឺ ៖

-វិការរូប ៣ ដែលកើតអំពីចិត្ត ឧតុ និងអាហារ ជាសមុដ្ឋាន ។

ន័យទី ៤ ចតុសមុដ្ឋានិករូប រូបដែលកើតដោយសមុដ្ឋាន ទាំង៤ មាន ៩រូប គឺ មហាភូតរូប៤ គោចររូប៣ (វៀរសទ្ទរូប) បរិច្ឆេទរូប១ អាហាររូប១ ។

ន័យទី ៥ នកុតោចិសមុដ្ឋានិករូប រូបដែលមិនកើតអំពី សមុដ្ឋាន ៤ មាន ៤រូប គឺ លក្ខណរូប៤ មានឧបចយរូបជា

ដើម ។

# សរុបរូបដែលជាសមុដ្ឋាន ដោយអភិធម្មន័យ

| ចំនួន | កម្ម | ចិត្ត | ឧតុ | អាហារ | រួមសមុដ្ឋាន |
|---|---|---|---|---|---|
| មហាភូតរូប៤ | ៤ | ៤ | ៤ | ៤ | កើតបាន ៤ សមុដ្ឋាន |
| ប្រសាទរូប ៥ | ៥ | - | - | - | កើតបានចំពោះកម្ម |
| គោចររូប ៣ | ៣ | ៣ | ៣ | ៣ | កើតបាន ៤ សមុដ្ឋាន |
| សទ្ទរូប ១ | - | ១ | ១ | - | កើតបាន ២ សមុដ្ឋាន |
| ភាវរូប ២ | ២ | - | - | - | កើតបានចំពោះកម្ម |
| ហទយរូប ១ | ១ | - | - | - | កើតបានចំពោះកម្ម |
| ជីវិតរូប ១ | ១ | - | - | - | កើតបានចំពោះកម្ម |
| អាហាររូប ១ | ១ | ១ | ១ | ១ | កើតបាន ៤ សមុដ្ឋាន |
| បរិច្ឆេទរូប ១ | ១ | ១ | ១ | ១ | កើតបាន ៤ សមុដ្ឋាន |
| វិញ្ញត្តិរូប ២ | - | ២ | - | - | កើតបានចំពោះចិត្ត |
| វិការរូប ៣ | - | ៣ | ៣ | ៣ | កើតបាន ៣ សមុដ្ឋាន |
| លក្ខណរូប ៤ | - | - | - | - | មិនកើតពីសមុដ្ឋាន |
| រួមរូប ២៨ | ១៨ | ១៥ | ១៣ | ១២ | → ៥៨, / ២៦, ↵ |

## ចែកសមុដ្ឋាននិករូប ដោយសុត្តន្តន័យ

ក្នុងព្រះសូត្រ ចែករូបធម៌ គឺ រាងកាយរបស់សត្វ ដែលប្រកបដោយធាតុ ៤ រួមអាការ បាន ៤២ កោដ្ឋាសយ៉ាងនេះ គឺ

១-សសម្ភារបឋវី ២០ កោដ្ឋាស

២-សសម្ភារអាបោ ១២ កោដ្ឋាស

៣-សសម្ភារតេជោ ៤ កោដ្ឋាស

៤-សសម្ភារវាយោ ៦ កោដ្ឋាស

### ១- សសម្ភារបឋវី ២០

បឋវីដែលជាចំណែកខាងក្នុងរាងកាយរបស់សត្វ ហៅថា **អជ្ឈត្តិកបឋវី** ចែកជា ២ ប្រភេទ គឺ ៖

**១, ឧទរិយំ** អាហារថ្មី **ករីសំ** អាហារចាស់ មានឧតុ ជាសមុដ្ឋានតែម្យ៉ាង

**២, កោដ្ឋាស ១៨** ដែលនៅសល់ មាន ៤ សមុដ្ឋាន គឺ **កេសា** សក់, **លោមា** រោម, **នខា** ក្រចក, **ទន្តា** ធ្មេញ, **តចោ**

ស្បែក, **មំសំ** សាច់, **នហារូ** សរសៃ, **អដ្ឋិ** ឆ្អឹង, **អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង, **វក្កំ** តម្រងបស្សាវៈ, **ហទយំ** បេះដូង, **យកនំ** ថ្លើម, **កិលោមកំ** វាវ, **បិហកំ** ក្រពះ, **បប្ផាសំ** សួត, **អន្តំ** ពោះវៀនធំ, **អន្តគុណំ** ពោះវៀនតូច, **មត្ថលុង្គំ** ខួរក្នុងក្បាល ។

## ២- សសម្ភារអាបោ ១២ កោដ្ឋាស

អាបោដែលជាចំណែកខាងក្នុងនៃរាងកាយ ហៅថា **អជ្ឈត្តិកអាបោ** ចែក ជា ៣ ប្រភេទ គឺ ៖

**១, បុព្វោ** ទឹកខ្ទុះ **មុត្តំ** ទឹកមូត្រ មានឧតុជាសមុដ្ឋាន

**២, សេទោ** ញើស, **អស្សុ** ទឹកភ្នែក, **ខេឡោ** ទឹកមាត់, **សិង្ឃានិកា** ទឹកសំបោរ, មានចិត្ត និងឧតុ ជាសមុដ្ឋាន ។

**៣, កោដ្ឋាស ៦** ដែលនៅសល់ មាន ៤ សមុដ្ឋាន គឺ **បិត្តំ** ទឹកប្រមាត់, **សេម្ហំ** ស្លេស្ម៍, **វសា** ខ្លាញ់រាវ, **លោហិតំ** ឈាម, **លសិកា** ទឹករំអិល, **មេទោ** ខ្លាញ់ខាប់ ។

## ៣- សសម្ភារតេជោ ៤ កោដ្ឋាស

តេជោដែលជាចំណែកខាងក្នុងនៃរាងកាយ ហៅថា **អជ្ឈត្តិកតេជោ** គឺ ៖

**១, បាចកតេជោ** ភ្លើងរំលាយអាហារ មានកម្មជាសមុដ្ឋាន

**២, កោដ្ឋាស ៣** គឺ **ឧស្មាតេជោ. ជីរណតេជោ. សន្តាបនតេជោ.** ដែលនៅសល់ មានសមុដ្ឋាន ៤ ។

## ៤- សសម្ភារវាយោ ៦ កោដ្ឋាស

វាយោដែលជាចំណែកខាងក្នុងនៃរាងកាយ ហៅថា **អជ្ឈត្តិកវាយោ** ចែកជា ២ ប្រភេទ គឺ ៖

**១, អស្សាសបស្សាសវាយោ** ខ្យល់ដកដង្ហើមចូល-ចេញ មានចិត្ត ជាសមុដ្ឋានតែម្យ៉ាង

**២, កោដ្ឋាស ៥** គឺ **ឧទ្ធង្គមវាយោ អធោគមវាយោ កុច្ឆិសយវាយោ កោដ្ឋាសយវាយោ អង្គមង្គានុសារិវាយោ** ដែលនៅសល់ មានសមុដ្ឋាន ៤ ។

## ចែកសមុដ្ឋាន ៤ ក្នុងកោដ្ឋាស ៤២

១- មានកម្ម ជាសមុដ្ឋាន មាន១ គឺ បាចកតេជោ

២- មានចិត្ត ជាសមុដ្ឋាន មាន១ គឺ អស្សាសបស្សាសវាយោ

៣- មានឧតុ ជាសមុដ្ឋាន មាន៤ គឺ ឧទរិយំ ករីសំ បុព្វោ មុត្តំ

៤- មានចិត្ត និងឧតុ ជាសមុដ្ឋាន មាន៤ គឺ សេទោ អស្សុ ខេឡោ សង្ឃាណិកា

៥- មាន ៤ សមុដ្ឋាន គឺ កោដ្ឋាស ៣២ ដែលនៅសល់ ។

**ចប់ រូបន័យទី ៣ រូបសមុដ្ឋាន**

# រូបន័យទី ៤ រូបកលាប

រូបកលាប មានវចនត្ថៈថា **កលាបិយន្តិ សមូហាវសេន សង្ខ្យាបិយន្តិ ឯត្ថាតិ = កលាបោ** រូបទាំងឡាយ ដែលបណ្ឌិតកំណត់ទុក គឺ រាប់បាន ដោយអំណាចនៃការប្រជុំគ្នា ក្នុងធម៌នេះ ព្រោះហេតុនោះ ធម៌ដែលជាទីប្រជុំនៃរូបនេះ ទើបឈ្មោះថា **កលាប** ។

**ឯកុប្បាទា ឯកនិរោធា ឯកនិស្សយា ច សហវុត្តិនោ ឯកវីសតិ រូបកលាបា នាម** : រូប ២១ មានការប្រព្រឹត្តិទៅរួមគ្នា គឺ កើតជាមួយគ្នា រលត់ជាមួយគ្នា មានទីអាស្រ័យជាមួយគ្នា ឈ្មោះថា រូបកលាប ។

កលាប គឺ ក្រុម ពួក ដែលហៅថា សហវុត្តិ ព្រោះប្រកបដោយអង្គ ៣ គឺ ឯកុប្បាទ ឯកនិរោធ ឯកនិស្សយ ។

ក្នុងសង្គហគាថានេះ សម្តែងរូបកលាបទុក ២១ រូប ពិតមែន រូបកលាបទាំងនេះ កាលកើតអំពីកម្មជាដើម

រមែងមិនបែកអំពីគ្នា គឺ រមែងកើតរួមគ្នា ជាក្រុម ៗ ព្រោះដូច្នោះ ដើម្បីសម្តែងការកំណត់រាប់រូបដែលជាក្រុម ៗ និងដើម្បីសម្តែងការសរុប ទើបព្រះអនុរុទ្ធាចារ្យ ពោលថា រូបកលាបមានការប្រព្រឹត្តិទៅរួមគ្នាជាដើម ។

## សង្គហគាថា

៨. កម្មចិត្តោតុកាហារ សមុដ្ឋានា យថាក្កមំ
នវ ឆ ចតុរោ ទ្វេតិ កលាបា ឯកវីសតិ ។

រូបកលាប ២១ មានកម្មជាសមុដ្ឋាន ៩ កលាប. មានចិត្តជាសមុដ្ឋាន ៦ កលាប. មានឧតុ ជាសមុដ្ឋាន ៤ កលាប មានអាហារ ជាសមុដ្ឋាន ២ កលាប ដោយលំដាប់ ដោយប្រការដូច្នេះ ។

៩. កលាបានំ បរិច្ឆេទ លក្ខណត្តា វិចក្ខណា
ន កលាបំ គមិច្ចាហុ អាកាសំ លក្ខណានិ ច ។

បណ្ឌិតអ្នកឃើញប្រចក្ស មិនពោលអាកាស និង

លក្ខណៈ ទាំងឡាយថា ជាអង្គនៃកលាប ព្រោះ អាកាសត្រឹមតែជាគ្រឿងកំណាត់រូប និងលក្ខណៈ ក៏ត្រឹមតែជាគ្រឿងសម្គាល់នៃរូបកលាបទាំងឡាយ ។

## ១-កម្មជកលាប ៩

( រូបកើតអំពីកម្មមាន ៩ កលាប )

១- **ចក្ខុទសកកលាប** ក្រុមនៃចក្ខុប្រសាទមានរូប ១០ មានចក្ខុប្រសាទជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ចក្ខុប្រសាទរូប ១

២- **សោតទសកកលាប** ក្រុមនៃសោតប្រសាទមានរូប ១០ មានសោតប្រសាទជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ សោតប្រសាទរូប ១

៣- **ឃានទសកកលាប** ក្រុមនៃឃានប្រសាទមានរូប ១០ មានឃានប្រសាទជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប

១ ឃានប្រសាទរូប ១

៤- **ជិវ្ហាទសកកលាប** ក្រុមនៃជិវ្ហាប្រសាទមានរូប ១០ មាន ជិវ្ហាប្រសាទជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ជិវ្ហាប្រសាទរូប ១

៥- **កាយទសកកលាប** ក្រុមនៃកាយប្រសាទមានរូប ១០ មាន កាយប្រសាទជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ កាយប្រសាទរូប ១

៦- **ឥត្ថីភាវទសកកលាប** ក្រុមនៃភាពជាស្ត្រី មានរូប ១០ មាន ឥត្ថីភាវរូបជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ឥត្ថីភាវរូប ១

៧- **បុរិសភាវទសកកលាប** ក្រុមនៃភាពជាបុរស មានរូប ១០ មានបុរិសភាវរូបជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ បុរិសភាវរូប ១

៨- **វត្ថុទសកកលាប** ក្រុមនៃវត្ថុមាន ១០ រូប មានហទយ

វត្ថុរូបជាប្រធាន គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ហទយវត្ថុរូប ១

៩- **ជីវិតនវកកលាប** ក្រុមនៃជីវិតមានរូប ៩ មានជីវិតរូបជាប្រធាន គឺ អវិនិព្ភោគរូប ៨ និងជីវិតរូប ១

**អវិនិព្ភោគរូប** រូបមិនបែកអំពីគ្នា មាន៨ គឺ បឋវី អាបោ តេជោ វាយោ វណ្ណៈ គន្ធៈ រសៈ និងឱជា ។ រូបទាំង ៨ នេះ មាននៅប្រចាំក្នុងសមុដ្ឋានទាំង៤ ទើបឈ្មោះថា សុទ្ធដ្ឋកកលាប ។

កម្មជកលាបទាំង ៩ នេះ កើតអំពីកម្មជរូប ១៧ (វៀរបរិច្ឆេទរូប ព្រោះមិនជាអង្គរបស់កលាប) កម្មជកលាប ពួកនេះ កើតដល់ពួកសត្វដែលមានជីវិត ក្នុងម្នាក់ ៗ ក៏កើតបាន មិនលើស៨ កលាប ដោយវៀរភាវទសកកលាប១ ចេញ ព្រោះភាវៈទាំង២ គឺ ភាពជាស្រី និងប្រុស មិនកើតព្រមគ្នា ។

ក្នុងទីនេះ ប្រាថ្នាយកកម្មជកលាបដោយត្រង់ មិនបានប្រាថ្នាយកកម្មប្បច្ចយឧតុជកលាប ។

មួយទៀត គប្បីជ្រាបសេចក្ដីផ្សេងគ្នានៃសព្ទថា កម្មជរូប កម្មជកលាប និងកម្មប្បច្ចយឧតុជកលាប ដូច្នេះ គឺ ៖

កម្មជរូប បានដល់ រូបដែលកើតអំពីកម្មជាសមុដ្ឋាន មាន ១៨ រូប

កម្មជកលាប បានដល់ ក្រុមរូបដែលកើតអំពីកម្ម មាន ១៧ រូប (វៀរបរិច្ឆេទរូប) រាប់ជាកលាប បាន៩ កលាប ។

កម្មប្បច្ចយឧតុជកលាប បានដល់ កលាបដែលកើតអំពីឧតុ មានកម្មជាបច្ច័យ (ដែលនឹងពោលខាងមុខ) ។

## ចែកកម្មជកលាប ៩ ដោយកាយ ៣ ចំណែក

ក្នុងរូបធម៌ គឺ រាងកាយ ចែកចេញជា៣ ចំណែក គឺ ៖

**១-ឧបរិមកាយ** កាយខាងលើ តាំងពីករហូតដល់ក្បាល

**២-មជ្ឈិមកាយ** កាយកណ្ដាល តាំងពីកចុះមកដល់ផ្ចិត

**៣-ហេដ្ឋិមកាយ** កាយខាងក្រោម តាំងពីផ្ចិតចុះដល់ជើង ។

## ឋានរបស់កលាប ក្នុងកាយ ៣ ចំណែក

១- **ឧបរិមកាយ** មានកម្មជកលាបកើត ៧ គឺ

ចក្ខុទសកកលាប សោតទសកកលាប ឃានទសកកលាប កាយទសកកលាប ជិវ្ហាទសកកលាប ភាវទសកកលាប ជីវិតនវកកលាប

២- **មជ្ឈិមកាយ** មានកម្មជកលាបកើត ៤ គឺ

កាយទសកកលាប វត្ថុទសកកលាប ភាវទសកកលាប ជីវិតនវកកលាប

៣- **ហេដ្ឋិមកាយ** មានកម្មជកលាបកើត ៣ គឺ

កាយទសកកលាប ភាវទសកកលាប ជីវិតនវកកលាប ។

កលាប ៣ គឺ កាយទសកកលាប ភាវទសកកលាប ជីវិតនវកកលាប កើតក្នុងកាយទាំង ៣ ចំណែក ដូច្នេះ ទើបហៅថា សព្វដ្ឋានិកកលាប ចំណែកចក្ខុ-សោត-ឃាន-ជិវ្ហាវត្ថុទសកកលាប

ទាំង ៥ នេះ មានសមុដ្ឋានតាំងនៅ ( ១ កន្លែង ) ដូច្នេះ ទើបហៅថា ឯកសមុដ្ឋានកលាប ។

## ២-ចិត្តជកលាប ៦

ចិត្តជកលាប ប្រែថា ក្រុមរូបកើតអំពីចិត្ត ។

ក្នុងអភិធម្មត្ថសង្គហៈ មាន ៦ កលាប គឺ

១-សុទ្ធដ្ឋកកលាប បានដល់ ក្រុមរូប៨ គឺ អវិនិព្ភោគរូប៨

២-កាយវិញ្ញត្តិនវកកលាប បានដល់ ក្រុមរូប ៩ គឺ អវិនិព្ភោគរូប ៨ កាយវិញ្ញត្តិរូប ១

៣-វចីវិញ្ញត្តិសទ្ទទសកកលាប បានដល់ ក្រុមរូប ១០ គឺ អវិនិព្ភោគរូប៨ សទ្ទរូប១ វចីវិញ្ញត្តិរូប១

៤-លហុតាទិឯកាទសកកលាប បានដល់ ក្រុមរូប ១១ គឺ អវិនិព្ភោគរូប ៨ វិការរូប ៣

៥-កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាប បានដល់ ក្រុមរូប ១២ គឺ អវិនិព្ភោគរូប៨ កាយវិញ្ញត្តិរូប១ វិការរូប៣

**៦-វចីវិញ្ញត្តិសទ្ទលហុតាទិតេរសកកលាប** បានដល់ ក្រុមរូប ១៣ គឺ អវិនិព្ភោគរូប ៨ វចីវិញ្ញត្តិរូប១ សទ្ទរូប១ វិការរូប៣

**១- សុទ្ធដ្ឋកកលាប** ជាក្រុមនៃរូបដែលកើតអំពីចិត្តជាសមុដ្ឋាន មានរូបកលាបត្រឹមតែ ៨ រូប ក្រុមនៃរូបនេះ កើតឡើងក្នុងខណៈដែលមិនមានការកម្រើកញ៉ូវកាយ ឬមិនបាននិយាយ បញ្ចេញសំឡេងមកខ្លះនោះ មានរូបដែលត្រឹមតែជាអាការដកដង្ហើមចូល-ចេញ ឬជារូបសម្ដែងមុខស្លូត មុខក្រហមព្រឹមព្រោម បើក្នុងវេលាក្រោធ ក៏ធ្វើឱ្យរូប គួរស្អប់ ឬ គួរខ្លាចជាដើម ។

**២- កាយវិញ្ញត្តិនវកកលាប** ជាក្រុមនៃរូប ៩ រូបដែលកើតអំពីចិត្ត ធ្វើឱ្យកើតការកម្រើកញ៉ូវកាយ ក្នុងឥរិយាបថផ្សេង ៗ មានការដើរ ឈរ អង្គុយ ដេក បត់ លាជាដើម ។

**៣-វចីវិញ្ញត្តិសទ្ទទសកកលាប** បានដល់ ក្រុមនៃរូប ១០ រូប ជារូបដែលកើតក្នុងវេលានិយាយ ច្រៀង សូធ្យ អានសៀវ

កៅធម៌ជាដើម ។

***៤-លហុតាទិឯកាទសកកលាប*** បានដល់ រូបកលាបដែលកើតឡើងក្នុងខណៈដែលមិនមានការកម្រើកញ័រកាយ និងវាចា មានរូបកើត ១១ រូប ។

***៥-កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាប*** បានដល់ រូបកលាបដែលកើតឡើងក្នុងវេលា កម្រើកញ័រកាយ មានអាការផ្សេង ៗ ជារូបសមគួរដល់ការងារ មានរូបកើត ១២ រូប

៦- ***វចីវិញ្ញត្តិសទ្ទលហុតាទិតេរសកកលាប*** បានដល់ ក្រុមរូបដែលកើតឡើងក្នុងខណៈ កម្រើកញ័រវាចាគួរដល់ការងារព្រមទាំងសំឡេងដែលកើតឡើង មានរូបកើត ១៣ រូប ។

## ចិត្តជរូប - ចិត្តជកលាប

ចិត្តជរូប បានដល់ រូបដែលកើតអំពីចិត្ត មាន ១៥ រូប

ចិត្តជកលាប បានដល់ ក្រុមរូបដែលកើតពីចិត្តនោះឯង មាន ១៤ រូប វៀរបរិច្ឆេទរូប បើរាប់ជាកលាប បាន ៦

កលាប ។

ចិត្តជរូប ឬចិត្តជកលាបនេះ កើតក្នុងសត្វដែលមានខន្ធ ៥ និងកើតដោយចិត្ត ៧៥ តាមដែលពោលទុកក្នុងពួកទី ៣ (ដោយរូបសមុដ្ឋានន័យ) ចាត់ជាប្រភេទ បាន ៣ ពួក គឺ ៖

១- ចិត្ត ៧៥ ណាមួយ អាចឱ្យរូបដែលជាសុទ្ធដ្ឋកកលាប កើត ។

២- ចិត្តដែលអាចធ្វើឱ្យចិត្តជកលាប ៤ យ៉ាងកើត គឺ កាយវិញ្ញត្តិនវកកលាប វចីវិញ្ញត្តិសទ្ទទសកកលាប កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាប និង វចីវិញ្ញត្តិសទ្ទលហុតាទិតេរសកកលាប កើតឡើងបានចិត្ត ៣២ គឺ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ អភិញ្ញាចិត្ត ២

៣-ចិត្តដែលអាចឱ្យចិត្តជកលាប ដែលឈ្មោះថា លហុតាទិឯកាទសកកលាប កើតឡើងបានមាន ៥៨ គឺ មនោទ្វារាវជ្ជនចិត្ត ១ កាមជវនចិត្ត ២៩ អភិញ្ញាចិត្ត ២ អប្បនាជវនចិត្ត

២៦

បណ្ដាចិត្ត ៥៨ ណាមួយដែលអាចជាបច្ច័យឱ្យរូបកលាប កើតឡើងបាន ១១ រូប មានមនោទ្វារាវជ្ជនចិត្តជាដើមនោះ ចំពោះអភិញ្ញាចិត្ត ២ គឺ រូបាវចរបញ្ចមជ្ឈានកុសលចិត្ត ១ និង រូបាវចរបញ្ចមជ្ឈានកិរិយាចិត្ត ១ នេះ បាន រួមនៅក្នុង អប្បនាជវនចិត្ត ២៦ នោះឯង តែដែលថែមអភិញ្ញាចិត្ត ២ ចូលមក ទៀត ព្រោះអភិញ្ញាចិត្ត[១]នេះ ដឹងអារម្មណ៍ដែលជា សាមញ្ញក៏មាន ដែលដឹងអារម្មណ៍វិសេសក៏មាន ដើម្បីមិនឱ្យ លាយច្រឡំគ្នា ទើបបានចែកទុកផ្សេងគ្នា ។

ឋានរបស់ចិត្តជកលាប ៦ ក្នុងកាយ ៣ ចំណែក

**១-ក្នុងឧបរិមកាយ** កាយចំណែកលើ មានចិត្តជកលាបកើតបាន

---

១. អភិញ្ញា ៦ គឺ ១.ឥទ្ធិវិធ ២.ទិព្វសោត ៣.ចេតោបរិយញ្ញាណ ៤.បុព្វេនិវាសញ្ញាណ ៥.ទិព្វចក្ខុ ៦.អាសវក្ខយញ្ញាណ ។

ទាំង ៦ កលាប

**២-ក្នុងមជ្ឈិមកាយ** កាយចំណែកកណ្ដាល មានចិត្តជកលាប កើតបាន ៤ កលាប គឺ សុទ្ធដ្ឋកកលាប ១ កាយវិញ្ញត្តិនវកកលាប ១ លហុតាទិឯកាទសកកលាប ១ កាយវិញ្ញត្តិលហុតាទិទ្វាទសកកលាប ១

**៣-ហេដ្ឋិមកាយ** កាយចំណែកក្រោម មានកលាបកើត ៤ ដូចគ្នានឹងទី ២ ។

## ៣-ឧតុជកលាប

**ឧតុជកលាប** ប្រែថា ក្រុមរូបដែលកើតពីឧតុ ។

ក្រុមរូបនេះ មាន ១២ រូប ដោយវៀរបរិច្ឆេទរូប ក៏ឧតុជកលាបនេះ មានទាំងក្នុងកាយ និងខាងក្រៅកាយ ។ ដែលកើតក្នុងកាយសត្វ មាន ៤ កលាប ដែលកើតខាងក្រៅមាន ២ កលាប ។

## ឧតុជកលាប ៤ ដែលកើតខាងក្នុងកាយសត្វ

១. **សុទ្ធដ្ឋកកលាប** បានដល់ ក្រុមរូប ៨ រូប គឺ អវិនិព្ភោគរូប ៨ មានទាំងក្នុង និងខាងក្រៅ ឧតុជកលាបដែលជាខាងក្នុងរាប់ថា ជាកាយរបស់សត្វដែលមានខន្ធ ៥ ព្រោះជាផ្ទៃឋានឱ្យកលាបដទៃ ៗកើតឡើង បើមិនមានឧតុជកលាបហើយកលាបដទៃ ៗ ក៏មិនប្រាកដ ដូច្នេះ ទើបពោលថា ឧតុជកលាប គឺ រាងកាយរបស់សត្វ ។ សុទ្ធដ្ឋកកលាបខាងក្រៅ ដូចដើមឈើ ភ្នំជាដើម ។

២. **សទ្ទនវកកលាប** បានដល់ ក្រុមនៃសទ្ទ មាន ៩ រូប គឺ អវិនិព្ភោគរូប ៨ និងសទ្ទរូប ១ ។ កលាបនេះ កើតបានទាំងខាងក្នុងកាយសត្វ និងខាងក្រៅ សំដៅសេចក្ដីថា កើតជាមួយវត្ថុមានជីវិតក៏បាន មិនមានជីវិត ដូចដើមឈើ ភ្នំជាដើមក៏បាន ដែលកើតខាងក្នុងកាយសត្វ ដែលមិនជាប់ទាក់ទងជាមួយការបញ្ចេញសំឡេង ដូចសំឡេងក្ងពោះ សំឡេងស្រមុក

សំឡេងទះដៃជាដើម ។ សំឡេងប្រាកដខាងក្រៅ បានដល់ សំឡេងខ្យល់បក់ ផ្គរលាន់ និងសំឡេងទឹកហូរជាដើម ។

៣- **លហុតាទិឯកាទសកកលាប** បានដល់ ក្រុមនៃវិការរូបមានរូប ១១ គឺ អវិនិព្ភោគរូប ៨ និងវិការរូប ៣ ក្រុមកលាបនេះ កើតជាមួយសត្វដែលមានជីវិតប៉ុណ្ណោះ មិនកើតក្នុងវត្ថុខាងក្រៅ ។

៤- **សទ្ទលហុតាទិទ្វាទសកកលាប** បានដល់ ក្រុមនៃសទ្ទរូប និងវិការរូប មានរូប ១២ គឺ

អវិនិព្ភោគរូប ៨ និងសទ្ទរូប ១ វិការរូប ៣ ។

កលាបនេះ កើតខាងក្នុងសត្វប៉ុណ្ណោះ មិនកើតខាងក្រៅ តែមិនជាប់ទាក់ទងជាមួយការបញ្ចេញសំឡេង ឬការអានសៀវភៅ ដូចសំឡេងស្រមុក សំឡេងទះដៃ និងសំឡេងទះតប់ជាដើមទេ ។

## ឧតុជកលាប ២ កើតខាងក្រៅ

**១-សុទ្ធដ្ឋកកលាប** បានដល់ អវិនិព្ភោគរូប ៨ ដែលមាននៅក្នុងលោក ដូចក្នុងផែនដី ភ្នំ ដើមឈើ ទន្លេ ភ្លើង ខ្យល់ ព្រះចន្ទ ព្រះអាទិត្យ ផ្កាយ ពន្លឺជាដើម ។

**២-សទ្ទនវកកលាប** បានដល់ សទ្ទរូប ១ អវិនិព្ភោគរូប ៨ ដូចសំឡេងខ្យល់បក់ ផ្គរលាន់ សំឡេងទឹកហូរ សំឡេងរថ សំឡេងទូក និងសំឡេងរគាំងជាដើម ។

## ឋានរបស់ឧតុជកលាបក្នុងកាយ ៣ ចំណែក

**ឧបរិមកាយ** កាយផ្នែកខាងលើ **មជ្ឈិមកាយ** កាយផ្នែកកណ្ដាល **ហេដ្ឋិមកាយ** កាយផ្នែកខាងក្រោម; ទាំង ៣ ចំណែកនេះ មានកលាបកើតបានទាំង ៤ កលាប ចំណែក ២ កលាបទៀត គឺ សទ្ទនវកកលាបនិងសទ្ទលហុតាទិទ្វាទសកកលាបនោះ រមែងកើតក្នុងគ្រាខ្លះ ។

## ឧតុជកលាប ៤ យ៉ាងទៀត

១-កម្មប្បច្ចយឧតុជកលាប បានដល់ ឧតុជកលាបដែលមានកម្មជាបច្ច័យ

២-ចិត្តប្បច្ចយឧតុជកលាប បានដល់ ឧតុជកលាបដែលមានចិត្តជាបច្ច័យ

៣-ឧតុប្បច្ចយឧតុជកលាប បានដល់ ឧតុជកលាបដែលមានឧតុជាបច្ច័យ

៤-អាហារប្បច្ចយឧតុជកលាប បានដល់ ឧតុជកលាបដែលមានអាហារជាបច្ច័យ

ឧតុជកលាបទាំង ៤ នេះ កាលសត្វមានជីវិតហើយ ក៏កើតឡើងក្នុងរាងកាយ គឺ អាការ ៤២ មានសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម ក្នុងសត្វមានស្នែង និងភ្លុកជាដើម រមែងប្រព្រឹត្តទៅតាមគួរដល់ឋានៈ ។

ពិតមែន ឧតុជកលាបទាំង ៤ នេះ មិនមែនរូបដែលកើតអំពីកម្ម ចិត្ត អាហារ, ដោយត្រង់កើតឡើង ព្រោះមានកម្ម

ចិត្ត និងអាហារទាំងនោះឯង ជាបច្ច័យ (ជាសមុដ្ឋាន) ទើបហៅថា កម្មប្បច្ចយឧតុជកលាបជាដើម ព្រោះដូច្នោះ កាលសត្វនោះស្លាប់ កម្មជរូបប៉ុណ្ណោះ រលត់ទៅព្រមជាមួយការស្លាប់, តពីនោះ ចិត្តជរូបក៏រលត់ និងអាហារជរូប ក៏រលត់ទៅដោយលំដាប់ នៅសល់ត្រឹមតែឧតុជកលាបទាំង ៤ នេះ ដែលនឹងនៅរហូតដល់រូបនោះរលាយអស់ទៅ ។

## ៤-អាហារជកលាប ២

១- សុទ្ធដ្ឋកកលាប បានដល់ ក្រុមនៃរូបមាន ៨ រូប កាលសត្វបរិភោគអាហារណា ៗ ចូលទៅហើយ សូម្បីវត្ថុនោះ ៗ ជាថ្នាំក៏ដោយ បើធ្វើឱ្យរាងកាយមិនសប្បាយ មិនវាងវៃ មិនរឹងមាំ មិនគួរដល់ការធ្វើការងារ វត្ថុដែលជាអាហារនេះ ក៏មានត្រឹមតែអវិនិព្ភោគរូប ៨ ប៉ុណ្ណោះ ។

២- លហុតាទិឯកាទសកកលាប បានដល់ ក្រុមនៃវិការរូប មានរូប ១១ កាលសត្វបរិភោគវត្ថុណាចូលទៅហើយ សូម្បីជាថ្នាំក៏ដោយ បើធ្វើឱ្យរាងកាយសប្បាយ វាងវៃ រឹងមាំ គួរដល់

ការធ្វើការងារ ក៏ព្រោះអាហារនេះ មានវិការរូប ៣ កើតរួមផង ។

ម្យ៉ាងទៀត កាលសត្វបរិភោគអាហារប្រភេទណា ចូលទៅក្នុងបណ្តាអាហារ ទាំង ២ នេះ, រមែងធ្វើឱ្យមានអាយុរស់នៅតាមកាលគួរ, ចំណែកឱជា គឺ អាហារដែលជាពហិទ្ធាហារ សត្វនៅមិនបានបរិភោគអាហារ មិនហៅថា អាហារជ្ជកលាប ហៅថាឧតុជ្ជកលាប ព្រោះត្រឹមតែជាដុំនៃរូបដែលកើតអំពីឧតុប៉ុណ្ណោះ ។

## អាហារជ្ជរូប_អាហារជ្ជកលាប

អាហារជ្ជរូប បានដល់ រូបដែលកើតអំពីអាហារមានរូប ១២ តាមដែលពោលហើយ ។

អាហារជ្ជកលាប បានដល់ ក្រុមរូបដែលកើតអំពីអាហារមាន ១១ រូប ដោយវៀរបរិច្ឆេទរូប បើរាប់ជាកលាប បាន ២ កលាប ។

## ឋាននៃអាហារ ២ ក្នុងកាយ ៣ ចំណែក

*ពោលដោយឋាននៃអាហារជកលាប ដែលប្រព្រឹត្តទៅក្នុងកាយ ៣ ចំណែក គឺ ក្នុងឧបរិមកាយ ក្នុងមជ្ឈិមកាយ និងក្នុងហេដ្ឋិមកាយ មានអាហារជកលាប កើតបានទូទៅ ។*

## កលាប ២១ ក្នុងអាការ ៤២

*រូបកលាបដែលកើតអំពីកម្មមាន ៩, កើតអំពីចិត្តមាន ៦, កើតអំពីឧតុមាន ៤, កើតអំពីអាហារមាន ២, រួមជា ២១ កលាប ។ កលាបទាំង ២១ នោះ កាលនៅមានជីវិតរស់នៅ រមែងកើតប្រព្រឹត្តទៅក្នុងអាការ ៤២ ដូច្នេះ គឺ*

### ១. *សសម្ភារបឋវី* ២០ មាន ២ ន័យ គឺ

**១, ឧទរិយំ** *អាហារថ្មី* **ករីសំ** *អាហារចាស់ មានរូបកលាបកើត ១ គឺ ឧតុសុទ្ធដ្ឋកកលាប ១ មានរូប ៨ ប៉ុណ្ណោះ គឺ អវិនិព្ភោគរូប ៨*

២, អាការ ១៨ ដែលនៅសល់ កើតអំពីកម្ម ចិត្ត ឧតុ និងអាហារ រួម ៥ កលាប រាប់រូបបាន ៤៤ រូប គឺ

កាយទសកកលាប ១ ជាកម្មជកលាប មានរូប ១០

ភាវទសកកលាប ១ ជាកម្មជកលាប មានរូប ១០

ចិត្តសុទ្ធដ្ឋកកលាប ១ ជាចិត្តជកលាប មានរូប ៨

ឧតុសុទ្ធដ្ឋកកលាប ១ ជាឧតុជកលាប មានរូប ៨

អាហារសុទ្ធដ្ឋកកលាប១ ជាអាហារជកលាប មានរូប៨

**២. សសម្ភារអាបោ ១២ មាន ៣ ន័យ គឺ**

១, អាការ ៦ គឺ **បិត្តំ សេម្ហំ លោហិតំ មេទោ វសា លសិកា** នេះ មាន រូបកលាបកើត ៥ កលាប រាប់ជារូបបាន ៤៤ ដូចសសម្ភារបឋវីទី ២. ន័្យឯង ។

២, អាការ ៤ គឺ **សេទោ អស្សុ ខេឡោ សិង្ឃាណិកា** នេះ មានរូបកលាបកើត ២ រាប់ជារូប បាន ១៦ គឺ ចិត្តសុទ្ធដ្ឋកកលាប ១ ជាចិត្តជកលាប មានរូប ៨, ឧតុសុទ្ធដ្ឋកកលាប

១ ជាឧតុជកលាប មានរូប ៨

៣, អាការ ២ គឺ **បុញ្ញោ មុត្តំ** មានរូបកលាបកើត ១ គឺ ឧតុសុទ្ធដ្ឋកកលាប រាប់ជារូបបាន ៨ គឺ អវិនិព្ភោគរូប ៨ ។

## ៣. សសម្ភារតេជោ ៤ មាន ២ ន័យ គឺ

១-អាការ ៣ គឺ **ឧស្មាតេជោ ជីរណតេជោ សន្តាបនតេជោ** រាប់ជារូបបាន ៣៣ គឺ

ជីវិតនវកកលាប ១ ជាកម្មជកលាប មានរូប ៩

ចិត្តសុទ្ធដ្ឋកកលាប ១ ជាចិត្តជកលាប មានរូប ៨

ឧតុសុទ្ធដ្ឋកកលាប ១ ជាឧតុជកលាប មានរូប ៨

អាហារសុទ្ធដ្ឋកកលាប ១ ជាអាហារជកលាប មានរូប៨

២- អាការ ១ គឺ **បាចកតេជោ** មានរូបកលាប ១ គឺ ជីវិតនវកកលាប រាប់ជារូបបាន ៩ គឺ អវិនិព្ភោគរូប ៨ ជីវិតរូប ១ ។

## ៤. សសម្ភារវាយោ ៦ មាន ២ ន័យ គឺ

១- អាការ ៥ គឺ **ឧទ្ធង្គមវាយោ អធោគមវាយោ កុច្ឆិសយវាយោ កោដ្ឋាសយវាយោ អង្គមង្គានុសារិវាយោ** ៥ កោដ្ឋាសនេះ កើតបាន ៤ សមុដ្ឋាន មានរូប ៤ កលាប រាប់រូបបាន ៣៣ ដូចសសម្ភារតេជោទី ១ នុ៎ះឯង ។

២- អាការ គឺ **អស្សាសបស្សាសវាយោ** មានរូបកលាប ១ រាប់ជារូបបាន ៩ គឺ ចិត្តសមុដ្ឋកកលាប មានរូប ៨ និងសទ្ទរូប ១

## រូបកលាប ២១ ក្នុងសសម្ភាររូប ៥

រូបកលាបដែលកើតពីកម្ម ចិត្ត ឧតុ អាហារជាសមុដ្ឋាន គឺ

**១-ចក្ខុសសម្ភារ** មានរូបកលាបកើត ៦ រាប់ជារូបបាន ៥៤ គឺ ៖

| | | | |
|---|---|---|---|
| ចក្ខុទសកកលាប | ១ | កើតពីកម្ម | មានរូប ១០ |
| ភាវទសកកលាប | ១ | កើតពីកម្ម | មានរូប ១០ |

កាយទសកកលាប ១ កើតពីកម្ម មានរូប ១០
ចិត្តសុទ្ធដ្ឋកកលាប ១ កើតពីចិត្ត មានរូប ៨
ឧតុសុទ្ធដ្ឋកកលាប ១ កើតពីឧតុ មានរូប ៨
អាហារសុទ្ធដ្ឋកកលាប ១ កើតពីអាហារ មានរូប ៨

**២-សោតសសម្ភារៈ** មាន ៦ កលាប រាប់បាន ៥៤ រូប

**៣-ឃានសសម្ភារៈ** មាន ៦ កលាប រាប់បាន៥៤រូប

**៤-ជិវ្ហាសសម្ភារៈ** មាន ៦ កលាប រាប់បាន ៥៤ រូប ដូចគ្នានឹងចក្ខុសសម្ភារៈ

**៥-កាយសសម្ភារៈ** មានរូបកលាបកើតបាន ៥ រាប់ជារូបបាន ៤៤ ដូចគ្នានឹងទី ១ (គឺ ចក្ខុសសម្ភារៈ) ដោយវៀរចក្ខុប្រសាទ សោតប្រសាទ ឃានប្រសាទ ជិវ្ហាប្រសាទ មានតែកាយប្រសាទ ព្រោះកាយសសម្ភារៈមិនមានចក្ខុ សោត ឃាន និងជិវ្ហាប្រសាទ តែក្នុងចក្ខុសសម្ភារៈ សោតសសម្ភារៈ ឃានសសម្ភារៈ ជិវ្ហាសសម្ភារៈ មានកាយប្រសាទ កើតរួមផង ។

## ការបរិភោគអាហារ

មនុស្សបរិភោគអាហារបាន មានពិតឬ ?

ដោយបរមត្ថសច្ចៈ មនុស្សបរិភោគអាហារមិនបាន បើដោយសម្មតិសច្ចៈ មនុស្សបរិភោគអាហារបាន ព្រោះមនុស្សត្រឹមតែជាឧបាទាបញ្ញត្តិ អាហារជាបរមត្ថសច្ចៈ ដែលត្រូវគួរហៅថា យករូបធាតុខាងក្រៅ ដាក់ចូលទៅខាងក្នុងតែជាសច្ចៈដែលជ្រាលជ្រៅពេក ទើបព្រះមានព្រះភាគទ្រង់សម្តែងដោយសុត្តន្តន័យថា មនុស្សបរិភោគអាហារ ។

ដើមឈើ បរិភោគអាហារឬ ?

ដើមឈើ មិនបានបរិភោគអាហារ ដោយបរមត្ថសច្ចៈ ដើមឈើមិនមាន តែអាហារមានរូបកើតអំពីឧតុ ដោយវោហារ ហៅថាដើមឈើ ក៏ដើមឈើនេះ អាស្រ័យអាហារ គឺឧតុជរូបជាបច្ច័យ ទើបចម្រើន មានផ្កា មានផ្លែបាន មិនមែនដើមឈើស៊ីអាហារតាមដែលយល់មកដូចពាក្យថា រថយន្តស៊ីសាំងជាដើមនោះទេ ។

**ចប់ រូបន័យទី ៤ រូបកលាប**

# រូបន័យទី ៥ រូបបវត្តិក្កម

រូបបវត្តិក្កមន័យ ជាន័យដែលសម្តែងលំដាប់នៃការប្រព្រឹត្តិទៅរបស់រូប ដោយសេចក្តីផ្សេងគ្នានៃភព កាល និងសត្វ ។

រូបធម៌ ២៨ រមែងកើតក្នុងភូមិទាំងឡាយ តាមសមគួរ ក្នុងបវត្តិកាល រមែងមិនខ្វះខាត តែថា ក្នុងបដិសន្ធិកាលពោលដោយឧក្កដ្ឋន័យ (ន័យដែលមិនខ្វះខាត) រូបធម៌ទាំងឡាយរមែងកើតបានគ្រប់ តាមដែលពោលមកតែកាលពោលដោយឱមកន័យ (ន័យដែលខ្វះខាត)រូបធម៌ រមែងខ្វះ ទៅតាមភូមិនិងឋាននោះ ៗ ។

កាលបន្តនៃរូបកលាបរបស់សត្វដែលមានកម្មជាសមុដ្ឋាន ចាប់តាំងអំពីបដិសន្ធិកាល ។

ដែលមានចិត្តជាសមុដ្ឋាន ចាប់តាំងអំពីចិត្តទី ២ គឺ ឧប្បាទក្ខណៈ របស់បឋមភវង្គចិត្ត ។

ដែលមានឧតុជាសមុដ្ឋាន ចាប់តាំងអំពីឋិតិខណៈរបស់បដិសន្ធិចិត្ត ។

និងដែលមានអាហារជាសមុដ្ឋាន ចាប់តាំងអំពីឱជាដែលផ្សាយជ្រួតជ្រាបចូលទៅក្នុងសរីរៈ ។

សមុដ្ឋានទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងភូមិដែលប្រព្រឹត្តទៅបានដោយមិនដាច់ខ្សែ រហូតដល់អស់អាយុក្ខ័យ ដូចអណ្តាតភ្លើងដែលកំពុងឆេះសន្ធោសន្ធៅ និងដូចក្រសែទឹកដែលកំពុងជន់ដូច្នោះ ។

តែក្នុងមរណសម័យ សមុដ្ឋានទាំងឡាយ ដូចភ្លើងដែលកំពុងរលត់ ព្រោះកម្មជកលាប មិនកើតឡើង ផ្តើមតាំងអំពីឋិតិខណៈរបស់ចិត្តទី ១៧ ដូចចុតិចិត្ត, ចំណែកកម្មជរូបដែលកើតមុននោះ រមែងប្រព្រឹត្តទៅរហូតដល់ចុតិចិត្តនោះឯង ហើយរលត់ទៅព្រមជាមួយចុតិចិត្ត, តពីនោះ ចិត្តជរូប ក៏ប្រព្រឹត្តទៅរហូតអស់អាយុហើយរលត់ទៅ, តពីនោះ អាហារជរូបក៏ប្រព្រឹត្តទៅ

រហូតអស់អាយុ, កាលអាហារដាច់អស់ក្នុងភពនេះហើយ ការបន្ត នៃរូបក៏មានតែឧតុជរូបប៉ុណ្ណោះ នៅប្រព្រឹត្តទៅរហូតដល់ជាសាកសពដែលត្រូវបោះចោល ទុកដូចកំណាត់ឈើគ្មានប្រយោជន៍ ដូចពាក្យដែលព្រះធម្មសេនាបតីសារីបុត្តពោលទុកថា ៖

**អាយុ ឧស្មា ច វិញ្ញាណំ យទា កាយំ ជហន្តិមំ**
**អបវិទ្ធោ តទា សេតិ និរត្ថំវ កលិង្គរំ ។**

អាយុក្តី ភ្លើងធាតុក្តី វិញ្ញាណក្តី តែលះបង់នូវកាយនេះ ទៅក្នុងកាលណាហើយ (កាយនេះ ក៏ដល់នូវសេចក្តីមិនគួរទើងទុកដាក់ ឱ្យនៅលើផ្ទះសម្បែងបានឡើយ) គេតែងនាំយកទៅចោលឱ្យដេកនៅលើផែនដី ក្នុងកាលណោះឯង ដូចអង្កត់ឧសរកប្រយោជន៍គ្មានឡើយ ដូច្នេះ ។

## សង្គហគាថា

១០. ឥច្ចេវំ មតសត្តានំ បុនទេវ ភវន្តរេ
បដិសន្ធិមុបាទាយ តថារូបំ បវត្តតិ ។

រូបរបស់ពួកសត្វក្នុងលោកនេះ ដែលស្លាប់ហើយ រមែងប្រព្រឹត្តទៅយ៉ាងនោះ ក្នុងភពថ្មីទៀតទុំះឯង ព្រោះអាស្រ័យបដិសន្ធិ មានសេចក្ដីដូចដែលពោលមក ដូច្នេះ ។

ក្នុងបវត្តិក្កមន័យនេះ មានអត្ថសម្ដែងលំដាប់នៃការប្រព្រឹត្តិទៅរបស់រូបដោយអាការ ៣ យ៉ាង គឺ ៖

១- សម្ដែងរូបដោយភូមិ ២៧
២- សម្ដែងរូបដោយកាល ៣
៣- សម្ដែងរូបដោយកំណើត ៤

## ១~សម្តែងរូបដោយភូមិ ២៧

ភូមិ គឺ កន្លែងជាទីកើតរបស់រូបធម៌ ២៧ ភូមិ ក្នុងរូបបវត្តិក្កមន័យ តាមដែលពោលទុកក្នុងសង្គហគាថាទី ១១ ថា ៖

### សង្គហគាថា

១១ អដ្ឋវីសតិ កាមេសុ ហោន្តិ តេវីស រូបិសុ
សត្តរសេវាសញ្ញីនំ អរូបេ នត្ថិ កិញ្ចិបិ ។

ក្នុងកាមភូមិ ១១ មានរូបកើតបាន ២៨. ក្នុងរូបភូមិ ១៥ (វៀរអសញ្ញសត្តភូមិ) មានរូបកើតបាន ២៣. ក្នុងអសញ្ញសត្តភូមិ ១ មានរូបកើតបាន ១៧ ក្នុងអរូបភូមិ មិនមានរូបអ្វី ៗ កើតឡើងឡើយ ។

បណ្ដាភូមិ ២៧ ដែលឱ្យកើតរូបធម៌ គឺ

១- កាមភូមិ ១១ គឺ អបាយភូមិ ៤ និងសុគតិភូមិ ៧ នេះ កាលពោលដោយឧក្កដ្ឋន័យ (ន័យដោយឧក្រិដ្ឋ) មានរូបកើត បាន ២៧ (វៀរភាវរូប), កាលពោលដោយឱមកន័យ ក៏មានរូបណាមួយខ្វះខាត តាំងអំពីបដិសន្ធិកាល ។

២- រូបភូមិ ១៥ បឋមជ្ឈានភូមិ ៣ ទុតិយជ្ឈានភូមិ ៣ តតិយជ្ឈានភូមិ ៣ ចតុត្ថជ្ឈានភូមិ ៦ (វៀរអសញ្ញសត្តភូមិ) មានរូបកើតបាន ២៣ រូប ដោយវៀររូបទាំង ៥ នេះ គឺ ៖

១-ឃានប្រសាទរូប ២-ជិវ្ហាប្រសាទរូប ៣-កាយប្រសាទរូប ៤-ឥត្ថីភាវរូប ៥-បុរិសភាវរូប

រូបទាំង៥នេះ ចំណែកច្រើនប្រព្រឹត្តទៅក្នុងការឧបត្ថម្ភ ជួយកាមគុណារម្មណ៍ និងជាឧបនិស្សយរបស់កាមរាគៈយ៉ាងខ្លាំងក្លា ទើបមិនកើតក្នុងរូបព្រហ្មភូមិ ចំណែកចក្ខុប្រសាទរូប និងសោតប្រសាទរូបទាំង ២ នេះ មានប្រយោជន៍ដល់ព្រហ្មបុគ្គលជា

ចំណែកច្រើន គឺ ក្នុងកាលគ្រាខ្លះ រមែងឱ្យបានទស្សនានុត្តរិយ និងសវនានុត្តរិយជាដើម និងមគ្គ ផល និព្វាន ។

រូប ២៣ ដែលកើតដល់ព្រហ្មបុគ្គលទាំងនោះ ជារូបដែលមានប្រសិទ្ធិភាពល្អ មិនមានការខ្វះខាត ដោយមានការឃើញបានឆ្ងាយ និងឃើញបានច្បាស់ជាដើម ។

៣- <u>អសញ្ញសត្តភូមិ</u> មានរូបកើតបាន ១៧ រូប បានដល់ អវិនិព្ភោគរូប ៨ មានជីវិតរូប ១ បរិច្ឆេទរូប ១ វិការរូប ៣ និងលក្ខណរូប ៤ ។

៤- <u>អរូបភូមិ ៤</u> ជាភូមិរបស់អរូបព្រហ្មបុគ្គល មិនមានរូបណា ៗកើតឡើងទេ ដោយអំណាចនៃរូបវិរាគភាវនា ព្រោះមិនត្រេកអរ មិនប្រាថ្នា ក្នុងរូបធម៌ទាំងពួង ដូច្នេះ ពួកអរូបព្រហ្មបុគ្គល ទើបមិនមានរូប សូម្បីភូមិដែលឈ្មោះថា អរូបភូមិ ក៏មិនមានរូបដែរ តាមគាថាសង្គហៈដែលពោលថា "**អរូបេ នត្ថិ កិញ្ចិបិ**" ។

## ចែករូប ២៨ ក្នុងកាមភូមិ ១១ ដោយសមុដ្ឋាន ៤

រូប ២៨ ដែលកើតក្នុងកាមភូមិ ១១ ភូមិ កាលចែកដោយសមុដ្ឋាន៤ បានរូបចំនួន៥៨ រូប ដូច្នេះ គឺ កម្មជរូប ១៨ ឧតុជរូប ១៣ ចិត្តជរូប ១៥ អាហារជរូប ១២ ។

រូបដែលកើតអំពីសមុដ្ឋានទាំង ៤ នេះ សមុដ្ឋានមួយ ៗ មានលក្ខណរូបទាំង ៤ នៅជាមួយគ្រប់ ៗ សមុដ្ឋាន គឺ ក្នុងកម្មជរូប ១៨ មានឧបចយកម្មជរូប សន្តតិកម្មជរូប ជរតាកម្មជរូប អនិច្ចតាកម្មជរូប ។

សូម្បីក្នុងចិត្តជរូប ឧតុជរូប និងអាហារជរូប ក៏ប្រព្រឹត្តទៅក្នុងទំនងតែមួយ កាលរួមលក្ខណរូប ៤ ដែលនៅក្នុងសមុដ្ឋាន ៤ ត្រូវជារូប ១៦ (៤ × ៤) និង ១៦ រូបនេះ រួមជាមួយសមុដ្ឋានិករូប ៥៨ ត្រូវជារូប ៧៤ រូប ។ រូបទាំង ៧៤ នេះ កាលរាប់តាមធម្មតា ក៏បានរូប ២៨ នោះឯង ។

## ន័យមួយទៀត រាប់សមុដ្ឋានិករូបដោយពិស្តារ

១- កម្មជរូប ១៨ មាននិប្ផន្នរូប ១៧ (វៀរបរិច្ឆេទរូប) រូបនីមួយ ៗ មានលក្ខណរូប ៤ ផង (១៧ × ៤) ទើបរួមលក្ខណរូបទាំងអស់បាន ៦៨ កម្មជរូបទាំងអស់ ១៨ រួមជាកម្មជរូបទាំងអស់ ៨៦ ។

២-ចិត្តជរូប ១៥ មាននិប្ផន្នរូប ៩ (វៀរ ៦ រូប)រូបនីមួយ ៗ មានលក្ខណរូប ៤ ផង (៩ × ៤) ទើបរួមលក្ខណរូបទាំងអស់បាន ៣៦ រូប ចិត្តជរូបទាំងអស់ ១៥ រួមជាចិត្តជរូបទាំងអស់ ៥១ ។

៣-ឧតុជរូប ១៣ មាននិប្ផន្នរូប ៩ (វៀរ ៤ រូប) រូបនីមួយ ៗ មានលក្ខណរូប ៤ ផង ទើបរួមលក្ខណរូបទាំងអស់បាន ៣៦ រូប ឧតុជរូបទាំងអស់ ១៣ រួមជាឧតុជរូបទាំងអស់ ៤៩ ។

៤-អាហារជរូប ១២ មាននិប្ផន្នរូប ៨ (វៀរ ៤ រូប)

រូបមួយ ៗ មានលក្ខណរូប ៤ ផង ទើបរួមលក្ខណរូបទាំងអស់បាន ៣២ អាហារជរូបទាំងអស់ ១២ រួមជាអាហារជរូបទាំងអស់ ៤៤ ។

## ចែករូប ២៣ ក្នុងរូបភូមិ ១៥ ដោយសមុដ្ឋាន ៣

រូប ២៣ ដែលកើតក្នុងរូបភូមិ ១៥ នោះ កាលចែកដោយសមុដ្ឋានបាន ៣ សមុដ្ឋាន គឺ ៖

កម្មជរូប ១៣ ( កើតមិនបាន ៥ រូប ) ចិត្តជរូប ១៥ ឧតុជរូប ១៣

វៀរអាហារជរូប ១២ រូប ព្រោះពួកព្រហ្មបុគ្គល មិនបរិភោគអាហារ ។ បណ្តារូបទាំង ២៣ នេះ កាលចែកដោយសមុដ្ឋាន ៣ និងបានរូបរួម ៤១ និងកាលរួមជាមួយលក្ខណរូប ១២ ( ៣ × ៤ ) ទើបជារូប ៥៣ តែបើរាប់យ៉ាងធម្មតា ក៏បាន ២៣ ប៉ុណ្ណោះ ។

**ចែករូប ១៧ ដែលកើតក្នុងអសញ្ញសត្តភូមិ ដោយសមុដ្ឋាន ២**

រូបដែលកើតក្នុងអសញ្ញសត្តភូមិ មាន ១៧ កាលចែកដោយសមុដ្ឋានបាន ២ គឺ ៖

មានកម្មជាសមុដ្ឋាន និងឧតុសមុដ្ឋាន ពួកអសញ្ញសត្តព្រហ្ម មិនមានចិត្ត មិនមានបរិភោគអាហារ ទើបមិនមានចិត្ត និងអាហារជាសមុដ្ឋាន ។

សមុដ្ឋានទាំង ២ នោះ ចែកហើយ ទើងបានដូច្នេះ គឺ ៖

+ កម្មជរូប មាន ១០ រូប គឺ អវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ ជីវិតរូប ១

+ ឧតុជរូប ១២ រូប គឺ អវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ វិការរូប ៣ (វៀរសទ្ទរូប)

រួមរូបដែលកើតក្នុងអសញ្ញសត្តភូមិ ២២ រូប និងកាលរួមលក្ខណរូប ៨ (២ × ៤) ក៏ជារូប ៣០

ក៏កាលរាប់យ៉ាងធម្មតា ក៏ទើងបាន ១៧ រូបនោះឯង ។

## ២-សម្តែងរូបដោយកាល ៣

រូបទាំងអស់ ២៨ ក្នុងកាមភូមិ ១១ រូបណាខ្លះ ដែលបានកាល ៣ (បដិសន្ធិកាល បវត្តិកាល និងចុតិកាល) គឺមានរូបណា ដែលកើតបាន និងកើតមិនបាននោះ គប្បីជ្រាបតាមន័យនៃសង្គហគាថាដែលនឹងពោលតទៅ ៖

បដិសន្ធិកាល បានដល់ វេលាដែលនាមរូបបដិសន្ធិគ្រាដំបូង

បវត្តិកាល បានដល់ វេលាដែលនាមរូបកើតរលត់ប្រព្រឹត្តទៅ

ចុតិកាល បានដល់ វេលាដែលនាមរូបឃ្លាតចាកភព ។

### សង្គហគាថា

១២ សទ្ទោ វិការោ ជរតា មរណញ្ចោបបត្តិយំ

ន លព្ភន្តិ បវត្តេ តុ ន កិញ្ចិបិ ន លព្ភន្តិ ។

សទ្ទរូប ១ វិការរូប ៥ (គឺ វិញ្ញត្តិរូប ២ និងវិការរូប ៣) ជរតារូប ១ អនិច្ចតារូប ១ រួមជា ៨ មិនកើត

ក្នុងខណៈបដិសន្ធិ ចំណែកក្នុងបវត្តិកាលរូបណា ៗ ដែលមិនបានកើត មិនមាន ។

## អធិប្បាយ សង្គហគាថា

១- ក្នុងបដិសន្ធិកាល (របស់គព្ភសេយ្យកសត្វ) សម្ដែងដល់រូបដែលកើតមិនបានទុក ៨ រូប ព្រោះក្នុងខណៈនោះ សំឡេងមិនមាន ការនិយាយ ការកម្រើកញ័រកាយ ភាពស្រាល ភាពទន់ ភាពគួរដល់ការងារទាំងនេះ នៅមិនកើត ព្រោះដូច្នោះ រូបដែលកើតឡើងក្នុងខណៈបដិសន្ធិទើបបាន ២០ រូប គឺ ៖

ប្រសាទរូប ៥ ភាវរូប ២ ហទយរូប ១ ជីវិតរូប ១ អវិនិព្ភោគរូប ៨ បរិច្ឆេទរូប ១ ឧបចយរូប ១ សន្តតិរូប ១ ; រូបធម៌ទាំង ២០ នេះ កើតអំពីកម្មជាសមុដ្ឋានតែម្យ៉ាង ។

ចំណែករូបដែលកើតអំពីចិត្ត ឧតុ និងអាហារ ទាំង ៣ សមុដ្ឋាននេះ មិនកើតក្នុងបដិសន្ធិកាល តែកាលសម្ដែងដោយ

ឧប្បាទក្ខណៈរបស់បដិសន្ធិចិត្ត ចំនួនរូបទាំងឡាយ រមែងកើតបាន តាមសមគួរដល់ភូមិ និងកំណើតរបស់សត្វនោះ ៗ ។

ក្នុងអដ្ឋកថា និងដីកា សម្ដែងរូបដែលកើតមិនបាន ក្នុងបដិសន្ធិកាល ៩ រូប ដោយបន្ថែមសន្តតិរូប ១ រូបទៀត កាលបើដូច្នេះ រូបដែលកើតក្នុងបដិសន្ធិកាល ទើបនៅសល់ ១៩ រូប ។

២- ក្នុងបវត្តិកាល រូបទាំងអស់ ២៨ រមែងកើតបាន តាមសមគួរដល់ភូមិ និងកំណើតរបស់សត្វនោះ ៗ រូប ២៨ ក្នុងបវត្តិកាលនេះ រមែងបានសមុដ្ឋានទាំង ៤ គឺ កម្មជរូប ចិត្តជរូប ឧតុជរូប និងអាហារជរូប ។

៣- ក្នុងចុតិកាល គឺ ក្នុងសម័យជិតស្លាប់ រូបដែលកើតមិនបាន មាន ២ សមុដ្ឋាន គឺ ៖

១. កម្មជរូបទាំងអស់របស់សត្វទាំងពួង

២. ចិត្តជរូបចំពោះរបស់ព្រះអរហន្ត

ចំណែករូបដែលកើតតទៅ មាន ៣ សមុដ្ឋាន គឺ ៖

១- ចិត្តជរូបរបស់សត្វក្នុងបញ្ចវោការភូមិ (វៀរចុតិចិត្តរបស់ព្រះអរហន្ត) គឺ កាលកម្មជរូប រលត់ទៅព្រមនឹងភង្គខណៈនៃចុតិចិត្ត ហៅថា សត្វស្លាប់ហើយ តែរូបដែលកើតព្រមគ្នានឹងឧប្បាទក្ខណៈនៃចុតិចិត្តនោះ ក៏តាំងនៅតទៅ បន្តិចបន្តួចទៀត ហើយក៏រលត់ទៅ ។

២- អាហារជរូប ក្នុងឋិតិខណៈនៃចុតិចិត្តនោះឯង អាហារជរូប ១ អនុខណចិត្តកើតខាងចុងបំផុត តពីនោះ អាហារជរូបនោះ ក៏តាំងនៅរហូត ៥០ អនុខណចិត្ត អស់អាយុរបស់ខ្លួនហើយរលត់ទៅ ។

៣- ឧតុជរូប ៤ ប្រភេទ គឺ ៖

១-កម្មបច្ចយឧតុជរូប គឺ ឧតុជរូបដែលមានកម្មជាបច្ច័យ
២-ចិត្តបច្ចយឧតុជរូប គឺ ឧតុជរូបដែលមានចិត្តជាបច្ច័យ
៣-ឧតុបច្ចយឧតុជរូប គឺ ឧតុជរូបដែលមានឧតុជាបច្ច័យ
៤-អាហារបច្ចយឧតុជរូប គឺ ឧតុជរូបដែលមានអាហារជាបច្ច័យ ។

ចតុជរូប គឺ រូបដែលកើតអំពីសមុដ្ឋាន ៤ មានសក់ រោម ក្រចក ធ្មេញ ស្បែកជាដើម

កាលតិជរូប គឺ រូបដែលកើតអំពីកម្ម ចិត្ត អាហារ រលត់អស់ហើយ ឧតុជរូប គឺ សក់ រោម ក្រចក ធ្មេញ ស្បែកជាដើម ទាំងអស់នេះ រមែងតាំងនៅរហូតដល់សាកសពនោះបែកធ្លាយ រឡេះរលួយ ពុកផុយទៅ ។

## ៣-សម្តែងរូប ២៨ ដោយកំណើត ៤

បណ្តាសព្វសត្វដែលកើតឡើងក្នុងភូមិផ្សេង ៗនោះ កាលសម្តែងដោយកំណើត គឺ យោនិ មាន ៣ ឬ ៤ ក៏មានអត្ថដូចគ្នា គឺ

### យោនិ កំណើត ៣

**១- សំសេទជកំណើត** បានដល់ កើតក្នុងកម្មេចក្អែល ក្នុងជ័រស្អិតក្នុងផ្លែឈើ

**២- ឱបបាតិកកំណើត** បានដល់ កំណើតផុសឡើង ចម្រើនពេញទី(ធំពេញ រូបរាងភ្លាម)

**៣- គព្ភសេយ្យកកំណើត** បានដល់ កើតក្នុងគភ៌ មាន ២ គឺ អណ្ឌជកំណើត កើតក្នុងស៊ុត១ ជលាពុជកំណើត កើតក្នុងស្បូន១

## យោនិ កំណើត ៤

១- សំសេទជកំណើត ២- អណ្ឌជកំណើត

៣- ឱបបាតិកកំណើត ៤-ជលាពុជកំណើត

## អធិប្បាយ កំណើត ៤

១-សំសេទជកំណើត បានដល់ សត្វទាំងឡាយ ដែលបដិសន្ធិដោយមិនអាស្រ័យមាតាបិតា គឺ អាស្រ័យលើដើមឈើខ្លះ ផ្កាឈើខ្លះ ផ្លែឈើខ្លះ អាស្រ័យលោហិត និងក្អែលជាដើមខ្លះ ដូចចិញ្ចាមាណវិកា កើតអំពីដើមអំពិល, នាងវេឡុវតី កើតពីដើមឫស្សី, នាងបុទុមវតី កើតអំពីផ្កាឈូក, ឱរសរបស់នាងបុទុមវតី

៥០០, ៤៩៩ នាក់ កើតអំពីញើស, ម្នាក់កើតក្នុងភគិ, ពួកជន្ទូវទាំងឡាយ កើតអំពីផ្លែឈើនិងក្អែល, សត្វដែលបដិសន្ធិដោយសំសេទជកំណើតនេះ មិនបានកើតឡើងមានរាងកាយធំភ្លាមទេ គឺកើតជាទារកតូច ៗ មុនសិន ហើយចម្រើនធំឡើងបន្តបន្ទាប់ ដូចពួកគត្ភសេយ្យកនោះឯង ។

ម្យ៉ាងទៀត សត្វដែលជាសំសេទជកំណើតនេះ កើតក្នុងមនុស្សភូមិនេះក៏មាន ក្នុងទេវតាជាន់ទាប គឺ ភុម្មទេវតាក៏មាន ក្នុងកំណើតសត្វតិរច្ឆានក៏មាន ក្នុងបិត្តិវិស័យ (វៀរនិជ្ឈាមតណ្ហិកប្រេត)ក៏មាន និងក្នុងអសុរកាយក៏មាន ។ ចំណែកទេវតាខ្ពស់ ៗ និងនរកកើតដោយឧបបាតិកកំណើត ។

២- ឧបបាតិកកំណើត ពួកឧបបាតិកកំណើតអាស្រ័យអតីតកម្មតែម្យ៉ាងកើតឡើង កាលកើត ក៏កើតផុសឡើងមានរាងកាយពេញភ្លាម ដូចហោះមកអំពីភពដទៃ ឬដូចធ្លាក់អំពីទីខ្ពស់ សត្វដែលជាឧបបាតិកកំណើត មាន ៥ ពួក គឺ ពួកមនុស្សក្នុង

សម័យដើមកប្បា១ ទេវតា ៦ ជាន់ វៀរជាន់ទាបពួកខ្លះ១ ពួកព្រហ្មទាំងអស់១ ពួកប្រេតនិងនិជ្ឈាមតណ្ហិកប្រេត១ ពួកអសុរកាយ និងសត្វនរកទាំងអស់១ ។

៣- អណ្ឌជកំណើត ពួកសត្វដែលបដិសន្ធិដោយអណ្ឌជកំណើត អាស្រ័យគភ៌(ផ្ទៃពោះ)របស់មាតានោះ កើតហើយក្នុងស៊ុតមុន កាលប្រសូតអំពីគភ៌ហើយ ទើបចេញអំពីស៊ុតម្ដងទៀត ហៅសត្វប្រភេទនេះថា ទ្វិជកំណើត (កើត ២ ដង) បានដល់បក្សី ទា មាន់ ជីងចក់ តុកកែ និងពស់ជាដើម ។

ម្យ៉ាងទៀត សត្វដែលជាអណ្ឌជកំណើតនេះ មានច្រើនពួក គឺ ជាសត្វតិរច្ឆានខ្លះ ប្រេតពួកខ្លះ អសុរកាយពួកខ្លះ ទេវតាជាន់ទាបខ្លះ ពួកខ្លះសូម្បីជាមនុស្សក៏មាន ។

ក្នុងធម្មបទពោលថា ៖

ព្រះភិក្ខុ ២ រូប ឈ្មោះថា ទ្វេភាតិកត្ថេរ ជាកូនរបស់កោនតកិន្នរី គឺ លោកបដិសន្ធិគ្រាដំបូង កើតហើយក្នុងស៊ុតមុន កាល

ស៊ុតចេញអំពីគភ៌ហើយ ទើបចេញពីស៊ុតម្ដងទៀត ។

៤-ជលាពុជកំណើត ពួកសត្វដែលបដិសន្ធិដោយជលាពុជកំណើតអាស្រ័យមាតាកើតក្នុងស្បូន ជាខ្លួនតូច ៗ ហើយធំឡើងបន្តបន្ទាប់តាមលំដាប់ បានដល់ មនុស្ស សត្វតិរច្ឆាន ទេវតាពួកខ្លះ ប្រេតពួកខ្លះ (វៀរនិជ្ឈាមតណ្ហិកប្រេត) និងអសុរកាយពួកខ្លះ ។

<u>ក្នុងអដ្ឋកថានៃបដិច្ចសមុប្បាទ</u> សម្ដែងទុកថា ៖

និរយេ ភុម្មវជ្ជេសុ ទេវេសុ ច ន យោនិយោ
តិស្សោ បុរិមិកា ហោន្តិ ចតស្សោបិ គតិត្តយេ ។

**កំណើត ៣ ខាងដើម (ជលាពុជៈ អណ្ឌជៈ សំសេទជៈ) រមែងមិនមានក្នុងនរក ក្នុងនិជ្ឈាមតណ្ហិកប្រេត និងក្នុងទេពទាំងឡាយវៀរភុម្មទេវតា ចំណែកកំណើត ៤ រមែងមានក្នុងគតិ ៣ (សត្វតិរច្ឆានបិត្តិវិស័យ មនុស្ស) និងពួកភុម្មទេវតា ។**

## ចែកកំណើត ៤ ដោយកម្មជកលាប ៩

*ចំណែកសត្វទាំងឡាយ ដែលកើតក្នុងកាមភូមិ ១១ និង រូបភូមិ ១៦ ចែកដោយកំណើត ៤ ដោយក្រុមនៃរូបមានកម្មជាសមុដ្ឋាន រមែងបាន ដូច្នេះ*

**១, *សំសេទជ និងឱបបាតិក*** *ដែលកើតក្នុងកាមភូមិក្នុង បដិសន្ធិកាល ពោលដោយឧក្កដ្ឋន័យ មានកម្មជកលាបកើត ៧ កលាប គឺ ១-ចក្ខុទសកកលាប ២-សោតទសកកលាប*

*៣-ឃានទសកកលាប ៤-ជិវ្ហាទសកកលាប*

*៥-កាយទសកកលាប ៦-ហទយទសកកលាប*

*៧-ភាវទសកកលាប*

## ឱមកន័យ ក្នុងបដិសន្ធិកាល គឺ

*១- ពួកសំសេទជ: មានកម្មជកលាប ខ្វះខាត មិនលើសអំពី ៤ គឺ ចក្ខុទសកកលាប សោតទសកកលាប ឃានទសកកលាប ភាវទសកកលាប*

២- ទុគ្គតិឱបបាតិកៈ មានកម្មជកលាបខ្វះខាត បាន ៣ គឺ
ចក្ខុទសកកលាប សោតទសកកលាប
ភាវទសកកលាប

៣- សុគតិឱបបាតិកៈ ដែលជាមនុស្សក្នុងសម័យដើមកប្បមានភាវទសកកលាបខ្វះខាត

៤- ពួកឱបបាតិកៈ ដែលជាទេវតាក្នុងបដិសន្ធិកាល មានកម្មជកលាប កើតបាន ៧ កលាប គ្រប់បរិបូណ៌ មានចក្ខុទសកកលាបជាដើម ។[១]

**២, ពួកឱបបាតិកកំណើត** ដែលជារូបព្រហ្ម (វៀរអសញ្ញសត្តាព្រហ្ម) ក្នុងបដិសន្ធិកាលកម្មជកលាបដែលកើតបាន ៤ កលាប គឺ ចក្ខុទសកកលាប ១ វត្ថុទសកកលាប ១ សោត

---

១. អត្ថយោជនា តតិយភាគពោលថា ក្នុងកាមលោកជីវិតនវកៈរបស់ពួកសំសេទជ និងឱបបាតិក កើតក្នុងបវត្តិកាល ព្រោះប្រព្រឹត្តទៅព្រមនឹងបាចនគ្គិ និងកើតព្រោះអាស្រ័យអាហារដែលបរិភោគ ចូលទៅ ។

ទសកកលាប ១ ជីវិតនវកកលាប ១ ។ ក្នុងបវត្តិកាល មិនមាន កម្មជកលាបកើតថែមទៀតទេ មានតែត្រឹមតែ ៤ កលាប ប៉ុណ្ណោះ ។

៣, **ពួកឱបបាតិក** ដែលជាអសញ្ញសត្តាព្រហ្ម ទាំងក្នុង បដិសន្ធិកាល ទាំងក្នុងបវត្តិកាល មានជីវិតនវកកលាប ១ ប៉ុណ្ណោះកើតឡើង ។

៤, **គព្ភសេយ្យកកំណើត** ក្នុងបដិសន្ធិកាល ដោយ ឧក្កដ្ឋន័យ(ន័យបរិបូណ៌) មានកម្មជកលាបកើតបាន ៣ គឺ កាយទសកកលាប ១ ភាវទសកកលាប វត្ថុទសកកលាប១; ពោលដោយឱមកន័យ (ន័យដែលខ្វះខាត) មានកម្មជកលាបកើត បាន ២ គឺ កាយទសកកលាប និងវត្ថុទសកកលាប មិនមាន ភាវទសកកលាប ព្រោះមិនមានភេទ តែក្នុងបវត្តិកាល មានរូប កលាបកើតថែម៥ទៀត គឺ ចក្ខុទសកកលាប សោតទសកកលាប

ឃានទសកកលាប ជិវ្ហាទសកកលាប ជីវិតនវកកលាប[១] ។

ក្នុងចំនួនរូបកលាបទាំងនេះ អាចមានកលាបណាមួយខ្វះខាតបាន ក្នុង ៣ កលាប គឺ ចក្ខុទសកកលាប សោតទសកកលាប ឬ ឃានទសកកលាប ។

## សម្ដែងកម្មជកលាប ដែលកើតក្នុងបវត្តិកាល

ក្នុងបរមត្ថទីបនី សម្ដែងការកើតឡើងនៃកម្មជកលាប ៤ មានចក្ខុទសកៈជាដើមរបស់គព្ភសេយ្យកសត្វ ក្នុងបវត្តិកាលតពីបដិសន្ធិកាលថា ៖

ខាងមុខពីបដិសន្ធិនេះ ទៅកម្មជកលាប ៤ គឺ ចក្ខុ

១. ជីវិតនវកៈនេះ បានដល់ បាចនគ្គិ (ភ្លើងរំលាយអាហារ) ជាឧតុជរូបកើតអំពីកម្មជាបច្ច័យ ។ ចម្រើនជំមាត់ជាបន្តបន្ទាប់ តាមសមគួរតែមិនបានសម្ដែងថា កម្មជកលាបណា កើតមុនកើតក្រោយ ជាការសម្ដែងដោយទេសនាន័យ មិនបានសម្ដែងដោយឧប្បត្តិកន័យ (ន័យលំដាប់នៃការកើត) ។

ទសកកលាប សោតទសកកលាប ឃានទសកកលាប ជិវ្ហាទសកកលាប រមែងកើតឡើង

## ឧប្បត្តិកន័យ

ពោលដោយលំដាប់នៃការប្រាកដ (កើត) នៃរូប មានចក្ខុទសកជាដើម រមែងប្រព្រឹត្តទៅតាមលំដាប់យ៉ាងនេះគឺ "កន្លងទៅបាន ៧ ថ្ងៃ រាប់តាំងពីថ្ងៃដែលចក្ខុទសកប្រាកដ សោតទសកប្រាកដ, តពីនោះ គឺ កន្លងទៅបាន ៧ ថ្ងៃ រាប់តាំងពីថ្ងៃដែលសោតទសកប្រាកដ ឃានទសកប្រាកដ, តពីនោះ គឺ កន្លងទៅបាន ៧ ថ្ងៃ រាប់តាំងពីថ្ងៃដែលឃានទសកប្រាកដ ជិវ្ហាទសកប្រាកដ" ដូច្នេះ ។

<u>ក្នុងសគាថវគ្គ យក្ខសំយុត្ត</u> ព្រះមានព្រះភាគទ្រង់សម្តែងថា ៖

បឋមំ កលលំ ហោតិ   កលលា ហោតិ អព្វុទំ
អព្វុទា ជាយតេ បេសិ   បេសិយា និព្វត្តតី ឃនោ

ឃនា បសាខា ជាយន្តិ  កេសា លោមា នខាបិ ច ។

*កលលរូបកើតជាដំបូង តពីកលលរូបមក កើតជាអព្វុទរូប តពីអព្វុទរូបមក កើតជាបេសិរូប តពីបេសិរូបមក កើតជាឃនរូប តពីឃនរូបមកកើតជាសាខារូប តមកទៀត ទើបកើតសក់ រោម ក្រចក ។*[១]

សប្តាហ៍ដំបូង រូបជា **កលលៈ** មានលក្ខណជាតំណក់ទឹកថ្លាដូចប្រេងល្ង, ក្នុងសប្តាហ៍ទី ២ រូបជា**អព្វុទៈ** មានលក្ខណៈជាពង ដូចទឹកលាងសាច់, ក្នុងសប្តាហ៍ ទី ៣ រូបជា**បេសិ** មានលក្ខណៈជាដុំសាច់រាវ ពណ៌ក្រហម, ក្នុងសប្តាហ៍ទី ៤ រូបជា**ឃនៈ** មានលក្ខណៈជាដុំ ដូចស៊ុតមាន់ ។ ក្នុងសប្តាហ៍ទី ៥ រូបកើតជា **ពក ៥** ។ តពីនោះ ព្រះមានព្រះភាគ កាលទ្រង់សង្ខេបធម៌ទេសនា ដោយកន្លងសប្តាហ៍ទី ៦  ទី ៧ ជាដើម ដើម្បីនឹងសម្តែងវេលាដែលកន្លងទៅដល់ ៤២ សប្តាហ៍ ទើបត្រាស់ថា

---

១. សំយុ. សគា. ឥន្ទកសូត្រ. ៣០. ២៨២/២០៨ ។

សក់ រោម និងក្រចកជាដើម ។ សំដៅសេចក្ដីថា សក់ រោម ក្រចកជាដើម រមែងកើតក្នុង ៤២ សប្ដាហ៍ ។

ក្នុងអភិធម្មវិភាវិនីដីកា អាចារ្យពួកខ្លះថា សប្ដាហ៍ទី១ ជា **កលលៈ** សប្ដាហ៍ទី ២ ជា**អព្វុទៈ** សប្ដាហ៍ទី ៣ ជា**បេសិ** សប្ដាហ៍ទី ៤ ជា **ឃនៈ** សប្ដាហ៍ទី ៥ ជា **បញ្ចសាខៈ** សប្ដាហ៍ទី៦ ជាបរិបាក, សប្ដាហ៍ទី៧ កើតចក្ខុប្រសាទ, សប្ដាហ៍ទី៨ កើតសោតប្រសាទ, សប្ដាហ៍ទី៩ កើតឃានប្រសាទ, សប្ដាហ៍ទី ១០ កើតជិវ្ហា ប្រសាទ, សប្ដាហ៍ទី១១ ជាដើម កើតកេសា លោមាជាដើម ក្នុងមួយសប្ដាហ៍ កើតអាការ មួយ ៗ ដរាបដល់គ្រប់អាការ ៣២ របស់សត្វក្នុងគភ៌ ។

## សម្ដែងការកើតឡើងនៃតិជរូប

(គឺ ចិត្តជរូប ឧតុជរូប អាហារជរូប)

សត្វទាំងឡាយ ដែលកើតក្នុងបញ្ចវោការភូមិនោះ បដិសន្ធិចិត្តកើតព្រមជាមួយកម្មជរូប ក្នុងបដិសន្ធិកាល កាល

បដិសន្ធិចិត្តរលត់ហើយ ចិត្តទី ២ គឺ បឋមភវង្គ ក៏កើតឡើង, ឧប្បាទក្ខណៈរបស់បឋមភវង្គនេះឯង ចិត្តជរូបក៏កើតព្រមជាមួយចិត្ត និងចិត្តជរូបនេះ រមែងកើតឡើងគ្រប់ ៗ ឧប្បាទក្ខណៈរបស់ចិត្ត មិនកើតត្រង់ឋិតិខណៈ ឬភង្គខណៈនៃចិត្ត ព្រោះចិត្តុប្បាទមានកម្លាំងចំពោះត្រង់ឧប្បាទក្ខណៈប៉ុណ្ណោះ ។

ឧតុជរូប គឺ រូបដែលកើតអំពីឧតុជាបច្ច័យ រមែងកើតឡើង ក្នុងរាងកាយរបស់សត្វ តាំងអំពីឋិតិខណៈរបស់បដិសន្ធិចិត្ត នឹងកើតត ៗគ្នាទៅ ដោយមិនបានអាស្រ័យចិត្ត អាស្រ័យតែឧតុប៉ុណ្ណោះកើតឡើង ។

អាហារជរូប គឺ រូបកើតអំពីអាហារជាបច្ច័យ រមែងកើតឡើងដល់ពួកសំសេទជនិងឧបបាតិកកំណើត ក្នុងកាមភូមិនោះ ធំភ្លាម គឺ កាលបដិសន្ធិហើយ ក៏បរិភោគអាហារបានព្រោះអាហាររបស់បុគ្គល ២ ពួកនេះ ផ្តើមកើតតាំងអំពីមនោទ្វារ វិថីដែលកើតក្រោយពីបដិសន្ធិចិត្ត និងភវង្គចិត្ត ។ អាហារជរូបនេះ រមែងកើតជាប់តគ្នាទៅ ដូចគ្នានឹងឧតុនោះឯង ។

***<u>អភិធម្មត្ថវិភាវិនី</u>*** *ពោលថា ៖*

*"ភាវៈនៃឧតុ និងឱជា មានកម្លាំងក្នុងឋិតិខណៈប៉ុណ្ណោះ ព្រោះបានសេចក្តីឧបត្ថម្ភពីបច្ឆាជាតប្បច្ច័យជាដើម ដូច្នេះ ទើបលោកអាចារ្យពោលថា* ***តេជោធាតុ ឋិតិប្បត្តា****ជាដើម" ដូច្នេះ ។*

*ចំណែកពួកគព្ភសេយ្យកបុគ្គល អាហារជរូប រមែងកើតកាលមាតាបរិភោគអាហារ ចូលទៅលេបល្អហើយ ក៏ផ្សាយចូលទៅចិញ្ចឹមរាងកាយរបស់ទារកក្នុងគភ៌ ក្នុងសប្តាហ៍ដំបូង រូបដែលបដិសន្ធិនោះនៅជាកលលៈ អាហារផ្សាយចូលទៅមិនបាន កាលសប្តាហ៍ទី ២ ឬ ៣ អាហារជរូបនោះ ទើបផ្តើមចូលទៅកាន់រាងកាយរបស់ទារកនោះបាន កាលអាហារជរូបកើតហើយ ក៏កើតជាប់តគ្នាទៅ ព្រោះរូបនេះអាស្រ័យអាហារជាបច្ច័យ ។*

***<u>ក្នុងសគាថវគ្គ យក្ខសំយុត្ត</u>*** *ពោលថា ៖*

យញ្ចស្ស ភុញ្ជតី មាតា អន្នំ បានំ ភោជនំ
តេន សោ តត្ថ យាបេតិ មាតុកុច្ឆិគតោ នរោ ។

ឯមាតារបស់សត្វនោះ បរិភោគភោជនណា ទោះបាយក្តី ទឹកក្តី សត្វដែលឋិតនៅក្នុងផ្ទៃមាតានោះ ក៏ញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយភោជននោះ ដូច្នេះ ។[1]

ក្នុងអដ្ឋកថា ពោលថា ពិតមែន ការបរិភោគអាហាររបស់សត្វ ក្នុងគភ៌នោះ ជាប់ដោយខ្សែផ្ចិតរបស់ក្មេងនោះជារន្ធ ដូចទងឈូក និងជាប់គ្នាជាមួយនឹងផ្ទៃពោះមាតា ។ រសអាហារនោះ ស្រូបចូលទៅតាមក្រសែផ្ចិតនោះ អាហារនេះដូចគ្នានឹងរូបដែលមានអាហារជាសមុដ្ឋាន ។ ទារកនោះ រមែងចម្រើនធំឡើងទៅដោយលំដាប់កាលមានប្រមាណ ១០ ខែ ដោយប្រការ ដូច្នេះឯង ។

**ចប់ រូបន័យទី ៥ រូបបវត្តិក្កម**

**ចប់ រូបបរមត្ថ**

---

១. សំយុ. សគា. ឥន្ទកសូត្រ. ៣០. ២៨២/២០៨ ។

# និព្វានបរមត្ថ

ព្រះនិព្វាន ជាបរមត្ថធម៌ដែលល្អិត ប្រណីតជាងនាមធម៌ណា ៗទាំងអស់ ជាធម៌ជ្រាលជ្រៅ ឃើញបានលំបាកដឹងតាមបានលំបាក ស្ងប់ ប្រណីត គិតស្មាន ៗមិនបានទេ ដឹងបានចំពោះបណ្ឌិតដែលបានសម្រេចមគ្គហើយ និងគប្បីដឹងច្បាស់ដោយខ្លួនឯង ជាអារម្មណ៍របស់មគ្គចិត្ត និងផលចិត្ត ។ បុថុជ្ជនទាំងឡាយ មិនអាចធ្វើឱ្យជាក់ច្បាស់បាន ។

## វចនត្ថៈរបស់និព្វាន

ពាក្យថា **និព្វាន** បានដល់ **និ** បទមុខ **វាន** ធាតុ ។

ពាក្យថា **និ** ប្រែថា មិនមាន ឬ **និក្ខន្តំ** ប្រែថា ចេញទៅហើយ ។

ពាក្យថា **វាន** ប្រែថា គ្រឿងរួបរឹត រួមគ្នាជា **និវាន** ( និព្វាន ) ប្រែថា មិនមានគ្រឿងរួបរឹត ។

**វាន** មានវចនត្ថៈថា **ខន្ធាទិភេទេ តេភូមិកធម្មេ ហេដ្ឋុបរិយវសេន វិននតោ សំសិព្វនតោ = វានំ តណ្ហា :** តណ្ហា ឈ្មោះថា វាន ព្រោះរួបរឹត គឺ ដេរទុកនូវធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលផ្សេងដោយធម៌ មានខន្ធជាដើម ដោយអំណាចដែលប្រព្រឹត្តទៅទាំងខាងក្រោម និងខាងលើ ។

**និវាន** ( និព្វាន ) មានវចនត្ថៈថា ៖

**មគ្គផលានមាលម្ពនភូតំ វានសង្ខាតាយ តណ្ហាយ និក្ខន្តត្តា និព្វានន្តិ បវុច្ចតិ :** ធម៌ដែលជាអារម្មណ៍របស់មគ្គផល លោកពោលថា **និព្វាន** ព្រោះចេញចាកពីតណ្ហា ពោលគឺ **វានៈ** ។

<u>**ក្នុងអភិធម្មាវតារ**</u> ពោលវចនត្ថៈ ថា ៖

**ភវាភវំ វិននតោតិ វានំ វុច្ចតិ តណ្ហា តតោ វានតោ និក្ខន្តត្តា និព្វានំ :** តណ្ហា ហៅថា វាន ព្រោះអត្ថថា ដោតក្រងនូវភពតូចធំទុក ដែលឈ្មោះថា និព្វាន ព្រោះចេញចាកពីគ្រឿងដោតក្រងនោះ ។

## សង្គហគាថា

១៣. បទមច្ចុតមច្ចន្តំ អសង្ខតមនុត្តរំ
និព្វានមិតិ ភាសន្តិ វានមុត្តា មហេសយោ ។

ព្រះពុទ្ធទាំងឡាយ អ្នកស្វែងរកគុណដ៏ធំ មានសីលាទិគុណជាដើម រួចផុតហើយចាកតណ្ហា ឈ្មោះថាវានៈ ត្រាស់ហៅ បទធម៌ដែលចូលដល់បាន មានដោយចំពោះ ជាធម៌មិនកម្រើកញាប់ញ័រ ឃានកន្លងខន្ធ ដែលមិនមានបច្ច័យតាក់តែង ជាធម៌ដែលប្រសើរបំផុតថា ព្រះនិព្វាន ដូច្នេះ ។

# អធិប្បាយ គុណរបស់ព្រះនិព្វាន

ព្រះគាថានេះ លោកពណ៌នាគុណរបស់ព្រះនិព្វានទុក ៥ បទ គឺ **បទំ** **អច្ចុតំ** **អច្ចន្តំ** **អសង្ខតំ** និង **អនុត្តរំ** ។ សភាវធម៌៥នេះ សុទ្ធតែជាធម៌ដែលសម្ដែងដល់ព្រះនិព្វាន ។

ពាក្យថា **បទំ** ប្រែថា ធម៌មួយចំណែក សំដៅដល់សភាវធម៌មួយប្រភេទ ដែលចូលដល់បាន មានដោយចំពោះដឹងបានដោយលំបាក ប្រៀបដូចការហើរទៅក្នុងអាកាសរបស់ពួកសត្វដែលមិនអាចដឹងបាន ព្រោះមិនឃើញស្នាមជើង ក្នុងអាកាសយ៉ាងណា គតិរបស់ព្រះខីណាស្រពទាំងឡាយ ដែលបរិនិព្វានហើយ ក៏យ៉ាងនោះ ដឹងបានលំបាក គឺ មិនអាចបញ្ញត្តិបានច្បាស់ដូចសត្វអ្នកទៅហើយ ក្នុងចំណែកទាំង ៥ គឺ ទៅកាន់ភព ៣, កំណើត ៤, គតិ ៥, វិញ្ញាណឋិតិ ៧, សត្តាវាស ៩ ព្រោះដូច្នោះទើបលោកពោលថា **បទំ** បានដល់ ព្រះនិព្វាន ។

ពាក្យថា **អច្ចុតំ** ប្រែថា មិនកម្រើកញ័រ ព្រោះព្រះនិព្វាន

មិនកើត មិនរលត់ ។

ពាក្យថា **អច្ចុតំ** ប្រែថា ឈានកន្លង បានដល់ ធម៌ដែលឈានកន្លងខន្ធទាំងឡាយ ដែលជាអតីត (បុព្វន្តខន្ធ) និងអនាគត ខន្ធ (អបរន្តខន្ធ) ។ ដីកាចារ្យពន្យល់ សេចក្តីថា **បុព្វន្តាបរន្តេ អតិក្កម បវត្តតា អច្ចុតំ** : និព្វាន ឈ្មោះថា អច្ចុតៈ ព្រោះឈានកន្លងធម៌ដែលជាអតីត និងអនាគតប្រព្រឹត្តទៅ ។ លោកហៅនិព្វានថា កាលវិមុត្ត ។

ពាក្យថា **អសង្ខតំ.** ប្រែថា ធម៌ដែលមិនត្រូវតាក់តែងដោយបច្ច័យអ្វី ៗ តែជាបរមត្ថធម៌ ដែលមានដោយពិត ព្រោះដូច្នោះ ទើបហៅព្រះនិព្វានថា អសង្ខតធម៌ ។

ពាក្យថា **អនុត្តរំ** ប្រែថា ធម៌ដែលប្រសើរបំផុត ព្រោះព្រះនិព្វាន មិនមានធម៌ដទៃក្រៃលែងជាង ជាធម្មទំនៀមមានសុខយ៉ាងក្រៃលែង ដូចដែលទ្រង់ត្រាស់ទុកថា ៖

**អមតំ អសង្ខតំ បរមំ សុខំ** : អមតនិព្វាន មិនមានអ្វីប្រជុំតាក់តែង ជាសុខក្រៃលែង ។

## ព្រះនិព្វានមាន ១

ព្រះនិព្វាន កាលសម្តែងដោយសភាវលក្ខណៈ ក៏មានតែមួយ ហៅថា សន្តិលក្ខណៈ សំដៅដល់ សេចក្តីស្ងប់ចាកកិលេស និងខន្ធ ៥ និងពោលដល់លក្ខណាទិតិកៈរបស់ព្រះនិព្វានទុក ដូច្នេះ ៖

សន្តិលក្ខណមច្ចុត រសំ និព្វានអមតំ
អនិមិត្តំ ឧបដ្ឋានំ បទដ្ឋានំ ន លព្ភតិ ។

ក្នុងអភិធម្មាវតារ ពោលទុកម្យ៉ាងទៀតថា ៖

សន្តិលក្ខណំ អច្ចុតរសំ អស្សាសករណរសំ វា
អនិមិត្ត បច្ចុប្បដ្ឋានំ និស្សរណបច្ចុប្បដ្ឋានំ វា

គប្បីជ្រាបពាក្យអធិប្បាយតទៅ ៖

### លក្ខណាទិតិកៈរបស់ព្រះនិព្វាន

១-សន្តិលក្ខណំ មានសេចក្តីស្ងប់ចាកកិលេស និង

ខន្ធ ជាលក្ខណៈ

**២-អច្ចុតិរសំ** មានសេចក្ដីមិនកម្រើកញ័រ ជារស

**អស្សាសករណរសំ វា** ឬមានសភាពស្រោលចិត្ត ជារស

**៣-អនិមិត្តបច្ចុប្បដ្ឋានំ** មិនមាននិមិត្ត ជាអាការប្រាកដ

**និស្សរណបច្ចុប្បដ្ឋានំ វា** ឬថា មានការចេញទៅ ជាអាការប្រាកដ

* **បទដ្ឋានំ ន លព្ភតិ** ព្រះនិព្វានមិនមានហេតុជិតឱ្យកើត ព្រោះព្រះនិព្វានផុតពីហេតុបច្ច័យទាំងពួង ។

## ព្រះនិព្វានមាន ២

ព្រះនិព្វាន កាលសម្តែងដោយបរិយាយនៃហេតុ គឺហេតុដែលឱ្យតាំងឈ្មោះមាន ២ យ៉ាង គឺ ៖

***១-សឧបាទិសេសនិព្វានធាតុ ២-អនុបាទិសេសនិព្វានធាតុ***

## អធិប្បាយ និព្វានធាតុ ២

***១-សឧបាទិសេសនិព្វានធាតុ*** បានដល់ និព្វានធាតុដែលមានវិបាកក្ខន្ធនៅសល់ ។ ព្រះមានព្រះភាគត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអរហន្តខីណាស្រព មានព្រហ្មចរិយៈប្រព្រឹត្តរួចហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយដោយលំដាប់ មានសំយោជនៈក្នុងភពអស់ហើយ ផុតស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ប៉ុន្តែឥន្ទ្រិយទាំង ៥ របស់អរហន្តខីណាស្រពនោះ តាំងនៅដដែលអរហន្តខីណាស្រពនោះ នៅសោយអារម្មណ៍ដែលពេញចិត្ត និងមិនពេញចិត្ត សោយសុខនិងទុក្ខ ព្រោះឥន្ទ្រិយទាំង ៥ នោះ មិនមានសេចក្តី

ថ្នាំងថ្នាក់ទេ ។ ការអស់រាគៈ អស់ទោសៈ អស់មោហៈណា របស់ព្រះអរហន្តនោះ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សឧបាទិសេសនិព្វានធាតុ"[១] បានដល់ ព្រះអរហន្តដែលនៅមានជីវិត ។

ពាក្យថា សឧបាទិសេសនិព្វានធាតុ មកអំពីពាក្យថា **ស + ឧបាទិ + សេស + និព្វាន + ធាតុ** សភាវធម៌ ដែលឈ្មោះថា ឧបាទិ ព្រោះអត្ថថា ត្រូវឧបាទាន មានកាមជាដើម ប្រកាន់ទុកមាំ ពាក្យថា ឧបាទាននេះ ជាឈ្មោះនៃបញ្ចក្ខន្ធ ។ ឧបាទិនោះឯង ដែលនៅសល់អំពីកិលេសទាំងឡាយ ដូច្នេះទើបឈ្មោះថា **ឧបាទិសេស** ។ និព្វានដែលប្រព្រឹត្តទៅដោយឧបាទិសេសនោះ ហេតុនោះ ទើបឈ្មោះថា **សឧបាទិសេស** ។ សឧបាទិសេសនោះឯង ជានិព្វានធាតុ ហេតុនោះ ទើបឈ្មោះថា **សឧបាទិសេសនិព្វានធាតុ** ។

**២-អនុបាទិសេសនិព្វានធាតុ** បានដល់ **និព្វានធាតុ** ដែល

---

១. ខុទ្ទ. ឥតិ. ទុកនិបាត. ៥៣. ៤៤/៥០ ។

មិនមានវិបាកក្ខន្ធនៅសល់ គឺ ព្រះនិព្វានរបស់ព្រះអរហន្ត ដែលបរិនិព្វានហើយ ។

## ព្រះនិព្វានមាន ៣

និព្វាន កាលពោលដោយសេចក្តីផ្សេងគ្នានៃការត្រាស់ដឹង មាន ៣ យ៉ាង គឺ ៖

**១.សុញ្ញតនិព្វាន ២.អនិមិត្តនិព្វាន ៣.អប្បណិហិតនិព្វាន**

និព្វាន ដែលឈ្មោះថា **សុញ្ញត** នុ៎ះឯង ឈ្មោះថា **សុញ្ញតនិព្វាន** ព្រោះជាធម៌ឆ្ងាយចាករាគៈ ទោសៈ និងមោហៈ ទាំងដោយអារម្មណ៍ និងដោយសម្បយោគ ។ ឈ្មោះថា **អនិមិត្ត** ព្រោះវៀរអំពីនិមិត្ត មានរាគៈជាដើម ដោយអាការយ៉ាងនោះ ។ ឈ្មោះថា **អប្បណិហិត** ព្រោះវៀរអំពីទីតាំង គឺ កិលេស មានរាគៈជាដើម ដោយអាការយ៉ាងនោះ ។

ឈ្មោះថា **សុញ្ញត** ព្រោះសូន្យចាកសង្ខារទាំងពួង ។

ឈ្មោះថា **អនិមិត្ត** ព្រោះមិនមាននិមិត្ត គឺ សង្ខារទាំង

ពួង ។

ឈ្មោះថា **អប្បណិហិត** ព្រោះមិនមានទីតាំង គឺ សង្ខារទាំងពួង ។

ន័យមួយទៀត និព្វាន ឈ្មោះថា **សុញ្ញត** ព្រោះស្ងប់ចាក បលិពោធទាំងពួង គឺ ព្រះយោគាវចរ ចម្រើនវិបស្សនាឃើញ ត្រៃលក្ខណ៍ ដោយអនត្តានុបស្សនាជាប្រធាន រហូតដល់ការ សម្រេចមគ្គផល មានព្រះនិព្វានជាអារម្មណ៍ និព្វាននេះ ឈ្មោះថា **សុញ្ញតនិព្វាន** ។

ឈ្មោះថា **អនិមិត្ត** ព្រោះភាពមិនមាននិមិត្ត គឺ ទីកើតនៃ កិលេសទាំងឡាយ និង មិនមានទីកើតនៃធម៌ មានជរា និង មរណៈជាដើម គឺ អ្នកចម្រើនវិបស្សនា ឃើញត្រៃលក្ខណ៍ ដោយអនិច្ចានុបស្សនាជាប្រធាន រហូតដល់ការសម្រេចមគ្គផល មានព្រះនិព្វាន ជាអារម្មណ៍នេះ ឈ្មោះថា **អនិមិត្តនិព្វាន** ។

ឈ្មោះថា **អប្បណិហិត** ព្រោះមិនមានតណ្ហាដែលជា ហេតុនៃទុក្ខទាំងពួង គឺ អ្នកចម្រើនវិបស្សនា ឃើញត្រៃលក្ខណ៍

ដោយទុក្ខានុបស្សនាជាប្រធាន រហូតដល់ការសម្រេចមគ្គផលមាន ព្រះនិព្វានជាអារម្មណ៍ នេះឈ្មោះថា **អប្បណិហិតនិព្វាន ។**

មួយទៀត ព្រះនិព្វាននោះ កាលសម្ដែងដោយជា អារម្មណ៍របស់មគ្គចិត្ត ក៏មាន ៤ តែកាលសម្ដែងដោយការរាប់ តណ្ហា ត្រង់ទ្វារ ៦ ក៏ជានិព្វាន ៦ គឺ រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា និងធម្មតណ្ហា ។

ព្រះមានព្រះភាគទ្រង់សម្ដែងការមិនមានតណ្ហា (តាមទ្វារ ៦) ដែលអរិយមគ្គកាត់ផ្ដាច់ហើយ ដោយអាស្រ័យព្រះនិព្វានជា អារម្មណ៍ ដោយប្រៀបដូចបុរសឃើញនទោងព្រៃកើតក្នុងស្រែ ហើយរកមើលឫស តាំងអំពីចុងរហូតដល់ឃើញគល់ហើយកាត់ ចោល នទោងព្រៃនោះក៏ស្ងួតស្វិត, ទើបមិនមានការបញ្ញត្តិតទៅ យ៉ាងណា តណ្ហាកើតក្នុងអារម្មណ៍ទាំងឡាយ មានផ្លូវភ្នែកជាដើម ដែលជាបិយរូប សាតរូប ត្រូវអរិយមគ្គដកឫសឡើងហើយ ព្រោះអាស្រ័យព្រះនិព្វាន ក៏យ៉ាងនោះដែរ ។

**ចប់ និព្វានបរមត្ថ**

## សង្គហគាថា

១៤ ឥតិ ចិត្តំ ចេតសិកំ រូបំ និព្វានមិច្ចបិ
បរមត្ថំ បកាសេន្តិ ចតុធាវ តថាគតា

ព្រះតថាគតទាំងឡាយ ប្រកាសបរមត្ថធម៌ដោយសង្ខេប ត្រឹម ៤ យ៉ាង គឺ ចិត្ត ចេតសិក រូប និងព្រះនិព្វាន ទុកដោយប្រការដូច្នេះ ។

## អវសានគាថា

ឥច្ចានុរុទ្ធរចិតេ អភិធម្មត្ថសង្គហេ
ឆដ្ឋមោ បរិច្ឆេទោយំ សមាសេនេវ និដ្ឋិតោ ។

បរិច្ឆេទទី៦ នេះ ឈ្មោះថា រូបសង្គហវិភាគក្នុងបករណ៍ ដែលព្រះអនុរុទ្ធាចារ្យរួបរួម រចនាទុកនូវសេចក្តីនៃព្រះអភិធម្ម ដោយសង្ខេប ចប់ហើយដោយប្រការដូច្នេះ ។

**បរិច្ឆេទទី ៦ រូបសង្គហវិភាគ-និព្វានបរមត្ថ ចប់**

យំ ឯត្ថ វុឌ្ឍិមន្តោ សលក្ខណា បូជិតា បរិច្ឆិន្នា
វុត្តាធិកា ច ធម្មា អភិធម្មោ តេន អក្ខាតោ ។
ព្រោះហេតុដែលធម៌ទាំងឡាយ មានសេចក្តីចម្រើន
មានការកំណត់ ជាធម៌ដែលបុគ្គលបូជាហើយ ជាធម៌
ដែលបណ្ឌិតកាត់ជាចំណែកៗ និងជាធម៌ដ៏ក្រៃលែង
ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ក្នុងព្រះ
អភិធម្មនេះ ដូច្នោះ ទើបលោកពោលថា អភិធម្ម ។



ភិក្ខុ អគ្គធីរោ គង់ សុមិត្ត